ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- អង្គការសហប្រជាជាតិ កម្ពុជា និងខ្មែរក្រហម
- ពាក្យស្លោកដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៣១ ខែវិច្ឆិកា ឆ្នាំ២០១០

ស្វែងរកការពិត

លេខ១៣១ ខែវិច្ឆិកា ឆ្នាំ២០១០

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆អង្គការសហប្រជាជាតិ កម្ពុជា និងខ្មែរក្រហម ....................................១

**ផ្នែកឯកសារ**

◆ខ្មែរក្រហម ៖ ការកេណ្ឌទ័ពនិងការជ្រើសរើស ....................................៤

◆ការបញ្ចាំងសាលក្រម ឌុច នៅម៉ាឡៃ ...........................................១០

◆ពាក្យស្លោកដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍............................២៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆សំបុត្រហៅឲ្យត្រឡប់ទៅផ្ទះ .......................................................២៦

◆ក្លាយជាកុមារកំព្រាឪពុក..........................................................២៨

◆គ្រួសារ ហេង នៃហុង ក្នុងរបបខ្មែរក្រហម .....................................៣០

◆អ្នករៀបចំអាហារនៅមន្ទីរក-៦ ...............................................៣២

◆ជួបប្អូនប្រុសវិញបន្ទាប់ពីបែកគ្នាជាងបីទសវត្សរ៍ ...........................៣៤

◆អ្នកដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម .................................៣៦

◆ការនិយាយផ្ទាល់មាត់ និងការអប់រំ ............................................៣៧

**ផ្នែកច្បាប់**

◆ការចោទប្រកាន់អំពីការអនុវត្តផ្នែកសុខាភិបាល ............................៣៩

◆ថិរវេលាកំណត់បីឆ្នាំលើការឃុំខ្លួនបណ្តោះអាសន្ន...........................៤៣

**វេទិកាពិភាក្សាសាធារណៈ**

◆លទ្ធភាពនៃការចោទប្រកាន់អំពើប្រល័យពូជសាសន៍.....................៤៧

◆ការិយាល័យជួយជនរងគ្រោះនៅសាលាក្តីខ្មែរក្រហម....................៥ ១

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆វិញ្ញាណចងចាំ ..............................................................................៥២

◆កែន ឆែម ៖ សៀវភៅស្វែងរកគ្រួសារ....................................៥៧

◆ខ្មោចជីវិត ..............................................................................៥៩



សិស្សវិទ្យាល័យបុស្សរីកែវ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាដៃ លេខនេះ ៖** ហ្គ្រីហ្គោរី ប្រុកណូ, អាន ហាញ្ញុឌួល, ចាន់ ផល្លា, លី សុខចំរើន, ឡូរ៉ា រីលីម, អាមី ហាយនីស, ជេមស៍ ស៊ី. វ៉ូប៊ីត, ជី ទេវិទ្ធិ, ថៃ ច័ន្ទរិទ្ធ, អ៊ូច ប៊ុន, នន់ ឧត្តម **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត គុណ្ណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែៈ** ជា ផល្លា, ទេស ម៉ារីម **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ញ្ញាណ សុជាតិ និង ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុជាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# អង្គការសហប្រជាជាតិ កម្ពុជា និងខ្មែរក្រហមៈ គោលនយោបាយសំខាន់ជាងជនរងគ្រោះ?

នៅពីក្រោយដំណើរទស្សនកិច្ចជាន់ខ្ពស់មកកាន់ប្រទេសកម្ពុជានាពេលខាងមុខរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន តាមរយៈការស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានការចោទជាសំណួរអស់រយៈពេលជាងបីទសវត្សរ៍មកហើយចំពោះកិច្ចខិតប្រឹងប្រែងរបស់អង្គការសហប្រជាជាតិទាក់ទងទៅនឹងដំណើរការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា ។ អង្គការសហប្រជាជាតិដែលមានកម្មវិធីសេវាសុខភាពដ៏ប្រសើរនិងបេសកកម្មរក្សាសន្តិភាពដ៏គួរឲ្យអាម៉ាស់មានកំណត់ហេតុអតីតកាលដ៏ប្របូកប្របល់ក្នុងការដោះស្រាយពីបញ្ហាខ្មែរក្រហមនិងជំរុញលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ។ កំណត់ហេតុដ៏ប្របូកប្របល់ដែលរួមបញ្ចូលទាំងការគាំទ្រជាផ្លូវការចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះនៅតែដក់ជាប់ក្នុងចិត្តរបស់អ្នកនៅរស់ពីរបបខ្មែរក្រហមជានិច្ច ។ ជាលទ្ធផល ជនរងគ្រោះនៃរបបខ្មែរក្រហមគ្រប់រូបសុទ្ធតែស្វាគមន៍ដល់អង្គការសហប្រជាជាតិផង និងស្អែតស្អន់ផង ។ ដូច្នេះហើយ អង្គការសហប្រជាជាតិគួរតែវាយតម្លៃថាតើរបៀបវារៈរបស់ខ្លួននៅប្រទេសកម្ពុជាដើម្បីស្វែងរកសន្តិភាពដ៏សុខសាន្តមួយនិងការលើកកម្ពស់យុត្តិធម៌ផ្លូវច្បាប់ពិតជាអាចផ្តល់ប្រយោជន៍ដល់អ្នកនៅរស់ដែរឬទេ ។

អង្គការសហប្រជាជាតិបានចូលរួមពាក់ព័ន្ធជាមួយនឹងបញ្ហាខ្មែរក្រហមតាមរយៈចំណុចសំខាន់បី ។ ទីមួយគឺក្រោយពេលដែលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ អង្គការសហប្រជាជាតិបានគាំទ្រចលនាខ្មែរក្រហម ។ ខណៈពេលដែលសហគមន៍អន្តរជាតិបានដឹងពីព័ត៌មានទាក់ទិននឹងការបង្អត់អាហារ ការធ្វើទារុណកម្ម និងការសម្លាប់ពីជនភៀសខ្លួនកម្ពុជា អង្គការសហប្រជាជាតិបានសម្រេចអនុញ្ញាតឲ្យខ្មែរក្រហមនៅតែបន្តមានអាសនៈនៅមហាសន្និបាតអង្គការសហប្រជាជាតិដដែល ។ ពីឆ្នាំ១៩៧៩ ដល់ ១៩៨២ ខ្មែរក្រហមដែលមានឈ្មោះថា «កម្ពុជាប្រជាធិបតេយ្យ» បានតំណាងអាសនៈរបស់កម្ពុជា ។ ពីឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៩៣ រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលមានខ្មែរក្រហមជាសមាជិកត្រីភាគីមួយដែរនោះគឺជាអ្នកកាន់អាសនៈនៅអង្គការសហប្រជាជាតិ ។ ដូច្នេះអស់រយៈពេលជាងមួយទសវត្សរ៍ អង្គការសហប្រជាជាតិនៅតែទទួលស្គាល់ខ្មែរក្រហមថាជារដ្ឋាភិបាលស្របច្បាប់នៅកម្ពុជា និងបដិសេធមិនទទួលស្គាល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលគាំទ្រដោយវៀតណាមឡើយ ។ នៅពេលនោះ អ្នកនៅរស់ពីរបបខ្មែរក្រហមមានអារម្មណ៍មិនពេញចិត្តជាខ្លាំង ។ ជាងនេះទៅទៀត នយោបាយសង្គ្រាមត្រជាក់នៅពេលនោះបានបង្វែរចំណាប់អារម្មណ៍ពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាទៅផ្តោតទៅលើ«ការឈ្លានពាន»របស់វៀតណាមមកលើកម្ពុជាវិញ ដែលធ្វើឲ្យអង្គការសហប្រជាជាតិនៅតែគាំទ្រខ្មែរក្រហមដដែល ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងនាមជាម្ចាស់នៃការប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាប្រល័យពូជសាសន៍និងអនុសញ្ញាស្តីពីការធ្វើទារុណកម្ម អង្គការសហប្រជាជាតិមិនគួរផ្តល់អត្តិភាពផ្នែកនយោបាយមុនប្រជាជនដែលនៅរស់រាប់លាននាក់ទាក់ទងនឹងបញ្ហានៃការទទួលស្គាល់របស់រដ្ឋាភិបាលទេ ។

ប៉ុន្តែការគាំទ្ររបស់អង្គការសហប្រជាជាតិចំពោះខ្មែរក្រហមបានផ្លាស់ប្តូរដោយសារការធ្លាក់ចុះនៃរបបកុម្មុយនីស្តនៅអឺរ៉ុបខាងកើតនៅដើមទសវត្សរ៍៩០ ។ នៅខណៈពេលនោះ ទាហានវៀតណាមប្រមាណជា១៥០.០០០នាក់ បានចាកចេញពីប្រទេសកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានបោះបង់ចោលនូវមនោគមន៍វិជ្ជាម៉ាក់ស៊ីសដែរ ។ អង្គការសហប្រជាជាតិ ហើយនិងសហគមន៍អន្តរជាតិបានផ្លាស់ប្តូរផ្តត់គំនិតមកលើប្រទេសកម្ពុជាថ្មីដោយបានបោះបង់ចោលរបបកុម្មុយនីស្ត ។ នេះគឺជាឱកាសមួយសម្រាប់អង្គការសហប្រជាជាតិដើម្បីធ្វើការតបស្នងចំពោះពលរដ្ឋកម្ពុជាវិញបន្ទាប់ពីការគាំទ្រខ្មែរក្រហមអស់រយៈពេលដប់ឆ្នាំ ។

អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា(អ៊ុនតាក់) ត្រូវបានបង្កើតនៅក្នុងឆ្នាំ១៩៩២ ក្នុងគោលបំណងនាំមកនូវសន្តិភាពនិងរបៀបរៀបរយក្នុងសង្គម ។ នេះជាបទពិសោធន៍ថ្មីមួយសម្រាប់ប្រទេសកម្ពុជានិងអង្គការសហប្រជាជាតិ ។ សម្រាប់ប្រជាជនកម្ពុជា នេះគឺជាលើកទីមួយដែលអាជ្ញាធរបណ្តោះអាសន្នបានគ្រប់គ្រងប្រទេសរបស់ខ្លួន ។ សម្រាប់អង្គការសហប្រជាជាតិ នេះគឺជាលើកទីមួយដែលខ្លួនបានគ្រប់គ្រងទៅលើរដ្ឋបាលរបស់ប្រទេសដែលមានបូរណភាព និងរៀបចំការបោះឆ្នោតដើម្បីដោះស្រាយបញ្ហា ។ តម្លៃសម្រាប់ដំណើរការរបស់អង្គការសហប្រជាជាតិមានទឹកប្រាក់ចំនួនពីរពាន់លានដុល្លារ ។ នេះជាចំនួនមួយដ៏ច្រើនដែលអង្គការសហប្រជាជាតិបានចំណាយលើដំណើរការរក្សាសន្តិភាពនៅពេលនោះ ។ ប៉ុន្តែអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាមិនបានដកហូតអាវុធរបស់ខ្មែរក្រហមទេ ដែលធ្វើឲ្យអ្នកទាំងនោះមានឱកាសបន្តធ្វើសង្គ្រាមស៊ីវិលទ្រង់ទ្រាយតូចជាច្រើនឆ្នាំបន្តទៀត ។


លោក បាន គីមូន ថ្លែងសុន្ទរកថានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខែតុលា ឆ្នាំ២០១០

ការចូលរួមថ្មីៗនេះរបស់អង្គការសហប្រជាជាតិទៅលើបញ្ហាខ្មែរក្រហមបានធ្វើឲ្យមានទម្រង់ស្មុគស្មាញមួយទៀតនៃតុលាការកូនកាត់ដែលគ្រប់ដណ្តប់ដោយភាគីកម្ពុជាដែលមានឈ្មោះជាផ្លូវការថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ កាលពីពេលចាប់ផ្តើមដំណើរការដំបូងមក តុលាការនេះស្ថិតនៅក្នុងការតស៊ូមួយរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ នៅទីបញ្ចប់ អង្គការសហប្រជាជាតិបានសម្រុះសម្រួលនិងចុះញ៉មភាគីកម្ពុជាដែលគ្រប់ដណ្តប់ធំជាងខ្លួននៅក្នុងតុលាការដែលប្រព័ន្ធតុលាការកម្ពុជាមានភាពទន់ខ្សោយ ឱនថយ និងមានសម្ពាធផ្នែកនយោបាយជាខ្លាំង ។ គួរឲ្យហួសចិត្តទៅទៀតនោះគឺថាការចោទប្រកាន់ពីអំពើពុករលួយ និងការចោទប្រកាន់អំពីឥទ្ធិពលផ្នែកនយោបាយបានកើតមាននៅក្នុងតុលាការក្នុងអំឡុងឆ្នាំទីមួយនៃកិច្ចដំណើរការតុលាការនេះ ។ ការិយាល័យអង្គការសហប្រជាជាតិនៃសេវាកម្មត្រួតពិនិត្យផ្ទៃក្នុងបានស៊ើបអង្កេតករណីនៃការចោទប្រកាន់នេះ ហើយបានចេញរបាយការណ៍មួយច្បាប់កាលពីឆ្នាំ២០០៨ ។ ប៉ុន្តែរបាយការណ៍នេះត្រូវរក្សាទុកជាការសម្ងាត់ ហើយមិនបានផ្សព្វផ្សាយជាសាធារណៈទេ ។ ស្រដៀងគ្នានេះដែរការស៊ើបអង្កេតផ្សេងគ្នាមួយដែលធ្វើឡើងដោយក្រុមប្រឹក្សា

ឯករាជ្យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញរបាយការណ៍របស់ខ្លួនមួយ ហើយទុកជាការសម្ងាត់ដដែល ។ ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែរស់នៅក្នុងភាពអន្ទះអន្ទែងដដែល ។

ក្តីបារម្ភមួយទៀត គឺទាក់ទងនឹងចំនួនជនត្រូវចោទដែលនឹងត្រូវយកមកកាត់ទោស ។ នៅក្នុងដំណាក់កាលនៃការចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គការសហប្រជាជាតិចង់ឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមច្រើនរូបជាងអ្វីដែលរដ្ឋាភិបាលកម្ពុជាចង់ឲ្យ ។ រាជរដ្ឋាភិបាលកម្ពុជាហាក់បីដូចជាលាតត្រដាងឲ្យឃើញកាន់តែច្បាស់ទៅលើករណីជម្លោះនេះ ដោយការប្រើប្រាស់អំណាចផ្លូវច្បាប់ក្នុងការកាត់ទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយកំណត់អ្នកដែលត្រូវយកមកកាត់ទោសគឺ «មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត» ។ អតីតមេដឹកនាំចំនួនប្រាំរូបត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមនូវការចោទប្រកាន់ចំពោះមេដឹកនាំទាំងប្រាំនេះ ។ ក្រោយមក អតីតសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ើត ពើទីត បានធ្វើការបញ្ជាក់អំពីលទ្ធភាពក្នុងការកាត់ទោសបុគ្គលច្រើនជាងប្រាំរូប ។ រាជរដ្ឋាភិបាលកម្ពុជាបានឆ្លើយតបប្រឆាំងនឹងបញ្ហានេះភ្លាមៗ ដោយព្រមានថាការកាត់ទោសជនត្រូវចោទបន្ថែមអាចនឹងនាំប្រទេសទៅរកអស្ថិរភាពនិងអំពើហិង្សាផ្សេងៗ និងគំរាមកំហែងដល់ភាពសុខសាន្តដែលកម្ពុជាមានអស់រយៈពេលពីរទសវត្សរ៍មកហើយ ។ សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង បានគាំទ្រដល់ជំហររបស់រាជរដ្ឋាភិបាល ។ ក្រោយមក រ៉ូប៊ើត ពើទីត បានលាលែងពីតំណែងជាសហព្រះរាជអាជ្ញា ។ ភាគីអង្គការសហប្រជាជាតិមិនបានធ្វើឲ្យបញ្ហានេះស្ងប់ស្ងាត់ទេ តែនៅតែប្រឹងប្រែងព្យាយាមចោទប្រកាន់មេដឹកនាំខ្មែរក្រហមបន្ថែមទៀត ។

នៅអំឡុងពេលនៃការខ្វែងគំនិតគ្នានេះ មនុស្សម្នាក់ៗមានការងឿងឆ្ងល់ថាតើក្តីប្រាថ្នារបស់អ្នកដែលធ្លាប់រស់រានមានជីវិតត្រូវបានពិចារណាឬក៏អត់ ។ របាយការណ៍របស់គម្រោង «ចូលរួមរបស់ជនរងគ្រោះ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ២០០៩ បានរៀបរាប់ថា ៤១,៤ភាគរយនៃប្រជាជនចំនួន១.១១០នាក់ ដែលបានធ្វើការស្ទាបស្ទង់មតិមិនចង់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាត់ទោសជនបន្ថែមទៀតទេ ។ ចំណែកឯប្រជាជនចំនួន៥៦,៨ភាគរយទៀត ចង់ឲ្យមានការកាត់ទោសបន្ថែម ។

គួរកត់ចំណាំផងដែរថា ប្រជាជនប្រមាណជា៣០ភាគរយគឺជាក្មេងដែលកើតក្រោយជំនាន់ខ្មែរក្រហមមានអាយុចាប់ពី២០ដល់៣០ឆ្នាំ ។ ទោះបីមនុស្សដែលកើតក្រោយជំនាន់ខ្មែរក្រហមមិនមានចំណេះដឹងច្រើនពីរបបខ្មែរក្រហមក៏ដោយ ក៏ក្រុមមនុស្សប្រភេទនេះយល់ដឹងច្រើនពីគំនិតតាមបែបបស្ចិមប្រទេសនៃយុត្តិធម៌តាមផ្លូវច្បាប់ដែរ ។ ការស្ទាបស្ទង់មតិនោះក៏បានរកឃើញដែរថា ៦៧,៥ភាគរយចង់ឲ្យមានការកាត់ទោសជនបន្ថែមទៀត ។ សម្រាប់ជនរងគ្រោះដែលធ្លាប់ជួបបទពិសោធន៍ផ្ទាល់កាលពីជំនាន់ខ្មែរក្រហមប្រមាណជា៥២ភាគរយ ចង់ឲ្យមានការកាត់ទោសបន្ថែម ។ តាមរយៈតួលេខនេះ នេះជាការលំបាកណាស់ថាតើអង្គការសហប្រជាជាតិ ឬរដ្ឋាភិបាលកម្ពុជាអះអាងពីសេចក្តីសម្រេចរបស់ខ្លួនដើម្បីបន្ថែមចំនួនជនដែលត្រូវយកមកកាត់ទោសនិងដើម្បីកំណត់ចំនួនជាក់លាក់ណាមួយក្នុងការឆ្លុះបញ្ចាំងពីចំនួនជនរងគ្រោះភាគច្រើនឬយ៉ាងណានោះ ។ អង្គការសហប្រជាជាតិគួរគិតគូរពីឱកាសនេះឲ្យបានហ្មត់ចត់ថាតើអ្វីជាផលប្រយោជន៍ដ៏សំខាន់បំផុតរបស់ជនរងគ្រោះ ។ ការគិតពីប្រយោជន៍នយោបាយច្រើនជាងបញ្ហាសិទ្ធិមនុស្សដ៏សំខាន់នេះនឹងជាសញ្ញាណថ្មីមួយទៀតចំពោះជនរងគ្រោះគឺថា រឿងរ៉ាវនយោបាយមានសារសំខាន់ជាងការរងគ្រោះ និងការបាត់បង់របស់មនុស្សជាតិទៅទៀត ។ រដ្ឋបាលថ្មីរបស់អង្គការសហប្រជាជាតិនៅតែមានឱកាសនៅឡើយក្នុងការផ្លាស់ប្តូរស្លាកស្នាមដែលប្រកបដោយបញ្ហាផ្សេងៗកាលពីអតីតកាលរបស់ខ្លួនអំពីបញ្ហាខ្មែរក្រហមដោយការកែប្រែពីវិធីដំណើរការងារប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់និងម៉ឺងម៉ាត់ជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នេះទើបហៅថាសាលាក្តីនេះពិតជាបង្កើតឡើងសម្រាប់ជនរងគ្រោះប្រាកដមែន ។

**កែវ ជាស៊ីល**

# ខ្មែរក្រហម ៖
# ការកេណ្ឌទ័ពនិងការជ្រើសរើស ការបណ្តុះបណ្តាលនិងការអភិវឌ្ឍ

***(តពីលេខមុន)***

ឧបករណ៍បំពងសំឡេងត្រូវបានដំឡើងនៅក្នុងសហករណ៍ដើម្បីចាក់ភ្លេង និងចម្រៀងបដិវត្តន៍ ដោយសំឡេងឮខ្លាំងៗ ។ បន្ទាប់ពីសង្គ្រាមចប់ភ្លាម ខ្មែរក្រហមបានព្យាយាមបញ្ចូលកំហឹងបដិវត្តន៍ទៅកាន់កម្មាភិបាលដែលទើបនឹងជ្រើសរើសឲ្យចូលបម្រើការក្នុងគោលបំណងឲ្យកម្មាភិបាលទាំងនោះមានកំហឹងយ៉ាងស្រួចស្រាល់ចំពោះសត្រូវ ។

*ភូមិបរិបូរបង្ហូរទឹកភ្នែក សត្រូវទម្លាក់គ្រាប់បែក និងរដ្ឋប្រហារ ។ សម្រែកមិត្តយុទ្ធជន និងយុទ្ធនារី តើអ្នកនៅទីណា? សត្រូវកំណាចសម្លាប់មិត្តខ្ញុំ ។ ពេលមិត្តស្លាប់ទៅមិត្តមានខ្លួនទទេ ពោះ ទ្រូងរហែក សួត ថ្លើមខ្លាត់បាត់អស់ អ្នកអណ្តែតទៅឆ្ងាយដូចខ្សែទឹកហូរ ។ សួត ថ្លើម បាត់អស់ធ្វើឲ្យស្រណោះ ។ ដីស្រែរបស់ម៉ែនៅឆ្ងាយ ។ ថ្ងៃទេរនៅលើខ្នងភ្នំពណ៌ខៀវ ។ នៅពេលមិត្តស្លាប់ទៅ អ្នកនៅតែធ្វើឲ្យខ្ញុំចងចាំ សត្រូវកំណាចបានលេបត្របាក់ទឹកដីកម្ពុជា ។*

តាមរយៈវិន័យបដិវត្តន៍ចំនួន៩ក្នុងចំណោមវិន័យទាំង១៥ បានបញ្ជាក់ថា មាគ៌ាបដិវត្តន៍ខ្មែរក្រហម «ត្រូវតែបន្តដុតកំហឹងទៅលើសត្រូវ» ។ ខែល បាននិយាយថា វគ្គបំពាក់បំប៉ននយោបាយរបស់ខ្មែរក្រហមបានប្រាប់យើងពី «ទំហំនៃកំហឹងឈឺចាប់ចំពោះវណ្ណៈជិះជាន់ ។ ខ្មែរក្រហមបាននិយាយពាក្យនេះគ្រប់ពេល» ។ ខ្មែរក្រហមបានទទួលជោគជ័យក្នុងការបញ្ចេះឲ្យមានកំហឹងវណ្ណៈដើម្បីអប់រំមនុស្សម្នាក់ៗឲ្យមានការស្អប់និងចង់ «ស៊ីសាច់ហុតឈាម» ចំពោះសត្រូវ ។ ឡូ ជាជនរងគ្រោះពីរបបខ្មែរក្រហមម្នាក់ទៀតបាននិយាយថា នៅក្នុងវគ្គបំពាក់បំប៉ននយោបាយគាត់ត្រូវបានអប់រំថា «អ្នកក្រនៅតែក្រ ហើយអ្នកមាននៅតែមានដោយសារអ្នកក្រ ខ្មែរក្រហមចង់ឲ្យយើងមានអារម្មណ៍ឈឺចាប់ចំពោះអំពើកេងប្រវ័ញ្ច ឲ្យយើងស្អប់ និងប្រយុទ្ធយ៉ាងក្លៀវក្លាប្រឆាំងនឹងមូលធននិយម វណ្ណៈសក្តិភូមិ ម្ចាស់ដី និងអ្នកមានដែលកេងប្រវ័ញ្ចអ្នកក្រ» ។ កម្មាភិបាលខ្មែរក្រហម និងអ្នកណែនាំមនោគមន៍វិជ្ជាបានប្រើពាក្យពេចន៍ទាំងអស់នេះដើម្បីដុតកំហឹងកសិករក្រីក្រ «ដើមនៅឯស្រែ ផ្លែនៅឯក្រុង» ។ ទស្សនាវដ្តីទង់បដិវត្តន៍ចេញខែកក្កដា ឆ្នាំ១៩៧៧ បានសរសេរថា កម្មាភិបាលខ្មែរក្រហមមានស្មារតីនយោបាយដែលមានធាតុផ្សំសំខាន់បីជាមូលដ្ឋាននៃស្មារតីប្រយុទ្ធប្រចាំថ្ងៃ ៖

១) មានកំហឹងនឹងសត្រូវជាប្រចាំ

២) មានគំនិតបដិវត្តន៍ជ្រាលជ្រៅប្រឆាំងដាច់ខាតចំពោះវណ្ណៈជិះជាន់

៣) មានមនសិការស្នេហាជាតិ បដិវត្តន៍ សហករណ៍ និងបក្ស ។

កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមរំពឹងថា កម្មាភិបាលបក្សជាន់ខ្ពស់នឹងបន្តពង្រីកសេចក្តីណែនាំនយោបាយរបស់ថ្នាក់លើដើម្បីជ្រើសរើសសមាជិកថ្មីក្រោមគំនិតនៃការ «ជិះជាន់» ។ នៅខែមីនា ឆ្នាំ១៩៧៦ មេដឹកនាំបក្សបានផ្តល់សិទ្ធិទៅឲ្យកម្មាភិបាលថ្នាក់ក្រោមប្រើប្រាស់អំពើហិង្សាដើម្បីកម្ទេចសត្រូវទាំងក្នុងនិងក្រៅជួរបក្ស ។ ផាច់ ខៀម ដែលបានចូលជាមួយខ្មែរក្រហមនៅឆ្នាំ១៩៧០ បាននិយាយថា «ខ្មែរក្រហមក៏បាននិយាយរឿងនយោបាយស៊ីជម្រៅអំពីទស្សនៈនយោបាយទាក់ទងនឹងការកេងប្រវ័ញ្ចរបស់អ្នកមានដែរ ។ ជាឧទាហរណ៍ ខ្មែរក្រហមនិយាយថាខ្ញុំមានកំហឹងនឹងពួកមូលធននិយម និងពួកចក្រពត្តិអាមេរិក ។ ខ្មែរក្រហមនិយាយទៀតថា វិធីសាស្ត្ររបស់ពួកមូលធននិយម និងចក្រពត្តិនិយមគឺ ជិះជាន់ ធ្វើបាប សង្កត់សង្កិនប្រជាជនក្រីក្រ និង

ជញ្ជក់ឈាមពីប្រជាជន ។ នោះគឺជាអ្វីដែលខ្មែរក្រហមនិយាយមុនគេ ។ ការបន្តធ្វើឲ្យមានកំហឹង និងគំនិតភ័យខ្លាចតាមរយៈការឃោសនាបានធ្វើឲ្យយុវកុមារមានឆន្ទៈមោះមុតក្នុងសង្គ្រាម ។ កុមារជាច្រើនត្រូវបានណែនាំឲ្យជឿថាអ្នកទីក្រុងជាពួកចក្រពត្តិនិយមដែលប្រឆាំងនឹងបដិវត្តន៍ ដូច្នេះត្រូវតែកម្ទេចចោល ។

## ការទីពឹងលើខ្លួនឯង

ខ្លួនទីពឹងខ្លួន និងឯករាជ្យម្ចាស់ការគឺជាគំនិតរួមនៃមនោគមន៍វិជ្ជារបស់ខ្មែរក្រហមដែលត្រូវបានបង្រៀនទៅដល់មហាជន ជាពិសេសទៅកាន់អ្នកក្រ និងយុវជន ។ នេះជាគំនិតខ្មែរគួរតែធ្វើអ្វីៗទាំងអស់ដោយខ្លួនឯង មានន័យថា កសាងសង្គមថ្មីមួយដោយគ្មានចម្លងចេញពីខាងណាទេ ។ ក្រោយមក ប៉ុល ពត អះអាងថា «យើងកំពុងកសាងសង្គមនិយមមួយដោយគ្មានចម្លងចេញពីប្រទេសណាទាំងអស់ ។ យើងមិនចង់ចម្លងចេញពីនរណាម្នាក់ឡើយ» ។ ដើម្បីកម្ចាត់ឥទ្ធិពលអប់រំតាមបែបបស្ចិមប្រទេស និងបង្កើតកម្មវិធីសិក្សាដោយខ្លួនឯងឲ្យស្របទៅនឹងពាក្យខ្លួនទីពឹងខ្លួន ខ្មែរក្រហមបានបង្កើតកម្មវិធីអប់រំដើម្បីសម្រេចតាមគោលនយោបាយរបស់ខ្លួន ។ នៅឆ្នាំ១៩៧៨ ប៉ុល ពត បាននិយាយថា «គ្មានសាលារៀន គ្មានមហាវិទ្យាល័យ សកលវិទ្យាល័យទេកាលពីអតីតកាល» ។ ខៀវ សំផន បានលើកឡើងថា របបចាស់ (រដ្ឋាភិបាលរបស់ សម្តេច សីហនុ) គឺខ្វះសមត្ថភាពក្នុងការអប់រំសិស្សនៅគ្រប់កម្រិតទាំងអស់ ពីព្រោះសិស្សទាំងនោះមិនទទួលបានចំណេះដឹងអំពី «វិទ្យាសាស្ត្រធម្មជាតិ» ពិតប្រាកដទេ ។ ខៀវ សំផន លើកឡើងថា កូនសិស្សទាំងនេះមិនដឹងពីរបៀបដាំស្រូវ ឬច្រូតស្រូវទេ ជាលទ្ធផល សិស្សទាំងនោះមិនដឹងពីការពិតជាក់ស្តែងឡើយ ។ ខៀវ សំផន និយាយទៀតថា «អ្វីទាំងអស់ត្រូវបានធ្វើតាមសៀវភៅ និងតាមបែបបរទេសប៉ុណ្ណោះ ។ ដូច្នេះ វាជារឿងគ្មានបានការ ហើយមិនអាចបម្រើសេចក្តីត្រូវការរបស់ប្រជាជនឡើយ ហើយក៏មិនអាចជួយកសាងប្រទេសបានដែរ» ។ ជាលទ្ធផលមនោគមន៍វិជ្ជានេះបានជំទាស់រាល់ប្រពន្ធ័អប់រំពីសង្គមចាស់ដោយបង្កើតប្រពន្ធ័អប់រំថ្មីមួយទៀតជាមួយនឹងបុសគល់កុម្មុយនីស្ត ។

ហាំង ងៅ ត្រូវបានចាត់ទុកជាប្រជាជន «ថ្មី» នៅក្រោមរបបខ្មែរក្រហម បាននិយាយថា ថ្នាក់បណ្តុះបណ្តាលមនោគមន៍វិជ្ជាភាគច្រើននិយាយពីហេតុអ្វីបានជាសង្គមថ្មីគួរតែចៀសវាងពីការពឹងផ្អែកទៅលើបរទេស និងរៀបរាប់អំពីឆន្ទៈគោលនយោបាយឯករាជ្យម្ចាស់ការរបស់កម្ពុជាប្រជាធិបតេយ្យ «ទស្សនៈសំខាន់របស់សង្គមថ្មីគឺភាពឯករាជ្យម្ចាស់ការ ដែលកម្មាភិបាលខ្មែរក្រហមនិយាយប្រាប់យើងគ្រប់ពេលក្នុងវគ្គបណ្តុះបណ្តាលមនោគមន៍វិជ្ជាម្តងៗ ។ ពាក្យនេះកើតចេញពីពាក្យពីរម៉ាត់គឺឯករាជ្យនិងម្ចាស់ការ ។ សម្រាប់កម្ពុជាប្រជាធិបតេយ្យ ពាក្យនេះមានន័យថា មានសេរីភាពទាំងស្រុង ដោយមិនទទួលជំនួយបរទេស និងឥទ្ធិពលវប្បធម៌ពីប្រទេសដទៃឡើយ ។ យើងជាប្រជាជនខ្មែរត្រូវធ្វើអ្វីៗដោយខ្លួនឯង ។ តាមរយៈការរៀបចំឡើងវិញការប្រើប្រាស់កម្លាំងប្រជាជន និងការលុបបំបាត់អ្វីដែលមិនរំខានដល់ការងាររបស់យើង យើងនឹងក្លាយជាប្រទេសរុងរឿងរីកចម្រើន និងអភិវឌ្ឍយ៉ាងឆាប់រហ័ស» ។

សេចក្តីណែនាំរបស់បក្សចុះខែកញ្ញា ឆ្នាំ១៩៧៥ បង្ហាញថាគោលបំណងរបស់ខ្មែរក្រហមគឺមិនចង់បដិសេធវិស័យអប់រំទាំងស្រុងទេ ។ ឯកសារនេះបញ្ជាក់ថា នៅតាមតំបន់នីមួយៗកំពុងបង្កើតសាលាថ្មីៗជាបន្តបន្ទាប់ ។ លើសពីនេះទៅទៀត ឯកសារនេះបញ្ជាក់ថា សម្រាប់សិស្សចង់រៀនពិសេសក្រៅម៉ោង សាលារៀនដែលចប់នៅពេលថ្ងៃត្រង់សុទ្ធសឹងទទួលបានលទ្ធផលល្អ ។ អេយើរ ជឿថា នៅក្នុងឯកសារនេះ គោលបំណងរបស់បក្សគឺ «រដ្ឋត្រូវតែរៀបចំសៀវភៅលំហាត់ និងខ្មៅដៃសម្រាប់សិស្ស ហើយត្រូវតែមានគ្រូជំនាញ ប៉ុន្តែគ្រូទាំងនោះត្រូវតែបង្រៀនខ្លួនឯងក្នុងចំណោមចលនាមហាជនជាមុនសិន» ។ ឯកសារទាំងនេះបង្ហាញថា ប្រពន្ធ័អប់រំថ្មីមួយនេះនឹងបង្កើតឡើងនៅក្នុងសង្គមថ្មីមួយបានដោយជោគជ័យ ។ ខ្លួនទីពឹងខ្លួនក៏បានផ្លាស់ប្តូរពីការប្រើឧបករណ៍បច្ចេកទេស និងគ្រឿងម៉ាស៊ីនមកប្រើប្រាស់កម្លាំងមនុស្សវិញដែរ ។ ខៀវ សំផន បាននិយាយថា «តើជោគជ័យទាំងអស់នេះកើតឡើងដោយសារគ្រឿងម៉ាស៊ីនឬយ៉ាងណា? យើងគ្មានម៉ាស៊ីនទេ ។ យើងធ្វើអ្វីៗដោយពឹងផ្អែកលើកម្លាំងប្រជាជនយើងទាំងអស់ ។ យើងធ្វើការទទួលបានជោគជ័យទាំងស្រុងដោយខ្លួនយើង ។ ជោគជ័យនេះបង្ហាញពីវីរភាពរបស់ប្រជាជន

យើង ។ ប្រជាជនយើងអាចធ្វើអ្វីៗ បានដោយដៃទទេ» ។

## ភាពស្មោះត្រង់ចំពោះបក្ស (អង្គការ)

អង្គការជានិមិត្តរូបនៃរបបថ្មី ។ លោក ហ៊ីនតុន បានអះអាងថាអង្គការ «ជាបណ្តុំគំនិតរបស់ខ្មែរក្រហមដែលផ្សារភ្ជាប់ទៅនឹងគំនិតជឿនលឿន មនោគមន៍វិជ្ជាកុម្មុយនីស្ត និងការយល់ដឹងរបស់ប្រជាជនក្នុងស្រុក ដើម្បីយកទៅប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព» ។ តាមរយៈការផ្សព្វផ្សាយតាមវិទ្យុ ការនិយាយបូរបាច់ និងការថ្លែងសុន្ទរកថារាល់ថ្ងៃ អង្គការត្រូវបានបង្កើតដោយគ្មានរូបរាង ដែលបានលើកទឹកចិត្តឲ្យប្រជាជនត្រូវតែជឿ និងស្រឡាញ់ងប់ងុល ។ នៅក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ខ្មែរក្រហមបាននិយាយប្រាប់ថា អង្គការបានផ្តល់សិទ្ធិឲ្យប្រជាជនជាម្ចាស់ទឹកដី ។ អង្គការបានរំពុកលើបញ្ហានេះម្តងហើយម្តងទៀត ដើម្បីឲ្យប្រជាជនគោរពអង្គការ និងដើម្បីប្រាប់ថា អង្គការដឹងពីចិត្តរបស់ប្រជាជនទាំងអស់ ។ អង្គការបាននិយាយគ្រប់ម៉ាត់ក្នុងការឃោសនាថា «ជាអាទិទេពដែលមិនអាចប្រឆាំងបាន» ហើយទទួលខុសត្រូវក្នុងការផ្តល់អាហារ និងសម្លៀកបំពាក់ដល់ប្រជាជន ដោយលះបង់នូវកម្មសិទ្ធិសួនតួទាំងអស់ ។ អ្នកដែលបានជ្រើសរើសឲ្យចូលរួម និងអ្នកបដិវត្តន៍ថ្មីៗត្រូវបានប្រាប់ថា «អង្គការភ្នែកម្នាស់ អង្គការដឹងពីសកម្មភាពគ្រប់យ៉ាងរបស់មនុស្សគ្រប់រូប ហើយតែងតែឃ្លាំមើលជានិច្ច ដែលនេះជាវិធីរំពុកដល់កម្មាភិបាលថ្មីថា ពួកគេនឹងត្រូវបានតាមដាន ដូច្នេះត្រូវតែប្រុងប្រយ័ត្នពីការប្រព្រឹត្តនានា ។ ប្រសិនបើអង្គការត្រូវបានប្រជាជនដឹងថាជាជនបដិវត្តន៍ ដូច្នេះអង្គការកំពុងតែតាមដានជនគ្រប់រូប ដូចជនបដិវត្តន៍ត្រូវទាមទារឲ្យមានការតាមដានលើសមាជិកក្រុមដទៃទៀតដើម្បីបញ្ជាក់ថា រាល់សកម្មភាពរបស់អ្នកឯទៀតត្រឹមត្រូវ និងគោរពតាមគោលនយោបាយរបស់បក្ស ។ ការមានឆន្ទៈចង់នៅជាមួយគ្រួសារនិងទំនាក់ទំនងសាសនាមិនត្រូវនឹងគោលការណ៍ទៅកាន់អង្គការទេ ។

ខ្មែរក្រហមយល់ឃើញថា ទាំងគ្រួសារ និងសាសនាជាប្រភពនៃភាពមិនស្មោះត្រង់ ហើយមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើយុវជនដែលកំពុងទទួលការបំពាក់បំប៉នមនោគមន៍វិជ្ជា ។ ក្មេងៗនិងយុវជនត្រូវបានអប់រំថាគួរតែស្មោះត្រង់នឹងបក្សមិនមែនក្រុមគ្រួសារទេ ។ គ្រូបង្រៀនដែលបានបង្រៀនក្មេងៗជាកម្មាភិបាលរបស់បក្សនៅទីក្រុងភ្នំពេញបានរាយការណ៍ថា ក្មេងៗកំពុងរៀនសូត្រមនោគមន៍វិជ្ជាយ៉ាងយកចិត្តទុកដាក់ ។ ការបង្រៀនទៀងទាត់ត្រូវបានផ្តល់ដោយអង្គការ ហើយក្មេងៗទាំងនោះគួរតែសម្តែងការពេញចិត្តចំពោះអង្គការ ដោយគោរពតាមគោលការណ៍របស់បក្ស ។ លឿង អ៊ីង ជាកុមារនៅក្នុងរបបខ្មែរក្រហមមិនមានបំណងទៅចូលរួមនឹងកងកុមារ និងសាលារៀនទេ ដោយគាត់បានរំពុកថា កម្មាភិបាលខ្មែរក្រហម ឬគ្រូបង្រៀននឹងបង្រៀនមេរៀនដដែលៗទៅកាន់ក្មេងៗអំពីតួនាទីចំពោះអង្គការ និងតួនាទីចម្បងនៅក្នុងបដិវត្តន៍ ៖

*«តួនាទីទីមួយគឺអង្គការ...អ្នកគឺជាកូនរបស់អង្គការ! អ្នកគឺជាសសរទ្រូងប្រទេសជាតិ ។ អង្គការដឹងថាអ្នកមានគំនិតបរិសុទ្ធ មិនពុករលួយដោយសារឥទ្ធិពលអាក្រក់ អ្នកនៅតែអាចរៀនពីមាគ៌ារបស់អង្គការ! នេះគឺជាអ្វីដែលអង្គការស្រឡាញ់អ្នកទាំងអស់គ្នា ។ ហេតុនេះអង្គការផ្តល់អំណាចគ្រប់យ៉ាងឲ្យអ្នក ។ អ្នកជារបស់យើងទាំងអស់គ្នា!» ។*

ដោយធ្វើតាមបទបញ្ជាដែលគ្មានការជំទាស់ ការស៊ើបការណ៍ពីអ្នកផ្សេង និងការរាយការណ៍ពីសកម្មភាពក្បត់រួមទាំងសមាជិកក្រុមគ្រួសារផងនោះ ក្មេងៗត្រូវបានរំពឹងទុកថាមានភាពស្មោះត្រង់នឹងឪពុកម្តាយថ្មី គឺអង្គការ ។ ចំពោះកម្មាភិបាល និងយុទ្ធជនដែលទទួលការបំពាក់បំប៉នមនោគមន៍វិជ្ជាថ្មីៗ ខ្មែរក្រហមព្យាយាមរៀបចំវគ្គសិក្សាជុំវិញសារសំខាន់នៃភាពម្ចាស់ការដោយពឹងផ្អែកលើអង្គការ ។ អង្គការមានភារកិច្ចទទួលខុសត្រូវលើការផ្តល់ឋានៈកិត្តិយស អាវុធយុទ្ធភណ្ឌ និងអាហារដល់កម្មាភិបាលខ្មែរក្រហមអង់អាចក្លាហានដែលបំពេញភារកិច្ចល្អក្នុងការលើកតម្កើងគោលជំហរនៃរបបថ្មី ។ ដោយសារមានកម្មាភិបាលខ្មែរក្រហមមួយចំនួនមិនទទួលបានការលើកទឹកចិត្ត នៅក្នុងសម័យមុនបដិវត្តន៍ ដោយសារតែខ្លួនជាជនក្រីក្រ ដូច្នេះកម្មាភិបាលទាំងនោះចង់ឲ្យសង្គមទទួលស្គាល់ និងមានការលើកទឹកចិត្តតាមការសន្យាមួយយ៉ាងច្បាស់លាស់តាមការឃោសនា និងមាគ៌ារបស់បក្ស ។ កែលបានធ្វើការកត់សម្គាល់ថា ការជជែកពីទំនាក់ទំនងអតីតកាលរបស់

គាត់ជាមួយនឹង «ប្រជាជន» ម្នាក់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែលបានប្រាប់ កែល អំពីឆន្ទៈរបស់ខ្លួនចំពោះអង្គការថា «អង្គការជាអ្នកដែលធ្វើល្អចំពោះគាត់ ប៉ុន្តែមិនមែនឪពុកម្តាយទេ ដូច្នេះគាត់គួរធ្វើអ្វីៗគ្រប់យ៉ាងសម្រាប់បដិវត្តន៍ដែរ ។ ប្រសិនបើអង្គការចង្អុលថានរណាម្នាក់ក្បត់ គាត់គួរតែមានសេចក្តីក្លាហានកម្ទេចអ្នកនោះចោលដោយគ្មានស្តាយស្រណោះ ទោះបីជនក្បត់នោះជាឪពុកម្តាយរបស់ខ្លួនក៏ដោយ» ។ ការស្មោះត្រង់ និងការព្យាយាមធ្វើការងារនឹងត្រូវបានមើលឃើញថា ម្នាក់នេះមានស្មារតីបដិវត្តន៍ខ្ពស់ ហើយនឹងទទួលបាននូវកិត្តិយស និងជានិមិត្តរូបនៅក្នុងបក្ស ។

អត្ថបទមួយនៅក្នុងទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍ ចុះខែឧសភា ឆ្នាំ១៩៧៧ មានចំណងជើងថា «តើភាពស្មោះត្រង់មានន័យដូចម្តេច»? អត្ថបទនោះបានដាក់គុណសម្បត្តិបួនយ៉ាងសម្រាប់ជ្រើសរើសអ្នកស្មោះត្រង់ ៖

១) អ្នកនោះត្រូវតែមានភាពស្មោះត្រង់គោរពរាល់គោលនយោបាយបក្ស ស្មារតីបក្ស និងមាគ៌ាចាត់តាំងគ្រប់ពេលវេលា ។

២) អ្នកនោះត្រូវតែអនុវត្តគ្រប់ចំណុចតាមគោលនយោបាយរបស់បក្សឲ្យបានត្រឹមត្រូវ ។

៣) អ្នកត្រូវតែព្យាយាមការពារមាគ៌ាបក្ស ដូច្នេះមាគ៌ារបស់បក្សគឺតែងតែត្រឹមត្រូវ និងបរិសុទ្ធ ។ ដូច្នេះ យុវជន និងយុវនារីរបស់បដិវត្តន៍មិនមែនត្រឹមតែព្យាយាមធ្វើការតាមមាគ៌ាបក្សឲ្យបានខ្ជាប់ខ្ជួននោះទេ ប៉ុន្តែ ក៏ត្រូវសង្កេត និងគោរពតាមមាគ៌ាណែនាំរបស់បក្សគ្រប់ទីកន្លែងដែរ ។

៤) អ្នកនោះត្រូវតែព្យាយាមបោសសម្អាតខ្មាំងដែលបង្កប់ខ្លួននៅក្នុងបក្ស និងបោសសម្អាតសមាសភាពក្បត់ឲ្យអស់ ដូច្នេះខ្មាំងទាំងនោះនឹងត្រូវកម្ចាត់ចេញអស់ជាស្ថាពរពីជួរបក្ស បដិវត្តន៍ និងយុវជនបដិវត្តន៍របស់យើង ។ ទីណាដែលមានខ្មាំងបង្កប់ខ្លួន ឬក៏មានសមាសភាពក្បត់នៅក្នុងជួរបក្ស ទីនោះចាំបាច់ត្រូវការយុវជន-យុវនារីបដិវត្តន៍របស់យើងចូលរួមបោសសម្អាតខ្មាំងលាក់ខ្លួនចេញពីជួរបក្ស បដិវត្តន៍យុវជន និងយុវនារី បដិវត្តន៍និងប្រជាជនយើង ។

## ខ្មែរក្រហមៈ ការអភិវឌ្ឍ

ដើម្បីជួយដល់ការជ្រើសរើសទ័ព និងកម្មាភិបាលសកម្មបក្សបានដាក់ចេញនូវវិធីសាស្ត្រមួយដើម្បីអនុវត្ត និងបណ្តុះស្មារតីនយោបាយដោយណែនាំឲ្យប្រជាជនទៅប្រជុំស្តាប់ការប្រកាសតាមវិទ្យុ រៀនសូត្រពីឯកសារខ្លីៗ ការនិយាយប្រាប់ (ការពិភាក្សាជាបុគ្គលរវាងមនុស្សពីរនាក់ ឬច្រើននាក់) និងសិក្សាយ៉ាងហ្មត់ចត់ទាំងឯកសារភូមិភាគ និងឯកសារតំបន់ ។ ការសិក្សាអាចមានរយៈពេលកន្លះថ្ងៃ មួយថ្ងៃ ឬ ពីរបីថ្ងៃ អាស្រ័យតាមស្ថានភាព និងបរិដ្ឋានជុំវិញ ។ ការជ្រើសរើសដោយផ្អែកលើលក្ខណៈសម្បត្តិនៃការជ្រើសជាបុគ្គលគឺជាផ្នែកសំខាន់បំផុតសម្រាប់ខ្មែរក្រហម ។ ការជ្រើសរើសបែបនេះ ភាគច្រើនធ្វើឡើងដោយផ្អែកតាមលក្ខណៈសម្បត្តិប្រាំយ៉ាងគឺ បទពិសោធន៍ការងារ ជីវប្រវត្តិ ការហ្វឹកហ្វឺន ស្ម័យទិតៀន និងការជួបជុំជាសាធារណៈ ។

## បទពិសោធន៍ពីការអនុវត្តការងារ

ការហ្វឹកហ្វឺនភាគច្រើនត្រូវបានធ្វើឡើងតាមការអនុវត្តផ្ទាល់លើការងារជាក់ស្តែង ។ ការផ្សព្វផ្សាយរបស់របបកម្ពុជាប្រជាធិបតេយ្យនៅខែមេសា ឆ្នាំ១៩៧៨ បានកំណត់រចនាសម្ព័ន្ធជាជួរការដែលសម្រេចដោយកម្មាភិបាលជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យស្តីពីការកសាងបក្ស ។ ទីមួយគឺជ្រើសរើសអ្នកដែលស័ក្តិសម ។ ទីពីរ គឺផ្តល់ការងារទទួលខុសត្រូវតូចនៅក្នុងសហករណ៍ ពីព្រោះជាវិធីសម្រាប់អ្នកដែលបានជ្រើសរើសដើម្បីអភិវឌ្ឍទាំងការងារ និងបទពិសោធន៍ដឹកនាំ ។ ការផ្តល់ការទទួលខុសត្រូវតូចៗនៅក្នុងសហគមន៍នេះបានដើរតួជាវិធីសាស្ត្រជ្រើសរើស ពីព្រោះរយៈពេលសាកល្បងនេះនឹងត្រូវបានតាមដានយ៉ាងហ្មត់ចត់ដូចជាការប្រឡង ប្រសិនបើប្រឡងធ្លាក់នឹងធ្វើឲ្យបេក្ខជនលែងមានសិទ្ធិក្លាយជាកម្មាភិបាលបក្សហើយ ។ ម៉ម បាននិយាយថា វិធីសាស្ត្រមួយដែលកម្មាភិបាលខ្មែរក្រហមនឹងដកប្រជាជនទន់ខ្សោយចេញ គឺខ្មែរក្រហមបានឲ្យក្រុមធំៗទាំងនោះបំលាស់ទីជុំវិញស្រែនិងព្រៃ ក្នុងគោលបំណងដើម្បីគ្រប់គ្រងឲ្យបានពេញ

លេញ ។ អ្នកទាំងនេះធ្វើដូច្នេះដើម្បីកម្ចាត់មនុស្សគ្មានបានការ ជាពិសេសអ្នកដែលខ្សោយនឹងការងារ ។ នេះគឺជាផ្នែកហ្វឹកហាត់សំខាន់ក្នុងការស្វែងរកបេក្ខជនកម្មាភិបាលដែលមានសក្តានុពល ។ ខ្មែរក្រហមបានចម្រាញ់បេក្ខជនដែលស័ក្តិសមជាកម្មាភិបាលរបស់អង្គការ ។ ការចម្រាញ់នេះគឺគ្មានអ្វីក្រៅពីគោលបំណងដើម្បីហ្វឹកហ្វឺននោះទេ ។ សម្រាប់អ្នកដែលខិតខំធ្វើការ កម្មាភិបាលខ្មែរក្រហមនឹងចំណាំទុកនិងណែនាំអ្នកដែលបានជ្រើសរើសពីរ-បីនាក់នោះទៅកម្មាភិបាលថ្នាក់កណ្តាលថា កម្មករ-កសិករមួយចំនួននោះគួរតែពិចារណាដើម្បីដំឡើងឋានៈនៅក្នុងជួរដឹកនាំបក្ស ។ ប្រជាជនថ្មីនិងក្រុមដែលត្រូវបានសង្ស័យត្រូវបានឲ្យឱកាសក្នុងការបង្ហាញថា ពួកគេមានតម្លៃសម្រាប់តំណែងនៅក្នុងរបបថ្មីនេះ ដោយ «ខិតខំធ្វើការងារពលកម្មជាមួយនឹងវណ្ណៈកម្មករ-កសិករ» ។ លោក ហ៊ីនតុន បានអះអាងថា «តម្លៃនៃការសិក្សាតាមរយៈការខិតខំប្រឹងប្រែងគឺត្រូវបានសរសើរតាមរយៈពាក្យស្លោកដែលមួយចំនួនយកលំនាំតាមការនិយាយស្តីរបស់ពួកម៉ៅ មានដូចជា «សាលាគឺជាកសិដ្ឋាន ។ ដីជាក្រដាស ។ នង្គ័លជាប៊ិច» ។ នៅក្រោមរបបខ្មែរក្រហម «ផ្ទៃមួយដែលម្នាក់ៗបំពេញតួនាទី ជាទូទៅរក្សាភាពស្ងៀមស្ងាត់ ពីព្រោះម្នាក់ៗកំពុងបង្ហាញសញ្ញានៃស្មារតីបដិវត្តន៍ដ៏ល្អមួយ ។ វិធីដ៏ល្អបំផុតមួយដើម្បីបង្ហាញថាមានអាកប្បកិរិយាត្រឹមត្រូវគឺត្រូវខិតខំបំពេញការងារដោយទឹកចិត្តសាទរអស់ពីចិត្ត និងមិនសាំញ៉ាំ» ។

## ការធ្វើជីវប្រវត្តិផ្ទាល់ខ្លួន

ដូចនឹងការប្រជុំស្វ័យទិតៀនដែរ ជីវប្រវត្តិផ្ទាល់ខ្លួនត្រូវបានធ្វើឡើងនៅក្នុងសហករណ៍របស់អ្នកដែលបានជ្រើសរើស ។ ជីវប្រវត្តិនេះត្រូវបានប្រើប្រាស់ដើម្បីជួយអ្នកដែលបានជ្រើសរើស និងកម្មាភិបាលក្នុងការកសាងស្មារតីបដិវត្តន៍ ឬនយោបាយបដិវត្តន៍ និងដើម្បីជួយកម្មាភិបាលឲ្យទទួលខុសត្រូវលើការពិនិត្យប្រវត្តិរូបទាំងនោះ ដើម្បីសន្និដ្ឋានអំពីឋានៈរបស់ម្ចាស់ប្រវត្តិរូបឲ្យបានច្រើនតាមតែអាចទៅបាន ។ សម្រាប់កម្មាភិបាលខ្លួនឯងផ្ទាល់ ការបំពេញជីវប្រវត្តិគឺមានដំណើរការធម្មតាដែលមានលក្ខណៈ «ផ្លូវការ និងសំខាន់ចំពោះការងាររបស់មនុស្សម្នាក់ៗ» ។ វាជាករណីចាំបាច់សម្រាប់អ្នកដែលចូលបក្សថ្មីត្រូវតែបំពេញឯកសារដែលមានប្រហែល១២ទំព័រ ឬក៏បំពេញសំណួរអំពីជីវប្រវត្តិ ។ សំណួរទាំងនេះត្រូវបានបែងចែកជាប្រាំពីរផ្នែកដែលទាមទារឲ្យបុគ្គលដែលចូលបក្សនោះនិយាយប្រាប់ព័ត៌មានអំពីប្តីប្រពន្ធ កូន ឪពុកម្តាយ បងប្អូន មិត្តភក្តិ និងបរិស្ថានសង្គម ។ សំណួរទាំងនោះបានទុកចន្លោះសម្រាប់ឲ្យបំពេញឈ្មោះ តួនាទី ឋានៈ និងប្រវត្តិចូលរួមបដិវត្តន៍របស់អ្នកដែលចង់ចូលបក្សដូចដែលបាននិយាយពីមុនរួចមកហើយ ។ សំណួរជាច្រើនគឺដើម្បីបញ្ជាក់ពីឋានៈរបស់បេក្ខជន ប្រវត្តិនៃការចូលរួមនិងស្មារតីរបស់បេក្ខជន ។ សំណួរទាំងនោះនឹងសួរបេក្ខជនពីអតីតភាពការងារដែលជារបៀបមួយដើម្បីកំណត់ពីឋានៈកាលពីមុន ។ សំណួរផ្សេងទៀតមានបំណងដើម្បីចង់ដឹងអំពីឋានៈបដិវត្តន៍របស់បេក្ខជនបច្ចុប្បន្ន ដោយសួរពីរយៈពេលបម្រើបដិវត្តន៍ សមាជិកភាពពីអតីតកាលនៅក្នុងអង្គការបដិវត្តន៍ផ្សេងទៀត ប្រវត្តិនៃការសិក្សា តួនាទី និងឋានៈ និងប្រវត្តិនៃសកម្មភាពបដិវត្តន៍ ។ ឧទាហរណ៍ កន្លែងណាដែលបានចូលបដិវត្តន៍? នៅពេលណា? តើនរណាជាអ្នកណែនាំឲ្យចូលបក្ស? នៅក្នុងការពិនិត្យខ្លួនឯង បេក្ខជនត្រូវឆ្លើយសំណួរអំពីអ្វីដែលពួកគេដឹងពីអាកប្បកិរិយារបស់របស់ខ្លួនដូចជា «តើអ្នកដឹងច្បាស់ពីអាកប្បកិរិយារបស់ខ្លួនឯងដោយរបៀបណា? ដឹងបានកម្រិតណា? តើដឹងពីភាពខ្លាំងនិងខ្សោយដោយរបៀបណា? តើអ្នកបានផ្លាស់ប្តូរឥរិយាបថដែលមិនមែនបដិវត្តន៍របស់អ្នក និងភាពខ្សោយដោយរបៀបណា? រាល់ចម្លើយទាំងអស់ត្រូវបានរៀបចំដើម្បីកត់ត្រាពីសកម្មភាពមុនបដិវត្តន៍ និង ភាពខ្លាំងរបស់បដិវត្តន៍ ភាពខ្សោយ និងបំណងចង់ផ្លាស់ប្តូរការរស់នៅដើម្បីឲ្យស្របជាមួយនឹងតម្លៃរបស់ខ្មែរក្រហម ។ កម្មាភិបាលនឹងព្យាយាមធ្វើតាមអ្នកដែលអនុវត្តបានល្អតាមខ្សែបន្ទាត់របស់បក្ស ដោយព្យាយាមបង្ហាញតាមរយៈ «កាយវិការ និងអាកប្បកិរិយា» ដែលបញ្ជាក់ពីស្មារតីបដិវត្តន៍ល្អមួយ ពីព្រោះការបង្ហាញជាសធារណៈនេះនិងការវាយតម្លៃចុងក្រោយរបស់បុគ្គលនឹងកំណត់ជីវិតសង្គមរបស់គេក៏ដូចជាការរស់នៅដែលកើតឡើងនៅក្នុងរបបថ្មី ។ ដើម្បីធានាអំពីការរស់នៅ និងការទទួលយកបានរបស់នរណាម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោក ហ៊ីនតុន បានបញ្ជាក់ថា «បេក្ខជនត្រូវតែធ្វើមានតុល្យភាពរវាង

ភាពខ្លាំងនិងភាពខ្សោយដោយប្រុងប្រយត្ន័នៅពេលបញ្ជាក់អំពីលទ្ធភាពនៃស្មារតីបដិវត្តន៍របស់នរណាម្នាក់» ។ ទាំងនេះគឺដូចនឹងការប្រជុំទិតៀនដែរ ការសរសេរជីវប្រវត្តិរបស់នរណាម្នាក់គឺជាការងារប្រកបដោយគ្រោះថ្នាក់ ដែលទាមទារឲ្យអ្នកចូលរួមធ្វើការបោកប្រាស់ដែលមិនអាចចាប់កំហុសបាននៅពេលផ្តល់ចម្លើយ ។

## ***កន្លែងប្រព្រឹត្តអំពើឃោរឃៅ***

ខ្មែរក្រហមបានធ្វើឲ្យអ្នកដែលត្រូវបានជ្រើសរើសថ្មីមើលឃើញពីអំពើរន្ធត់និងអំពើហិង្សាយ៉ាងធ្ងន់ធ្ងរ ។ រឹម សំ ជាជនភៀសខ្លួនដែលនៅរស់រានមានជីវិតបានរំឭកថា គាត់បានមើលឃើញការធ្វើទារុណកម្មទៅលើអ្នកទោសពីររូបដោយផ្ទាល់ភ្នែក ។ គាត់ត្រូវបានប្រាប់ឲ្យអង្គុយនៅចំពីមុខនិងសម្លឹងឲ្យចំមុខអ្នកទោសទាំងពីររូបនោះ ។ អង្គការបាននិយាយថា ៖ «ប្រសិនបើនរណាម្នាក់យំឬបង្ហាញការអាណិតអាសូរ ឬក្តីករុណាដល់មនុស្សនេះ អ្នកនោះនឹងទទួលរងទារុណកម្មដូចគ្នា» ។ អ្នកទោសម្នាក់ត្រូវបានស្នើឲ្យឆ្លើយសារភាពនូវបទឧក្រិដ្ឋរបស់ខ្លួន ។ អ្នកទោសនោះបដិសេធមិនព្រមឆ្លើយសារភាពនូវកំហុសរបស់ខ្លួនទេ ។ អ្នកទោសនោះស្រែកដាក់ខ្មែរក្រហមថា «អ្នកឯងសម្លាប់មនុស្សដោយគ្មានហេតុផល ។ នេះមិនយុត្តិធម៌សោះ» ។ យោធាម្នាក់ក្នុងចំណោមយោធាខ្មែរក្រហមជាច្រើនបានវាយគាត់ចំក្បាលពីក្រោយ ដែលបណ្តាលឲ្យគាត់ដួលផ្កាប់មុខទៅក្នុងភក់ ។ រឹម នៅចាំថា អង្គការបានពុះឆ្អឹងទ្រូងអ្នកទោសនោះរហូតដល់ពោះហើយយកសរីរាង្គខាងក្នុងចេញ ។ សំ ភ័យរន្ធត់ប្រៀបដូចជាគេវាយគាត់នឹងស្នូកកាំភ្លើងផងដែរ ។ យោធាដែលវះពោះបុរសជាអ្នកទោសនោះបានចងសរីរាង្គខាងក្នុងរបស់អ្នកទោសនោះជាមួយលួសបន្លា ហើយចងភ្ជាប់ចុងសងខាងនៃខ្សែលួសទៅនឹងដៃកង់របស់ខ្លួន រួចជិះកង់ចេញទៅដោយទុកចោលស្នាមប្រឡាក់ឈាមនៅនឹងកន្លែង ។ អង្គការបានប្រកាសតាមមីក្រូថា «កុមារា-កុមារីទាំងអស់បានឃើញដោយផ្ទាល់ភ្នែក ហើយប្រសិនបើនរណាម្នាក់មានអារម្មណ៍អាណិត ឬមេត្តាចំពោះសត្រូវដែលទើបតែស្លាប់ នោះនឹងទទួលទារុណកម្មដូចជាអ្នកទោសនេះអ៊ីចឹង» ។ រឹម មានអារម្មណ៍ថា រូបគាត់មិនគ្រាន់តែជាអ្នកទោសដែលជាប់តែផ្លូវកាយប៉ុណ្ណោះទេថែមទាំងផ្លូវចិត្តទៀតផង ។

ទាំង ប៉ុល ពត និង អៀង សារី ជឿជាក់យ៉ាងមុតមាំថា តាមរយៈការហ្វឹកហាត់យុវជនក្មេងៗឲ្យចេះលេងល្បែងដ៏ឃោរឃៅនេះ ចុងបញ្ចប់គេនឹងមិនអាចក្លាយជាទាហានដែលមិនមានក្តីមេត្តានិងស្រឡាញ់ជនរួមជាតិរបស់ខ្លួនឡើយ ប៉ុន្តែនឹងចូលចិត្តការកាប់សម្លាប់ ហើយចូលរួមក្នុងសង្គ្រាមដ៏សាហាវ ។ សម្តេចព្រះនរោត្តម សីហនុ បានធ្វើការកត់ចំណាំកាលពីពេលដែលព្រះអង្គបានចំណាយពេលនៅជាមួយខ្មែរក្រហម ខណៈពេលដែលព្រះអង្គជាប់ឃុំឃាំងនៅក្នុងព្រះរាជដំណាក់ក្រោមរបបខ្មែរក្រហមថា «ខ្ញុំបានឃើញអ្នកយាមនោះយាមដំណាក់របស់ខ្ញុំជាញឹកញាប់ធ្វើបាបសត្វដើម្បីជាការសប្បាយ ។ ខ្មែរក្រហមចូលចិត្តធ្វើបាបជនរងគ្រោះតាមដែលអាចធ្វើទៅបាន ។ ល្បែងធ្វើទារុណកម្មត្រូវបានកត់សម្គាល់ថាជាឧបករណ៍ហ្វឹកហ្វឺនមួយផ្នែកដ៏សំខាន់របស់កម្មាភិបាលដូចដែលគេជឿថា នៅពេលដែលយុវជនបានជ្រើសរើសសម្លាប់ឆ្កែ ឆ្មា និងសត្វនានាយ៉ាងសាហាវដោយប្រើដំបង និងជន្លួញ ធាតុពិតគេកំពុងពង្រឹងចិត្តនិងគំនិតរបស់ខ្លួន ដែលការសម្លាប់សត្វតូចៗគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ ហើយវាជាពេលវេលាដែលយុវជនបានជ្រើសរើសដើម្បីបញ្ជាក់ពីខ្លួនឯងដោយបង្ហាញពីភាពសាហាវនិងមិនគិតគូរដល់ភាពជាមនុស្ស ។

***(នៅមានត)***

**ហ្គ្រីហ្គោរី ប្រកណូ**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

# ការបញ្ចាំងសាលក្រម ឌុច នៅម៉ាឡៃ

## *សេចក្តីសង្ខេប*

គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបាន រៀបចំកិច្ចពិភាក្សាមួយស្តីពីការប្រកាសសាលក្រមលើកដំបូង បង្អស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នៅថ្ងៃទី១១ ខែកញ្ញា នៅឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមាន ជ័យ ដែលជាកន្លែងរស់នៅរបស់អតីតកម្មាភិបាលខ្មែរក្រហម ។

នៅថ្ងៃទី២៦ ខែកក្កដា សាលាក្តីខ្មែរក្រហមបានប្រកាស សាលក្រមរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចំពោះឧក្រិដ្ឋកម្មដែល បានប្រព្រឹត្តឡើងនៅមន្ទីរឃុំឃាំងស-២១ ដោយផ្តន្ទាទោស ឲ្យជាប់ពន្ធនាគារ៣៥ឆ្នាំ និងដកប្រាំឆ្នាំចំពោះការឃុំខ្លួនមិនស្រប ច្បាប់ ។ ដោយសារតែ ឌុច ធ្លាប់ត្រូវបានឃុំខ្លួនអស់រយៈពេល ១១ឆ្នាំទៅហើយ ដូច្នេះ ឌុច ត្រូវនៅជាប់ពន្ធនាគារតិចជាង ១៩ឆ្នាំ ។ ចាប់តាំងពីថ្ងៃប្រកាសសាលក្រម មជ្ឈមណ្ឌលឯកសារ កម្ពុជាបានចាក់បញ្ចាំងការផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើង វិញនៅក្នុងខេត្តចំនួនប្រាំបីនិងនៅភ្នំពេញដើម្បីសង្កេតនិងវាយ តម្លៃទៅលើប្រតិកម្មរបស់អ្នកចូលរួម ។

ទោះបីជា ឌុច គ្រប់គ្រងតែកន្លែងមួយក៏ដោយ ក៏ការជំនុំ ជម្រះ ឌុច បានជំរុញឲ្យមានបញ្ហាច្បាប់ នយោបាយ ប្រវត្តិសាស្ត្រ និងសីលធម៌ដែរ ។ កិច្ចពិភាក្សាក៏បានផ្តល់ឱកាសឲ្យប្រជាជនកម្ពុជា មានការពិភាក្សាអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិប តេយ្យដែលបណ្តាលឲ្យមានការស្លាប់ប្រជាជនជាងពីរលាននាក់ នៅក្នុងអំឡុងពេលតែបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃប៉ុណ្ណោះ ។ ការសារ ភាពកំហុសរបស់ ឌុច ទាក់ទងនឹងឧក្រិដ្ឋកម្មនិងការកាត់ទោសរបស់ តុលាការអាចផ្តល់អត្ថន័យជាច្រើនដល់ប្រជាជនសូម្បីតែអ្នកដែល មានជាប់ពាក់ព័ន្ធនឹងស-២១ ពីព្រោះការសារភាពអាចបង្ហាញ ពីការទទួលខុសត្រូវរបស់ប្រធានគុកផ្សេងទៀតដែលនៅរស់រាន មានជីវិតនិងមិនបានចេញមកទទួលខុសត្រូវ ។

ការបញ្ចាំងសាលក្រមគឺដើម្បីជំរុញឲ្យមានការពិភាក្សាអំពី អត្ថន័យនៃសាលក្រម ឌុច នៅក្នុងតំបន់ និងបង្កើនឲ្យមានការយល់ ដឹងអំពីករណី០០២នៅពេលខាងមុខនេះ ដែលជាករណីទីពីរ និង សំខាន់ជាងគេដែលត្រូវជំនុំជម្រះទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរ ក្រហមដូចជា នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ។ នេះជាការចាក់បញ្ចាំងសាលក្រមដំបូងគេដែលមានការចូលរួម របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលជំរុញឲ្យមានការពិភាក្សា និងការចូលរួមរបស់អ្នកភូមិ ។

## *ប្រវត្តិរបស់ស្រុកម៉ាឡៃ*



*ផ្លូវទៅកាន់ស្រុកម៉ាឡៃ*

ម៉ាឡៃគឺជាស្រុកមួយដែលអាចធ្វើដំណើរប្រាំនាទីពី ប្រទេសថៃ ប៉ុន្តែប្រហែលប្រាំបីម៉ោងពីភ្នំពេញ ។ យើងអាចធ្វើ ដំណើរទៅស្រុកនេះបានតែតាមផ្លូវរលាក់និងគ្រលុកដែលបណ្តាល មកពីរដូវភ្លៀង និងរថយន្តដែលដឹកមនុស្ស ទំនិញ និងផលិតផល កសិកម្មហួសចំណុះដូចជាសណ្តែកបាយទៅផ្សារនៅព្រំដែនថៃនិង ពីទីនោះមកវិញ ។ បើធ្វើដំណើរឆ្ពោះទៅភាគខាងត្បូងពីឃុំកូន ដំរីទៅ ដីដែលនៅជាប់ផ្លូវពោរពេញទៅដោយដីជាតិនិងមីនជា ច្រើន ហើយមានភូមិជាប់ៗគ្នាហូរហែរដឹកដែលជារបស់ខ្មែរ ក្រហមបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ ។

ប្រហែលជា៩៥ភាគរយនៃប្រជាជននៅឃុំម៉ាឡៃទាំង

៨៣៥០នាក់ គឺជាអតីតខ្មែរក្រហមមកពីខេត្តផ្សេងៗមករស់នៅតំបន់នេះនៅឆ្នាំ១៩៧៩ ។ មានអ្នកខ្លះបានរត់ទៅប្រទេសថៃ ដោយសារតែពាក្យចចាមអារ៉ាមរបស់ខ្មែរក្រហមថា វៀតណាមនឹងកាត់បំពង់កប្រសិនបើចាប់ខ្លួនបាន ។


សាលាឃុំបឹងបេង

ឡូរ៉ង់ ពិច ជនជាតិបារាំង និងជាប្រពន្ធរបស់ សួង ស៊ីគៀន ហៅ គង់ ដែលជាជំនួយការរបស់ អៀង សារី បានសរសេរពីការរត់គេចខ្លួនរបស់គាត់ពីភ្នំពេញទៅម៉ាឡៃនៅពេលនោះ ។ ឡូរ៉ង់ ពិច បានចំណាយពេលមួយខែធ្វើដំណើរទៅតំបន់ព្រៃនៅព្រំដែនហើយបង្កើតកូនប្រុសម្នាក់នៅក្នុងឃុំបឹងបេង ហើយប៉ុន្មានខែក្រោយមក កូននោះបានស្លាប់ដោយសារខ្វះអាហារនិងមានជំងឺ ។ កម្មាភិបាលជាច្រើនក៏មានជំងឺដូចគ្នាដែរ ។

តំបន់នេះជាតំបន់ប្រទាញប្រទង់គ្នាដ៏ខ្លាំងក្លាក្នុងអំឡុងទសវត្សរ៍៨០ និងដើមទសវត្សរ៍៩០ ដែលកាលនោះខ្មែរក្រហមបានប្រើប្រាស់ជួរភ្នំម៉ាឡៃដែលមានកម្ពស់ប្រហែល ៨០០ម៉ែត្រ ។ ប្រជាជនភាគច្រើនបានរត់ចេញពីតំបន់ដ៏តឹងតែងមួយនេះ ។ ពេលដែលមានកងទ័ពវៀតណាមវាយចូលតំបន់នេះកាលពីអំឡុងឆ្នាំ១៩៨៤ និង១៩៨៥ ហើយបណ្តាលឲ្យប្រជាជនរាប់ពាន់នាក់នៅម៉ាឡៃបាត់បង់ជីវិតក៏ដោយ ក៏តំបន់ម៉ាឡៃនេះត្រូវបានខ្មែរក្រហមដណ្តើមកាន់កាប់បានមកវិញក្នុងឆ្នាំ១៩៨៩ ក្រោយពេលកងទ័ពវៀតណាមត្រូវដកចេញពីប្រទេសកម្ពុជានៅឆ្នាំនោះ ។ ក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយខ្មែរក្រហម មេដឹកនាំខ្មែរក្រហមបានព្រមានប្រជាជនថា បើធ្វើដំណើរទៅតំបន់ដែលរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងច្បាស់ជាត្រូវទាហានរដ្ឋាភិបាលសម្លាប់ជាមិនខាន ។ ស្ត្រីម្នាក់ដែលបានចូលរួមវេទិកាពិភាក្សានៅវត្តរតនៈម៉ាឡៃឈ្មោះ ស៊ុាយ បូ បាននិយាយថា គាត់ត្រឡប់ទៅកាន់ស្រុកកំណើតរបស់គាត់នៅខេត្តតាកែវ ហើយរស់នៅទីនោះបានដប់មួយខែ ប៉ុន្តែគាត់បានត្រឡប់មកកាន់ម៉ាឡៃវិញដោយសារតែអ្នកជិតខាងរបស់គាត់នៅស្រុកកំណើតមិនបានស្វាគមន៍គាត់ទេ ដោយសារតែគាត់ធ្លាប់បម្រើខ្មែរក្រហម ។

នៅក្នុងឆ្នាំ១៩៩៦ អៀង សារី និងកម្មាភិបាលខ្មែរក្រហមផ្សេងៗទៀតបានចុះចូលជាមួយនឹងរដ្ឋាភិបាល ហើយតំបន់នេះក៏ត្រូវបានបង្កើតឡើងក្រោមក្រឹត្យច្បាប់ក្នុងរយៈពេលមួយឆ្នាំក្រោយមក គឺនៅថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ។ បន្ទាប់ពីចុះចូលរួច អៀង សារី បានបង្កើតគណបក្សនយោបាយមួយហៅថាចលនារួបរួមជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ រួមទាំងសមាជិកភាពមកពីម៉ាឡៃផងដែរ ។ រាល់មន្ត្រីថ្នាក់ខ្ពស់ទាំងអស់សុទ្ធសឹងតែជាអតីតខ្មែរក្រហម ។ អៀង សារី ចង់ធ្វើឲ្យគណបក្សរបស់ខ្លួនឃ្លាតឆ្ងាយពីក្រុមរបស់ ប៉ុល ពត ដោយធ្វើការអះអាងថាគណបក្សថ្មីនេះមិនមែនចង់ទាមទារអំណាចនោះទេ តែការបង្កើតនេះក្នុងគោលបំណងចាំបាច់មួយដើម្បីការផ្សះផ្សា ការបង្រួប


ទីប្រជុំជនឃុំម៉ាឡៃ

បង្រួម និងបញ្ឈប់ការវាយប្រហារគ្នា ។ នៅក្នុងឆ្នាំ២០០១ បន្ទាប់ពីច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានអនុម័ត អៀង សារី បានចេញសេចក្តីថ្លែងការណ៍មួយដោយសង្កត់ធ្ងន់ថា ចលនានេះប្រឆាំងរាល់សកម្មភាពទាំងឡាយណាដែលអាចនាំឲ្យកើតមាននូវអស្ថិរភាព ដែលប្រហែលជាចង់សំដៅទៅលើសាលាក្តីនេះ ។

ទោះបីជាអះអាងថាគណបក្សរបស់ខ្លួនមិនមានមនោគមន៍វិជ្ជាឬក៏ឧបករណ៍បក្សយ៉ាងណាក៏ដោយ ក៏បក្សនេះមានរួមបញ្ចូលគណៈអចិន្ត្រៃយ៍មួយដែលមានសមាជិកប្រាំពីរនាក់រួមទាំង អ៊ី ឈាន (ប្រធាន) សុខ ភាព (អនុប្រធាន) និង អៀង វុធ (សមាជិក) ផង ។ ម្យ៉ាងវិញទៀត កងពលធំទាំងប្រាំបីរបស់កងទ័ពខ្មែរក្រហមសុទ្ធតែមានអ្នកតំណាងបីរូបនៅក្នុង «គណៈអចិន្ត្រៃយ៍សម្រាប់សមរភូមិនីមួយៗ» ។ បន្ទាប់ពីបានបង្កើតគណៈកម្មាធិការទាំងនេះ ការដឹកនាំ «អាចបោះជំហានទៅមុខឆ្ពោះទៅលើកទឹកចិត្តដើម្បីពង្រឹងដំណើរការកិច្ចចរចាក្នុងគោលបំណងបញ្ឈប់ការបង្ហូរឈាមដ៏ខ្លាំងក្លា នៅក្នុងប្រទេសកម្ពុជាដើម្បីជាប្រយោជន៍ដល់ប្រជាជនទាំងអស់» ។ ចលនានេះនៅតែបន្តរហូតដល់ខែសីហា ឆ្នាំ២០០១ នៅពេលដែលសមាជិកជាង ៤០០ នាក់បានមកជួបជុំគ្នានៅម៉ាឡៃដើម្បីប្រារព្ធពិធីខួបលើកទីប្រាំនៃការបង្កើតចលនានេះ ។ នាពេលបច្ចុប្បន្ន ចលនានេះនៅតែមិនមានភាពច្បាស់លាស់នៅឡើយ ដោយសារតែពុំបានបញ្ឈប់សកម្មភាពរបស់ខ្លួនជាផ្លូវការ ។

លោក ទេព ឃុនណាល់ ដែលជាអតីតទីប្រឹក្សារបស់ ប៉ុល ពត ហើយដែលជាអ្នកតំណាងឲ្យខ្មែរក្រហមក្នុងអំឡុងដំណើរការសន្តិភាពដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិរវាងឆ្នាំ ១៩៩១-១៩៩៣ បានក្លាយជាអភិបាលស្រុកតាំងពីឆ្នាំ២០០៥ មកម្ល៉េះ ។ ឃុនណាល់ នៅតែជិតដិតជាមួយ ប៉ុល ពត រហូតដល់ខែមិថុនា ឆ្នាំ១៩៩៧ នៅពេលដែល ប៉ុល ពត បានបញ្ជាឲ្យសម្លាប់ សុន សេន រួមជាមួយនឹងសមាជិកគ្រួសារដប់នាក់ទៀតរបស់ សុន សេន ចំពោះអំពើក្បត់របស់គាត់ក្នុងការចរចាបញ្ឈប់ការប្រទូសរ៉ាយជាមួយលោកនាយករដ្ឋមន្ត្រីទីមួយព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ។ ទោះបីជាលោក ឃុនណាល់ បានរត់គេចខ្លួនចេញពីអ្នកប្រឆាំងនឹងកងកម្លាំងខ្មែរក្រហមទៅជាមួយនឹង ប៉ុល ពត ក្រោយពីការសម្លាប់ សុន សេន បានមួយរយៈក៏ដោយ ប្រហែលជាប៉ុន្មានសប្តាហ៍ក្រោយមក ឃុនណាល់ បានចូលរួមនៅក្នុងការកាត់ទោស ប៉ុល ពត ទាក់ទងនឹងរឿងក្តី របស់ សុន សេន ហើយគាត់បានគាំទ្រចំពោះការកាត់ទោសនេះដែលផ្តន្ទាទោស ប៉ុល ពត ឲ្យជាប់គុកអស់មួយជីវិត ។

នៅក្នុងឆ្នាំ១៩៩៨ ឃុនណាល់ បានក្លាយទៅជាជំនួយការម្នាក់របស់ ខៀវ សំផន និងជាអ្នកតំណាងឲ្យគណបក្សសាមគ្គីជាតិរបស់ខ្មែរក្រហមក្នុងការចរចាជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ នៅក្នុងឆ្នាំនោះ គាត់រួមជាមួយនឹងប្រពន្ធទីពីររបស់ ប៉ុល ពត ឈ្មោះ មា សុន បានចុះចូលជាមួយរដ្ឋាភិបាល ហើយក៏បានរៀបការជាមួយគ្នាភ្លាមបន្ទាប់ពីដឹងថា ប៉ុល ពត ស្លាប់នៅលើគ្រែ ។ គាត់ទាំងពីរនាក់បានផ្លាស់មកនៅម៉ាឡៃ ហើយបានក្លាយទៅជាអ្នកជិតខាងរបស់អ្នកនាំពាក្យឲ្យចលនាបង្រួបបង្រួមជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ លោក សួង ស៊ីគឿន ដែលជាស្វាមីដើមរបស់ ឡូរ៉េន ពិច ។ នៅក្នុងបទសម្ភាសន៍ឆ្នាំ២០០០ ទេព ឃុនណាល់ បាននិយាយថា «ហេតុអ្វីបានជាគេផ្តោតសំខាន់តែពីឆ្នាំ១៩៧៥ ដល់១៩៧៩? ចុះកាលពីទសវត្សរ៍៦០ ឬក៏កាលពីពេលដែលបារាំង ឬវៀតណាមគ្រប់គ្រងវិញនោះ ព្រោះមានប្រជាជនជាច្រើនត្រូវបានសម្លាប់កាលពីពេលនោះដែរ» ។ គាត់បានហៅ ខៀវ សំផន ថាជា «ជនគំរូ» របស់គាត់ចំពោះការដែល ខៀវ សំផន ខិតខំព្យាយាមធ្វើឲ្យមានយុត្តិធម៌សង្គមខណៈពេលដែលគាត់ធ្វើជាសមាជិករដ្ឋសភា ។


សួង ស៊ីគឿន

## វេទិកាពិភាក្សានៅម៉ាឡៃ

មានអ្នកចូលរួមប្រហែលជាង១២០នាក់ហើយបានទទួលនូវសៀវភៅសង្ខេបសាលក្រមរបស់ ឌុច សៀវភៅបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា «អំពើប្រល័យពូជសាសន៍ៈ សារសំខាន់នៃសំណុំរឿង០០២» ទស្សនាវដ្តីស្វែងរកការពិត និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប

គេយ្យ (១៩៧៥-១៩៧៩) នៅពេលដែលមកដល់កន្លែងប្រជុំភូមិ ។ លោកស្រីអភិបាលស្រុករង និន ភួក បានឡើងមានមតិបើកកម្មវិធីរួមជាមួយនឹងកិច្ចស្វាគមន៍ដល់អ្នកចូលរួមទាំងអស់ និង



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាពន្យល់អ្នកភូមិអំពីការបញ្ចាំងសាលក្រម ឌុច

លើកទឹកចិត្តម្នាក់ៗរួមទាំងមន្ត្រីផងដែរឲ្យធ្វើការចាប់អារម្មណ៍ចូលរួមក្នុងកិច្ចពិភាក្សានិងធ្វើការវិភាគឲ្យបានល្អិតល្អន់ទៅលើសាលក្រមនេះ ។ ភាគច្រើននៃអ្នកដែលចូលរួមទាំងនោះគឺជាស្ត្រី រួមទាំងអភិបាលស្រុករងផង និងសមាជិកទីប្រឹក្សាឃុំប៉ុន្មានរូបទៀតដែលបានអញ្ជើញមកពីឃុំទាំងបី (ដូចជា ម៉ាឡៃ បឹងបេង និងអូរស្រឡៅ) ។ លោកអភិបាលស្រុក ទេព យុនណាល់ មិនបានមកចូលរួមទេ ដោយសារតែលោកត្រូវបង្រៀនមុខវិជ្ជាសេដ្ឋកិច្ចនិងគ្រប់គ្រងនៅមហាវិទ្យាល័យមួយក្នុងខេត្តបាត់ដំបងជារៀងរាល់សប្តាហ៍ ។ ប៉ុន្តែ អភិបាលស្រុករងបាននិយាយថា លោកអភិបាលស្រុកចូលចិត្តចូលរួមក្នុងកម្មវិធីសង្គមនិងការប្រជុំផ្សេងៗដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល ឬរាជរដ្ឋាភិបាល ហើយប្រសិនបើគាត់មិនមានការមមាញឹកនឹងការងារផ្ទាល់ខ្លួនទេ គាត់ប្រាកដជាមកចូលរួមមិនខាន ។

ក្រុមការងារបានរៀបចំបញ្ចាំងកុនឯកសារពីររឿងដែលមានចំណងជើងថា «គុកទួលស្លែងឆ្នាំ១៩៧៩» និង «នៅកៀនជញ្ជាំងមន្ទីរស-២១» ។ កុនឯកសារទីមួយគឺមានផ្ទុកនូវវីដេអូយ៉ាងច្បាស់មួយដែលថតដោយជនជាតិវៀតណាម នៅពេលដែលបានរកឃើញមន្ទីរឃុំឃាំងនេះមុនដំបូង ចំណែកឯកុនឯកសារទីពីរវិញរួមមានកិច្ចសម្ភាសន៍ជាមួយអតីតអ្នកជាប់គុកទួលស្លែងពីរនាក់ និងអ្នកយាមគុកម្នាក់ ។ ម្យ៉ាងទៀត ក៏មានការបញ្ចាំងវីដេអូខ្លីអំពីការកាត់ទោស ឌុច ផងដែរ ។ បន្ទាប់ពីការបញ្ចាំងកុនឯកសាររួចមក ក្រុមការងារចាប់ផ្តើមកិច្ចពិភាក្សា ដែលផ្តោតសំខាន់ទៅលើសំណួរពីរដូចជា ៖

១) តើសាលក្រមឌុចមានន័យយ៉ាងដូចម្តេចចំពោះអ៊ំពូមីង?

២) តើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមគួរតែត្រូវបានយកមកកាត់ទោសនិងផ្តន្ទាទោសដែរឬយ៉ាងណា?

ហាវ សុភា ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណី០០១ ដែលមានឪពុកឈ្មោះ ចិន សៀ ហៅ ហាវ ហាន ស្លាប់នៅមន្ទីរ ស-២១ បានធ្វើដំណើរតាមរថយន្តតាក់ស៊ីពីផ្ទះរបស់គាត់នៅខេត្តកំពង់ធំដើម្បីមកចូលរួមនៅក្នុងវេទិកាពិភាក្សានេះផងដែរ ។ គាត់បានធ្វើការពន្យល់ដល់អ្នកដែលមកចូលរួមទាំងអស់អំពីរបៀបដែលគាត់បានចូលរួមនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ និងពីការចូលរួមដ៏មានអត្ថន័យក្នុងការស្វែងរកយុត្តិធម៌ជូនឪពុករបស់គាត់ដែលបានស្លាប់ដោយ «គ្មានទោសពៃរ៍» ។ តាមទស្សនៈរបស់គាត់ ការផ្តន្ទាទោស ឌុច បែបនេះគឺមានរយៈពេលខ្លីពេក ទោះបីជាសុភា ទទួលស្គាល់ពីការសហការរបស់ ឌុច ជាមួយតុលាការ និងការសារភាពទោសកំហុសរបស់គាត់យ៉ាងណាក៏ដោយ ។

បន្ទាប់មក ប្រធានគម្រោងឯកសាររស់ ស៊ិរិ សាវីណា បានសុំឲ្យអ្នកភូមិឡើងកាន់រូបថតរបស់មេដឹកនាំជាន់ខ្ពស់ទាំងបួនរូបដែលឥឡូវនៅជាប់ឃុំនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយឲ្យអ្នកភូមិដទៃទៀតមើលសៀវភៅដែលមានចំណងជើងថាអំពើប្រល័យពូជសាសន៍ ៖ សារសំខាន់នៃសំណុំរឿង ០០២ ។ អ្នកភូមិមួយចំនួនបាននិយាយថាពួកគាត់ស្គាល់ នួន ជា, ខៀវ សំផន និង អៀង សារី ថាជាអ្នកដឹកខាងរបស់គាត់ ។ អ៊ំស្រីប្រាំមួយនាក់បានឡើងមកចែករំលែកបទពិសោធន៍របស់គាត់កាលពីជំនាន់ខ្មែរក្រហមរួមទាំងទស្សនៈយល់ឃើញផ្ទាល់

របស់គាត់ទាក់ទិននឹងសាលក្រម ក៏ដូចជាសំណុំរឿង០០២ដែល ខិតជិតមកដល់នេះផងដែរ ។ អ្នកចូលរួមម្នាក់បានឡើងច្រៀង ចម្រៀងជ័យជម្នះរបស់ខ្មែរក្រហមមួយដែលមានចំណងជើងថា «១៧ មេសា មហាជោគជ័យ» ។ អ៊ីៗដែលបានបញ្ចេញមតិនៅ ពេលប្រជុំសុទ្ធតែត្រូវបានសម្ភាស បន្ទាប់ពីប្រជុំចប់ ដោយធ្វើការ ផ្តល់ព័ត៌មានបន្ថែមស្តីពីប្រវត្តិនិងទស្សនៈរបស់គាត់ចំពោះ សាលាក្តី ។

ជាដំបូង អ៊ំស្រី ស៊ុម អួន អាយុ៣៨ឆ្នាំ ដែលពីដើមរស់នៅ ភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ បានឡើង



អតីតយុទ្ធនារីខ្មែរក្រហមបង្ហាញរូបថតមេដឹកនាំខ្មែរក្រហមនៅក្នុងសៀវភៅសំណុំរឿង០០២

បញ្ចេញមតិមុនគេ ។ អ៊ំស្រីបាននិយាយប្រាប់អ្នកភូមិថា គាត់រស់ នៅក្បែរ នួន ជា នៅភ្នំឆ័ត្រក្នុងឆ្នាំ១៩៩២ ។ ប្តីរបស់អ៊ំស្រី គឺជាអ្នកចម្រៀងឲ្យខ្មែរក្រហមម្នាក់ក្នុងឆ្នាំ១៩៩១-១៩៩២ អំឡុងពេលដែលអ៊ុនតាក់កំពុងរៀបចំធ្វើការបោះឆ្នោតនៅស្រុក ថ្មពួក ។ អ៊ំស្រីបាននិយាយថា ៖

នៅពេលដែលនឹកឃើញរឿងកាលពីអតីតកាល យើង ម្នាក់ៗសុទ្ធតែមានអារម្មណ៍ពិបាកមិនស្រួលក្នុងចិត្ត សោះ ។ គ្មាននរណាម្នាក់អាចចៀសវាងពីការឈឺចាប់និង ការបាត់បង់សមាជិកគ្រួសារបានឡើយ ។ ទោះបីជាបងប្អូន បង្កើតរបស់ខ្ញុំមិនមាននរណាម្នាក់ស្លាប់ក៏ដោយ ក៏សាច់ ញាតិខាងឪពុករបស់ខ្ញុំបានស្លាប់កាលពីជំនាន់នោះដែរ ។

មុនដំបូង អ៊ំស្រីបាននិយាយថាគាត់យល់ស្របនឹងការ សម្រេចចិត្តធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុន្តែគ្មាន សិទ្ធិក្នុងការកាត់សេចក្តីអ្វីឡើយ ។ អ៊ំស្រីនិយាយថា «ខ្ញុំគ្រាន់តែជា អ្នកជិតខាងម្នាក់របស់ នួន ជា ប៉ុណ្ណោះ ។ ខ្ញុំមិនដឹងច្បាស់ថាគាត់ បានធ្វើអ្វីខ្លះចំពោះជនរងគ្រោះកាលពីរបបនេះនោះទេ» ។ នៅ ពេលដែលចោទសួរថាតើគួរតែកាត់ទោសមេដឹកនាំខ្មែរក្រហមទាំង បួនរូបនេះឬគួរតែកាត់ទោសទាំងជនដៃដល់ដែលប្រព្រឹត្តផ្ទាល់ដែរ ឬយ៉ាងណា អ៊ំស្រីឆ្លើយថា «ខ្ញុំគិតថា កាត់ទោសតែមេដឹកនាំធំៗ បានហើយ» ។ ចំពោះអ៊ំស្រី កម្មាភិបាលខ្មែរក្រហមថ្នាក់ទាបមិនគួរ យកមកកាត់ទោសទេ ដោយសារតែគាត់យល់ឃើញថាប្រសិន បើមិនមែនដោយសារមេដឹកនាំទាំងនោះ កម្មាភិបាលថ្នាក់ទាបក៏ មិនប្រព្រឹត្តបទល្មើសអ្វីដែរ ។ ម្យ៉ាងវិញទៀត អ៊ំស្រីជឿជាក់ថា ការកាត់ទោសជនដៃដល់ដែលប្រព្រឹត្តផ្ទាល់នោះអាចធ្វើឲ្យអ្នកភូមិ យល់ឃើញថាជាសកម្មភាពបង្ករឿង ហើយនាំឲ្យកើតមានអំពើ

ហ៊ានស្រាវជ្រាវថែមទៀត ។ បន្ទាប់ពីបានស្តាប់ពួកអ្នកភូមិដទៃទៀតបញ្ចេញយោបល់រួចមក អ៊ុំស្រី អួន បាននិយាយម្តងទៀត ហើយស្នើថា ការដាក់ទណ្ឌកម្មទៅលើមេដឹកនាំធំៗគួរតែត្រូវបានកាត់បន្ថយ ។ នៅពេលដែលសម្ភាសន៍ជាមួយគាត់ បន្ទាប់ពីចប់ប្រជុំរួចមក អ៊ុំស្រីបាននិយាយថា ៖

*ខ្ញុំគិតថា តុលាការនេះត្រឹមត្រូវហើយក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែ ក្នុងនាមខ្ញុំជាអ្នករស់នៅម៉ាឡៃនេះ ហើយក៏ជាអ្នកដើរតាមគាត់ម្នាក់ដែរ ខ្ញុំមិនចង់ឲ្យពួកគាត់ត្រូវបានកាត់ទោស ឬផ្តន្ទាទោសអ្វីឡើយ ។ គាត់ជាមេដឹកនាំរបស់យើងនិងជាអ្នកតំណាងឲ្យអ្នកភូមិយើងដែរ ។ ខ្ញុំមិនដែលបានមើលឃើញផ្ទាល់ភ្នែកនូវការសម្លាប់អ្វីនោះទេ ។ គាត់តែងតែជួយរកចំណីអាហារ និងជំនួយពីប្រទេសចិនមកឲ្យយើងទាំងអស់គ្នាជានិច្ច ។ គាត់ជួយរកសម្លៀកបំពាក់ និងអាហារឲ្យខ្ញុំឲ្យគ្រួសារខ្ញុំ ហើយឲ្យប្រជាជនទាំងអស់ដែលរស់នៅទីនេះផងដែរ ។ តាមគំនិតរបស់ខ្ញុំ ខ្ញុំមិនចង់ឲ្យតុលាការផ្តន្ទាទោស ឌុច ឲ្យ ជាប់គុកច្រើនឆ្នាំទេ ។ តុលាការគួរតែបន្ថយទោស ឌុច ដោយសារតែយើងមិនចង់សងសឹកនឹងគ្នាតទៅទៀត ។ ខ្ញុំគិតថា យើងសុទ្ធតែមានគំនិតដូចគ្នាទាំងអស់ទាក់ទងនឹងបញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែ យើងខ្លាចមិនហ៊ាននិយាយឲ្យអស់ពីចិត្តឡើយ ។*


អ្នកភូមិមើលការបញ្ចាំងសាលក្រម ឌុច

អ៊ុំស្រីបាននិយាយទៀតថា ការបញ្ចាំងកុនឯកសារនិងការពិភាក្សានេះពិតជាការក្រើនរំឭកមួយដ៏មានប្រសិទ្ធភាពសម្រាប់ក្មេងៗជំនាន់ក្រោយឲ្យចេះគិតឲ្យបានហ្មត់ចត់មុននឹងធ្វើអ្វីមួយ ដើម្បីកុំឲ្យជាន់ដានប្រវត្តិសាស្ត្រទៀត ។

អ៊ុំស្រី ពេន ប៉ាន់ បាននិយាយថា គាត់នៅចាំរូបលោក អៀង សារី ដោយសារតែគាត់រស់នៅតំបន់ម៉ាឡៃនេះតាំងពីឆ្នាំ ១៩៧៩មកម្ល៉េះពេលដែលគាត់ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញមក ។ «អៀង សារី គឺជាមនុស្សម្នាក់ដែលជួយនាំយកម្ហូបនិងរបស់របរផ្សេងៗដើម្បីមកជួយប្រជាជនតាមរយៈច្រកព្រំដែនម៉ាឡៃ» ។ អ៊ុំស្រីបាននិយាយទាំងទឹកភ្នែកថា គាត់ពិតជាគាំទ្រតុលាការនេះ ហើយទទួលយកការកាត់សេចក្តីរបស់តុលាការនេះទាំងអស់ ដោយសារតែសមាជិកគ្រួសារជាច្រើននាក់របស់គាត់បានស្លាប់កាលពីជំនាន់នោះ ។

អ៊ុំស្រីម្នាក់ទៀតស្គាល់ ខៀវ សំផន តាំងពីពេលដែល ខៀវ សំផន នៅជាមេដឹកនាំនៅម៉ាឡៃកាលពីឆ្នាំ១៩៧៩-១៩៨០ មកម្ល៉េះ ។ អ៊ុំស្រីនិយាយថា «ខ្ញុំមិនដឹងថា គាត់បានធ្វើអ្វីខ្លះទេកាលពីជំនាន់ខ្មែរក្រហម ប៉ុន្តែនៅពេលដែលខ្ញុំស្គាល់គាត់ ខ្ញុំគិតថាគាត់ជាមេដឹកនាំល្អម្នាក់» ។ ម្យ៉ាងវិញទៀត អ៊ុំស្រីយល់ស្របថាតុលាការគួរតែនាំយកមេដឹកនាំខ្មែរក្រហមទាំងអស់ទៅកាត់ទោស ។

អ៊ុំស្រី យ៉ី ស៊ីម អាយុ៥៣ឆ្នាំ ចាកចេញពីអន្លុងតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ មករស់នៅម៉ាឡៃ តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អ៊ុំស្រីធ្វើជាអ្នកជាំស្លនៅរោងចក្រអគ្គិសនីក្នុងទីក្រុងភ្នំពេញ ។ អ៊ុំស្រីម្នាក់នេះជាអ្នកទីមួយហើយដែលឡើងមកធ្វើការការពារជួសមេដឹកនាំខ្មែរក្រហមទាំងនេះ ។ ការបញ្ចេញមតិរបស់គាត់បានផ្លាស់ប្តូរបរិយាកាសនៃអង្គប្រជុំដោយសារមតិរបស់គាត់បានជះឥទ្ធិពលដល់អ្នកដទៃទៀតឲ្យគាំទ្រទស្សនៈរបស់គាត់ ក៏ដូចជាលើកទឹកចិត្តឲ្យអ្នកដទៃទៀតហ៊ាននិយាយជាសាធារណៈនូវយោបល់របស់ខ្លួន ។ អ៊ុំស្រីបាននិយាយទៀត

ថា «ខ្ញុំមិនដែលឃើញមេដឹកនាំទាំងបួននាក់នោះវាយដំ ចាប់ខ្លួន ឬក៏ធ្វើទារុណកម្មជនណាម្នាក់ឡើយ» ។ ឧក្រិដ្ឋកម្មតែមួយគត់ដែលគាត់មើលឃើញគឺចេញពីកុនឯកសារដែលបានបញ្ចាំងនៅពេលប្រជុំតែប៉ុណ្ណោះ ។ អ៊ំស្រីបានសង្កត់ធ្ងន់ថា អ្នកទាំងបួនរូបនេះជាមេដឹកនាំល្អនៅពេលដែលគាត់ធ្វើការជាមួយ ហើយអ្នកទាំងនោះក៏ចាស់ជរាណាស់ទៅហើយ ។ ដូច្នេះអ៊ំស្រីគិតថាតុលាការមិនគួរកាត់ទោសមេដឹកនាំទាំងនោះឲ្យជាប់ទោសយូរឆ្នាំពេកទេ ដោយសារតែពួកគាត់សុទ្ធតែជាខ្មែរដូចគ្នា ។



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ យី ស៊ីម

អ៊ំស្រី ស៊ីម បានបកស្រាយទស្សនៈរបស់គាត់ឲ្យកាន់តែក្បោះក្បាយថែមទៀតនៅក្នុងបទសម្ភាសន៍ដែលធ្វើឡើងដោយក្រុមការងាររបស់គម្រោងឯកសាររស់ ។ អ៊ំស្រីបាននិយាយថា ខណៈពេលដែលគាត់រស់នៅទីក្រុងភ្នំពេញកាលពីជំនាន់នោះ គាត់មិនដែលដឹងពីរឿងគុកទួលស្លែងឬមន្ទីរសន្តិសុខណាផ្សេងទៀតទេ ។ នៅរោងចក្រ គាត់សម្គាល់ឃើញថា យប់ខ្លះមានមនុស្សម្នាក់ទៅពីរនាក់បានបាត់ខ្លួន ប៉ុន្តែអ៊ំស្រីមិនដឹងថា អ្នកទាំងនោះត្រូវបានបញ្ជូនទៅទីណានោះទេ ហើយគាត់ក៏មិនហ៊ានទៅសួរនាំពីរឿងនេះដែរ ។ ការរស់នៅតាមព្រំដែននៅក្នុងឆ្នាំ១៩៧៩ តំបន់នេះព័ទ្ធទៅដោយព្រៃឈើ ហើយប្រជាជនមិនមានអ្វីហូបទេ សូម្បីតែអំបិល ។ គ្រួសារនីមួយៗមានតែអង្ករកន្លះកំប៉ុង ឬក៏បីស្លាបព្រាបាយប៉ុណ្ណោះសម្រាប់អាហារមួយពេលៗ ។ មានប្រជាជនជាច្រើនត្រូវស្លាប់ដោយសារការអត់អាហារ ។ ដោយសារតែភាពអត់ឃ្លានទើបធ្វើឲ្យអ្នកភូមិខ្លះលួចឆ្លងចូលទឹកដីថៃដើម្បីលួចយកម្ហូបអាហារ ។ អ្នកខ្លះត្រូវគេចាប់បាន ហើយវាយរហូតដល់ស្លាប់ ។ ដោយសារតែមើលឃើញនូវភាពអត់ឃ្លានបែបនេះ មេដឹកនាំខ្មែរក្រហមទាំងនេះបានស៊ុះស្វែងរកអាហារមកឲ្យប្រជាជនទទួលទានដោយសារអ្នកទាំងនេះបានធ្វើដំណើរទៅកាន់ប្រទេសថៃនិងចិនដើម្បីសុំជំនួយមកជួយប្រជាជន ។ មេដឹកនាំខ្មែរក្រហមបានជួយប្រជាជនឲ្យរួចពីសេចក្តីស្លាប់ ហើយបន្ទាប់ពីមេដឹកនាំទាំងនោះបានចុះចូលជាមួយរាជរដ្ឋាភិបាលមកក៏បានជួយប្រជាជនឲ្យជួបជុំគ្នាជាមួយក្រុមគ្រួសាររបស់ខ្លួនវិញ ។

អ៊ំស្រីបាននិយាយប្រាប់កូនៗរបស់គាត់អំពីរបបនោះជាពិសេសការលំបាករបស់គាត់កាលពីជំនាន់នោះដូចជា ៖ លើកដីលើកទំនប់ ហើយហូបតែបបររាវៗប៉ុណ្ណោះ ។ អ៊ំស្រីចង់ប្រាប់ទៅកូនៗឲ្យដឹងថា ប្រសិនជាប្រៀបធៀបឥឡូវនេះ គេមានជីវិតរស់នៅល្អជាងគាត់ ។ ដូច្នេះ គេត្រូវចេះឲ្យតម្លៃជីវិតរបស់ខ្លួនផង ។ កូនៗរបស់គាត់បានទៅទស្សនានៅគុកទួលស្លែង ហើយឥឡូវពេលដែលកូនរបស់គាត់ត្រឡប់មកផ្ទះវិញ អ៊ំស្រីព្យាយាម




កំណត់សម្គាល់ព្រំប្រទល់ថៃនៅជិតសាលាឃុំម៉ាឡៃ

ប្រដៅនិងណែនាំកូនៗ ហើយឲ្យនិយាយថា គាត់ពិតជាចិត្តអាក្រក់ខ្លាំងណាស់ដោយសារតែគាត់ជាខ្មែរក្រហម ។ អ៊ំស្រីមិនដឹងថាកូនគាត់គិតយ៉ាងម៉េចទេចំពោះរូបគាត់ដែរនោះទេ ។

ស៊ិម ជឿជាក់ថាតុលាការត្រូវបានបង្កើតឡើងក្នុងគោលបំណងកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយសារតែរបបនេះបានធ្វើឲ្យមនុស្សស្លាប់យ៉ាងច្រើនទូទាំងប្រទេស ។ អ៊ំស្រីបានទទួលស្គាល់ថារបបនេះគឺជារបបផ្តាច់ការ ។ ប៉ុន្តែ អ៊ំស្រីមិនដែលមើលឃើញមេដឹកនាំទាំងនេះប្រព្រឹត្តបទខុក្រិដ្ឋដោយផ្ទាល់ភ្នែកទេ ហើយគាត់ក៏មិនជឿថាមេដឹកនាំទាំងនេះ ឬក៏រដ្ឋាភិបាលនឹកចង់ដឹកនាំប្រទេសរបស់ខ្លួនទៅរកភាពវិនាសហិនហោច ឬក៏បណ្តាលឲ្យប្រជាជនខ្លួនឯងស្លាប់អ៊ីចឹងដែរ ។ អ៊ំស្រីខ្លាចក្រែងថាប្រហែលជាកូនចៅរបស់មេដឹកនាំទាំងនេះជាអ្នកប្រព្រឹត្តបទខុក្រិដ្ឋនោះហើយមើលទៅ ។ ទាក់ទិននឹង ឌុច វិញ ប្រសិនបើ ឌុច ពិតជាឃាតករដ៏សាហាវឃោរឃៅដែលមិនមានក្តីមេត្តាដល់ប្រជាជនខ្មែរពិតប្រាកដមែន នោះគឺជារឿងរបស់គាត់ ។ អ៊ំស្រីមិនដឹងថាតើ ឌុច ជាអ្នកទទួលខុសត្រូវចំពោះខុក្រិដ្ឋកម្មទាំងអស់នេះឬក៏យ៉ាងណានោះទេ ហើយគាត់ក៏មិនមានយោបល់អ្វីដែរចំពោះបញ្ហានេះ ។ អ៊ំស្រីមើលឃើញ ឌុច ថាជាមនុស្សគួរឲ្យអាណិតម្នាក់ដោយសារតែ ឌុច ជាមនុស្សចាស់ ហើយត្រូវទទួលរងការឈឺចាប់យ៉ាងច្រើនមុននឹងស្លាប់ទៀត ។ អ៊ំស្រីក៏អាណិតមេដឹកនាំធំៗប៉ុន្មានរូបនោះដែរ ហើយគាត់ក៏ជឿជាក់ថារដ្ឋាភិបាលនិងអង្គការសហប្រជាជាតិគួរតែកាត់ទោសឲ្យគាត់ជាប់ទោសតិចជាង ឌុច ទៅទៀត ដោយសារតែអ្នកទាំងនោះសុទ្ធតែមានវ័យចំណាស់ទៅហើយ ។ អ៊ំស្រីបានសង្កត់ធ្ងន់ថា គាត់មិនមែនកំពុងតែការពារមេដឹកនាំទាំងនេះទេ ប៉ុន្តែដោយសារតែគាត់រស់នៅជាមួយមេដឹកនាំទាំងនោះតាំងពីគាត់អាយុ១៩ឆ្នាំម៉្លេះ ហើយពុំដែលឃើញអ្នកទាំងនេះប្រព្រឹត្តបទខុក្រិដ្ឋអ្វីសោះឡើយ ។ ជាចុងក្រោយ អ៊ំស្រីបាននិយាយថា គាត់គិតថាការប្រជុំនេះពិតជាមានអត្ថប្រយោជន៍ដល់អ្នកភូមិមែនដោយសារតែអ្នកទាំងអស់នេះនឹងមានការយល់ដឹងកាន់តែប្រសើរឡើងទាក់ទងនឹងសាលាក្តីក៏ដូចជាដំណើរការនីតិវិធីរបស់តុលាការផងដែរ ។ មានអ្នកភូមិខ្លះបានតាមដានដំណើរការនីតិវិធីនៅក្នុងសារព័ត៌មានផ្សេងៗ ប៉ុន្តែមិនដែលទទួលបានឯកសារស្តីពីរបបខ្មែរក្រហមដែលនិយាយទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញទេ ។

បន្ទាប់ពី យ៉ី ស៊ិម និយាយចប់ មានអ៊ំស្រីម្នាក់ទៀតឡើងនិយាយថា ប្រជាជនមិនគួរសងសឹកនឹងមេដឹកនាំទាំងបួនរូប



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាពន្យល់អ្នកភូមិអំពីការបញ្ចាំងសាលក្រម ឌុច

ដែលជាប់ឃុំនោះទេ ។ ផ្ទុយទៅវិញ ប្រជាជនកម្ពុជាគួរតែសហការគ្នា កូនៗគួរតែស្តាប់តាមដំបូន្មានរបស់ឪពុកម្តាយ ហើយប្រជាជនគួរតែព្យាយាមរកស៊ីដើម្បីមានថវិកាគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។ ទោះបីជាខ្មែរក្រហមបានស្លាប់ទៅហើយក៏ដោយ ប៉ុន្តែក៏បានបន្សល់ទុកនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើនដូចជាប្រឡាយធារាសាស្ត្រជាដើម ។ អ៊ំស្រីចង់ឲ្យប្រជាជនគិតពិចារណាពីអំពើល្អរបស់អ្នកទាំងបួននាក់នោះ ហើយកាត់ទោសឲ្យជាប់ទោសរយៈពេលខ្លីបានហើយ ដោយសារតែមេដឹកនាំទាំងបួនសុទ្ធតែមានវ័យជរាណាស់ទៅហើយ ។

ដូចគ្នាដែរ ខឹម ខេង អាយុ៥២ឆ្នាំបានផ្តល់យោបល់ថា មេដឹកនាំខ្មែរក្រហមគួរតែត្រូវបានកាត់ទោសស្រាលៗបានហើយ ។ ទោះបីជាអ្នកទាំងនេះជាមេដឹកនាំខ្មែរក្រហមក៏ដោយ ប៉ុន្តែមានកម្មាភិបាលថ្នាក់ក្រោមជាច្រើននាក់ដែលជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែរ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សូម្បីតែអ្នកធ្វើការនៅក្នុងកងសន្តិសុខម្នាក់ក៏មានសិទ្ធិសម្លាប់មនុស្សដែរ ។ អ៊ំស្រីបានសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាព្យាយាមយល់ពីសភាពការណ៍ជាក់ស្តែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បើទោះជាមានប្រជាជននៅក្នុងតំបន់មួយចំនួនទទួលរងទុក្ខវេទនាខ្លាំងយ៉ាងណាក្តី ក៏នៅមានតំបន់ខ្លះដែលប្រជាជនរស់នៅប្រកបដោយសេចក្តីសុខផងដែរ ។ ឈាមមិនបានគ្របដណ្តប់ទូទាំងប្រទេសទេ ។

ខេង និយាយថា អៀង សារី និងគ្រួសារគាត់បានការពារគាត់ ហើយមិនឲ្យគ្រួសារគាត់ត្រូវបានចាប់ដាក់គុកទេបន្ទាប់ពីឆ្នាំ១៩៧៩ ហើយបានជួយឲ្យគាត់រស់នៅដោយសន្តិភាពទៀតផង ។ នៅក្នុងភូមិភាគបូព៌ា ទោះបីជាក្មេងៗត្រូវបានគេយកទៅសម្លាប់ក៏ដោយ ក៏ អៀង សារី មិនបានយកនរណាមួយទៅសម្លាប់ដែរ ។ អ៊ំស្រីនិយាយថា «តុលាការមិនគួរត្រឹមតែស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាប៉ុណ្ណោះទេ ថែមទាំងត្រូវស្វែងរកការពិតពីមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ទាំងនោះទៀតផង» ។ គាត់បានបញ្ជាក់ថា តុលាការបង្កើតឡើងមិនត្រឹមតែរកយុត្តិធម៌ជូនជនរងគ្រោះប៉ុណ្ណោះទេ តែថែមទាំងជូនអតីតខ្មែរក្រហមផងដែរ ។ គាត់មិនបន្ទោសរដ្ឋាភិបាលដែលនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសនោះទេ ប៉ុន្តែនៅពេលដែលគ្មានអាហារហូបសហករណ៍របស់ អៀង សារី បានផ្តល់អាហារដល់ប្រជាជនហូបគ្រប់គ្រាន់ ។ ប្រសិនបើតុលាការដំណើរការក្នុងលក្ខណៈសងសឹក នោះវដ្តនៃការសងសឹកនឹងមិនមានថ្ងៃបញ្ចប់ទេ បើទោះបីជាជាតិក្រោយក៏ដោយ ។

ខេង បានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៥ ប្រជាជនត្រូវបានគេបង្ខំឲ្យចាកចេញពីទីក្រុង ប៉ុន្តែនៅពេលដែលវៀតណាមចូលមក គាត់ក៏ត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញដែរ ហើយខ្មែរក្រហមជាច្រើននាក់ត្រូវបានវៀតណាមបាញ់សម្លាប់ ។ គាត់និយាយថា ៈ

*មនុស្សភាគច្រើនចាត់ទុកថ្ងៃ៧ មករា ថាជាថ្ងៃជោគជ័យ និងជាកំណើតទីពីររបស់ខ្លួន ។ ក៏ប៉ុន្តែ នេះមិនពិតទេសម្រាប់ខ្មែរក្រហម ។ ប្រជាជនខ្មែរចាកចេញពីក្រុងភ្នំពេញទៅព្រំដែនដើម្បីព្យាយាមស្វែងរកជីវិតសុខសាន្តមួយ ប៉ុន្តែអ្នកទាំងនេះត្រូវរងទុក្ខវេទនាដោយសារការអត់ឃ្លាន ជំងឺ និងការប្រយុទ្ធគ្នា ។ ខ្លួនខ្ញុំផ្ទាល់ធ្លាប់ឆ្លងកាត់បទពិសោធន៍បែបនេះហើយ ។ នៅពេលនោះ ខ្ញុំមានអាយុ១៨ឆ្នាំ ។ ចេញពីទីក្រុងភ្នំពេញ ខ្ញុំរត់ពីកន្លែងមួយទៅកន្លែងមួយទៀត ។ ដោយសារតែការស្រេកឃ្លាន ខ្ញុំបានសុំបាយពីសហករណ៍មូលដ្ឋាន ។ កាលនោះ យើងមានគ្នាមួយពាន់នាក់ ។ ប៉ុន្តែ វៀតណាមមិនត្រឹមតែមិនជួយយើងនោះទេ ថែមទាំងដាក់អន្ទាក់ ហើយសម្លាប់យើងទៀតផង ។ ប្រសិនបើគ្នារបស់យើងមិនចេញទៅស៊ើបទីតាំងមុនទេ នោះយើងប្រហែលជាត្រូវបានគេសម្លាប់បាត់ទៅហើយ ។ ខ្ញុំគិតថាការធ្វើបែបនេះ គឺជាការសងសឹកគ្នា ។*

ខេង សុំឲ្យតុលាការពិចារណាឡើងវិញពីចំនួនមនុស្សដែលត្រូវនាំយកមកកាត់ទោស ដោយនិយាយថា «ខ្ញុំគិតថាមនុស្សបួនឬប្រាំនាក់នេះគ្រប់គ្រាន់ឬច្រើនពេកហើយសម្រាប់ការកាត់ទោសនោះ ។ ខ្ញុំផ្ទាល់គិតថា គួរតែតិចជាងនេះ ហើយមិនគួរឲ្យលើសពីប្រាំនាក់នោះទេ ។ ជាចុងក្រោយ ខ្ញុំស្នើសុំឲ្យតុលាការសម្រាលទោសដើម្បីឲ្យយើងទាំងអស់គ្នាបានរស់នៅជុំគ្នាដោយសុខដុមរមនា» ។

មតិចុងក្រោយបន្ទាប់ពីការប្រជុំ លោកស្រីអភិបាលស្រុករង

និន ភួក បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានអញ្ជើញមក ហើយលោកស្រីមានប្រសាសន៍ថា សហគមន៍នេះគាំទ្រការកាត់សេចក្តីករណី០០២ និងការកាត់ទោស ឌុច ក៏ដូចជាស្វែងយល់ពីសាលក្រមនេះផងដែរ ។ លោក ទឹម សុខ មេឃុំម៉ាឡៃមានប្រសាសន៍ថា គាត់រីករាយដែលបានស្តាប់កិច្ចពិភាក្សាពីរឿងអតីតកាលពីព្រោះថា បើទោះជាសង្គ្រាមបានបំផ្លិចបំផ្លាញសង្គម យើងយ៉ាងណាក្តី ក៏កិច្ចពិភាក្សាថ្ងៃនេះជារឿងល្អមួយសម្រាប់ប្រជាជនធ្វើការបញ្ចេញគំនិតនិងបទពិសោធន៍របស់ខ្លួនដែរ ។ គាត់បានមានប្រសាសន៍ថា រយៈពេលជាង៤០ឆ្នាំមកនេះ គាត់រងទុក្ខវេទនាច្រើនណាស់ ។ លោកនិយាយថា “ខ្ញុំបាញ់គេ ហើយគេបាញ់ខ្ញុំវិញ ប៉ុន្តែឥឡូវនេះយើងរស់នៅក្នុងសន្តិភាពហើយ” ។ បើទោះជាគាត់មិនមានទំនាក់ទំនងជាមួយនឹងសាលាក្តីខ្មែរក្រហមក៏ដោយ តែ «យើងរស់នៅក្រោមច្បាប់ទាំងអស់គ្នា» ។


ប្រធានឃុំ ទឹម សុខ

## យោបល់បន្ថែម

នៅក្នុងបទសម្ភាសន៍បន្ទាប់ពីកិច្ចពិភាក្សា អ៊ំស្រី ស៊ិន សុផលរិទ្ធ អាយុ៥០ឆ្នាំ បានមានប្រសាសន៍ថា មុនឆ្នាំ១៩៧៥ ឪពុករបស់គាត់ជាគ្រូពេទ្យ ហើយគ្រួសាររបស់គាត់បានផ្លាស់ពីក្រុងភ្នំពេញមករស់នៅប៉ៃលិន ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ គ្រួសារគាត់ត្រូវបានជម្លៀសឲ្យទៅរស់នៅសាលាក្រៅ ។ បន្ទាប់មក គ្រួសាររបស់គាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងចល័តអម្ពិលប្រាំដើម ។ គាត់ត្រូវបានបញ្ជូនទៅធ្វើការនៅក្នុងរោងចក្រវាយនភណ្ឌនៅដំណាក់សាលារហូតដល់ឆ្នាំ១៩៧៩ ពេលដែលគាត់និងអ្នកធ្វើការដទៃទៀតបានរត់គេចពីកងទ័ពវៀតណាមទៅម៉ាឡៃ ។ នៅក្នុងឆ្នាំ១៩៨០ គាត់បានរៀបការជាមួយ ហ៊ូ ចូន ដែលជាអ្នកចម្រៀងខ្មែរក្រហមចាប់ពីឆ្នាំ១៩៨៥រហូតដល់ចុងទសវត្សរ៍៩០ ពេលដែលគាត់ចុះចូលជាមួយនឹងរដ្ឋាភិបាល ។ ប្តីរបស់គាត់ថតចម្រៀងហើយបញ្ជូនទៅឲ្យមេដឹកនាំខ្មែរក្រហមដែលរស់នៅកោះកុង ។ មេដឹកនាំទាំងនោះពិនិត្យចម្រៀងនេះឡើងវិញដើម្បីឲ្យត្រូវតាមគោលការណ៍បដិវត្តន៍ខ្មែរក្រហម ហើយបន្ទាប់មកទើបចាក់ផ្សាយតាមវិទ្យុ ។ គាត់បាននិយាយប្រាប់កូនៗពីរឿងរ៉ាវរបស់គាត់ តែកូនៗមិនជឿទេ ។

គាត់គិតថាតុលាការនិងអង្គការសហប្រជាជាតិគួរតែសម្រាលទោសដល់មេដឹកនាំខ្មែរក្រហម ពីព្រោះថាគាត់មិនដែលឃើញមេដឹកនាំទាំងនោះធ្វើអំពើអាក្រក់ដាក់ប្រជាជនខ្លួនឯងទេ ។ ជាធម្មតា មេដឹកនាំខ្មែរក្រហមរស់នៅក្នុងប្រទេសថៃ ហើយចូលមកក្នុងប្រទេសកម្ពុជាដើម្បីចូលរួមក្នុងកិច្ចប្រជុំធំៗតែប៉ុណ្ណោះ ។ នៅពេលដែលគាត់រស់នៅជាមួយមេដឹកនាំខ្មែរក្រហមទាំងនេះ គាត់មិនដែលឃើញអ្នកទាំងនេះប្រព្រឹត្តអំពើអាក្រក់អ្វីទេ ហើយមិនដែលឃើញអ្នកទាំងនេះសម្លាប់មនុស្សផងដែរ ។ គាត់ចង់ឲ្យតុលាការបន្ធូរទោសឲ្យ ឌុច ផង ពីព្រោះគាត់មិនច្បាស់ថាតើ ឌុច ជាអ្នកចេញបញ្ជាឲ្យគេសម្លាប់មនុស្សឬគ្រាន់តែជាអ្នកធ្វើតាមបញ្ជារបស់គេឬយ៉ាងណា ។ តែទោះជាយ៉ាងណា គាត់ចង់ឲ្យការកាត់ទោសរបស់ ឌុច មានលក្ខណៈធូរស្រាលជាងនេះបន្តិច ។

អ៊ំប្រុស ដួង ឈុន អាយុ៥០ឆ្នាំ កើតនៅភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ គាត់មានប្រសាសន៍ថា គាត់មិនបានរៀនសូត្រជ្រៅជ្រះទេ ពីព្រោះថាគាត់ឈប់រៀននៅថ្នាក់ទី១២ (ដែលស្មើនឹងថ្នាក់ទី១ឥឡូវ) នៅពេលដែលខ្មែរក្រហមចាប់ផ្តើមប្រមូលក្មេងៗឲ្យ

ចូលធ្វើយោធា ។ គាត់ឈរជើងនៅក្នុងកងពលទី១ ក្រោមបញ្ជារបស់ តាម៉ុក ។ នៅពេលដែលកងទ័ពវៀតណាមឈ្លានពាន គាត់រត់ទៅនៅតាមព្រំដែនថៃ ក៏ប៉ុន្តែខាងថៃមិនអនុញ្ញាតឲ្យស្នាក់នៅទីនោះទេ ។ មនុស្សជាច្រើនត្រូវស្លាប់ដោយសារការអត់ឃ្លាននិងការប្រយុទ្ធគ្នា ។ គាត់គិតថា ការសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហមកើតឡើងដោយសារតែការស្អប់ខ្ពើមគ្នា ។ នៅពេលដែលនរណាម្នាក់ត្រូវបានដំឡើងតំណែងខ្ពស់ម្នាក់នោះនឹងចាប់ផ្តើមធ្វើបាបអ្នកដែលនៅក្រោមខ្លួន ។ គាត់ពិបាកក្នុងការបង្ហាញពីទស្សនៈរបស់គាត់ទាក់ទងទៅនឹងសាលាក្តីខ្មែរក្រហមណាស់ ហើយមានប្រសាសន៍ថាគាត់មិនមានយោបល់អ្វីទេ ។

អ៊ំប្រុស ទុយ ល័ស អាយុ៥៨ឆ្នាំ កើតនៅក្នុងភូមិត្បែង ខេត្តកំពង់ធំ ។ គាត់ជាយោធាខ្មែរក្រហមម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានផ្លាស់ទៅរស់នៅម៉ាឡៃឆ្នាំ១៩៧៩ ។ គាត់មិនជំទាស់ទៅនឹងសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ហើយគាត់យល់ឃើញថាមេដឹកនាំខ្មែរក្រហមនឹងទទួលទោសរយៈពេលវែងឬខ្លីអាស្រ័យទៅលើពិរុទ្ធភាពរបស់អ្នកទាំងនោះ ។ គាត់ខ្លួនឯងផ្ទាល់គិតថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានសារសំខាន់ណាស់សម្រាប់ក្មេងៗជំនាន់ក្រោយពីព្រោះថាការកាត់ទោសនេះគឺជាគំរូសម្រាប់អ្នកទាំងនោះចេះគិតមុននឹងធ្វើអ្វីមួយ ។

អ៊ំប្រុស អ៊ុល វ៉ុន អាយុ៦០ឆ្នាំ កើតនៅខេត្តកំពង់ធំ ហើយផ្លាស់មកនៅម៉ាឡៃនៅឆ្នាំ១៩៨១ ។ គាត់ចូលបម្រើខ្មែរក្រហមនៅឆ្នាំ១៩៧២ ហើយបានបម្រើការនៅក្នុងអង្គភាពភស្តុភាររហូតដល់ កុយ ធួន ដែលជាមេបញ្ជាការយោធានៅភូមិភាគឧត្តរត្រូវបានចាប់ខ្លួននិងចោទថាជាខ្មាំង ។ បន្ទាប់មកទៀត មនុស្សជាច្រើនដែលធ្វើការនៅក្នុងកងរបស់គាត់ក៏ត្រូវបានចាប់ខ្លួន ។ វ៉ុន មានអារម្មណ៍សោប់សល់ ដេកមិនលក់ ហើយឆ្ងល់ថាមកពីមូលហេតុអ្វី ។ នៅពេលដែលកងទ័ពវៀតណាមកាន់កាប់ទីក្រុងភ្នំពេញ គាត់ព្យាយាមរត់ចេញពីខ្មែរក្រហម តែចុងក្រោយគាត់ធ្លាក់ខ្លួនបម្រើការនៅក្នុងអង្គភាពយោធានៅក្រុងប៉ៃលិន ហើយបន្ទាប់មកទៀតនៅម៉ាឡៃក្នុងអំឡុងទសវត្សរ៍៩០ ។

វ៉ុន តាមដានសវនាការរបស់ ឌុច តាមរយៈទូរទស្សន៍ ។ គាត់គិតថា របបខ្មែរក្រហមនឹងមិនអាចដួលរលំទេ ប្រសិនបើមិនមានសត្រូវស៊ីរូងផ្ទៃក្នុង ។ គាត់ខ្លួនឯងផ្ទាល់បានឃើញអំពើសាហាវយង់ឃ្នងនៅក្នុងខេត្តសៀមរាបដែលដូចទៅនឹងអ្វីដែលលើកឡើងនៅក្នុងអំឡុងពេលសវនាការ ហើយជឿជាក់ថាអំពើទាំងអស់នោះប្រព្រឹត្តឡើងដោយកម្មាភិបាលថ្នាក់ក្រោម ។ វ៉ុន និយាយថា ប្រជាជននៅតាមខេត្តហូបតែបបរ ដែលផ្ទុយពីគោលនយោបាយរបស់ ប៉ុល ពត ដែលថាផ្តល់អាហារឲ្យប្រជាជនបីពេលក្នុងមួយថ្ងៃ ។ បើទោះជាធ្វើការឲ្យខ្មែរក្រហមក៏ដោយ គាត់ខ្លួនឯងផ្ទាល់ក៏ធ្លាប់ឆ្លងកាត់ការស្រេកឃ្លាននេះដែរ ។ គ្មានអ្នកណាម្នាក់ហ៊ានប្រឆាំងនឹងគោលនយោបាយនេះទេ ។ ម្នាក់ៗបិទមាត់ជិតមិននិយាយអ្វីទាំងអស់ ពីព្រោះមិនមានសេរីភាពក្នុងការនិយាយស្តីឡើយ ។ នៅតាមតំបន់ខ្លះ កម្មាភិបាលថ្នាក់ក្រោមរាយការណ៍ជាបន្តបន្ទាប់ថា កងរបស់គាត់មានស្រូវគ្រប់គ្រាន់សម្រាប់ហូបចុកហើយ ទោះបីជាជាក់ស្តែងនេះមិនពិតយ៉ាងណាក៏ដោយ ។ គាត់គិតថាអ្នកទាំងនេះកុហក



ចម្ការមីនបោសសម្អាតរួចនៅស្រុកម៉ាឡៃ

ដើម្បីចង់ឡើងតំណែងតែប៉ុណ្ណោះ ។ បន្ទាប់ពីគាត់ត្រឡប់មកពីសៀមរាបវិញ គាត់បានរាយការណ៍អំពីភាពសាហាវយង់ឃ្នងដែលគាត់បានមើលឃើញដាក់ក្នុងសំបុត្រយកទៅឲ្យ នួន ជា ដែលទីបញ្ជាការធំរបស់គាត់នៅជិតពហុកីឡដ្ឋានភ្នំពេញ ។ រ៉ុន បានជិះកង់យកទៅដល់ទីនោះដើម្បីផ្ញើសំបុត្រតាមរយៈអ្នកយាមទៅឲ្យនួន ជា ។ នៅពេលដែលគាត់ដឹងថា កង ចាប ជាលេខាភូមិភាគឧត្តរត្រូវបានចាប់ខ្លួន គាត់បែរជាមានអារម្មណ៍ធូរស្បើយទៅវិញ ។

គាត់ជឿថាចំណុចខ្សោយរបស់របប ប៉ុល ពត គឺដោយសារតែរបបនេះមិនមានក្រុមឃ្លាំមើលនៅតាមខេត្តឲ្យបានច្បាស់លាស់ ។ «បើទោះបីជាយើងជាមនុស្សឆ្លាតយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខ្សោយដែរ ។ ឧទាហរណ៍ដូចជា ប៉ុល ពត ចំណុចខ្សោយរបស់គាត់គឺថាគាត់អានតែរបាយការណ៍ដែលលេខាភូមិភាគឧត្តរផ្តល់ឲ្យ ក៏ប៉ុន្តែគាត់មិនដែលចុះទៅមើលសភាពការណ៍នៅតាមខេត្តដោយផ្ទាល់ទេ ។

អ៊ំស្រី អ៊ិន ថាន កើតនៅខេត្តសៀមរាប ។ គាត់ជម្រះស្មៅ កាប់ពោតនិងបេះសណ្តែកឲ្យម្ចាស់ចម្ការពីព្រោះថាគាត់មិនមានដីស្រែទេ ។ គាត់ត្រូវបានគេផ្តល់ដីឲ្យប្រហែលជាពីរ-បីហិកតា នៅពេលធ្វើសមាហរណកម្មនៅក្នុងឆ្នាំ១៩៩៧ ។ ប៉ុន្តែក្រោយមកគាត់លក់ដីនោះទៅវិញ ដោយសារខ្លាចមានមីន ។ ថាន ចូលបម្រើខ្មែរក្រហមនៅឆ្នាំ១៩៧៣ ដោយការបង្ខំនិងការគំរាមកំហែង ។ គាត់ដឹងថា មេដឹកនាំខ្មែរក្រហមដឹកនាំប្រទេសដោយផ្អែកលើទ្រឹស្តីកុម្មុយនីស្ត តែគាត់មិនដឹងថាតើកុម្មុយនីស្តមានន័យថាម៉េចទេ ។ គាត់មិនហ៊ានសួរគេ ពីព្រោះគាត់ខ្លាចនិយាយខុស ហើយត្រូវចាប់យកទៅបាត់ ។ ថាន រត់គេចពីកងទ័ពវៀតណាមដោយសារតែមានពាក្យចចាមអារ៉ាមថា វៀតណាមនឹងអា-កអ្នកភូមិ ។ នៅម៉ាឡៃ ថាន ត្រូវបានចាប់ឲ្យចូលធ្វើទាហាន ហើយត្រូវចាត់ឲ្យទៅដឹកជញ្ជូនស្បៀងឲ្យទាហាន ។ គាត់ចង់ត្រឡប់មកផ្ទះវិញ ប៉ុន្តែគាត់ខ្លាច ហើយ «មិនបានគិតឲ្យជិតដល់» ទេ ។ ក្នុងអំឡុងពេលដែលខ្មែរក្រហមធ្វើសមាហរណកម្ម គាត់ចង់រត់ទៅចូលជាមួយខាងរដ្ឋាភិបាលដែរ ពីព្រោះគាត់ត្រូវបានបំបែកពីបងប្អូនបង្កើតរបស់គាត់អស់រយៈពេលជាយូរណាស់មកហើយ ។


ការដឹកជញ្ជូនតាមត្រាក់ទ័រនៅស្រុកម៉ាឡៃ

គាត់គិតថា ការដាក់ទោស ឌុច ឲ្យជាប់គុក១៩ឆ្នាំនេះ គឺសមរម្យហើយពីព្រោះគាត់បានប្រព្រឹត្តខុសកាលពីពេលកន្លងមក ។ បើយោងតាមទស្សនៈព្រះពុទ្ធ ឌុច បានទទួលផលអាក្រក់ហើយ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ ថាន ឮឈ្មោះ ខៀវ សំផន នួន ជា និង អៀង សារី ពីមិត្តភក្តិរបស់គាត់ដែរ ប៉ុន្តែគាត់មិនដែលបានស្គាល់មុខមេដឹកនាំទាំងនោះទេ ពីព្រោះថាគាត់មានតំណែងតូចពេក ។ គាត់គាំទ្រការកាត់ទោសនេះ ក៏ប៉ុន្តែគាត់ចង់ឲ្យតុលាការសម្រាលទោសអ្នកទាំងនោះពីព្រោះមេដឹកនាំទាំងនោះសុទ្ធតែមានវ័យជរាណាស់ទៅហើយ ។ គាត់សុំឲ្យអ្នកដែលបានបាត់បង់បងប្អូននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យធ្វើការអភ័យទោសដល់មេដឹកនាំខ្មែរក្រហមទាំងនេះផង ពីព្រោះប្រជាជនម្នាក់ៗយ៉ាងហោចណាស់សុទ្ធតែបាត់បង់សាច់ញាតិម្នាក់នៅក្រោមរបបនោះដូចគ្នា ហើយប្រជាជនមិនគួរសងសឹងគ្នាទេ ។ គាត់មានប្រសាសន៍ថា «ពេលវេលាដ៏អាក្រក់នេះបានកន្លងផុតទៅហើយ យើងគួរតែអត់ទោសនិងសម្រាលទោសឲ្យមេដឹកនាំទាំងនោះ ។ យើងអាចធ្វើការអត់ទោសនិងសម្រាលទោសឲ្យបាននាពេលបច្ចុប្បន្ននេះ តែកាលពីរបបខ្មែរក្រហមយើងមិនអាចអត់ទោសនិងសម្រាលទោសបានទេ ពីព្រោះថាមេដឹកនាំមិនជឿ

សាសនាអ្វីទាំងអស់» ។ តាំងពីនោះរហូតមកដល់ពេលនេះ គាត់នៅតែសោកស្តាយចំពោះអ្វីដែលគាត់បានធ្វើសម្រាប់បដិវត្តនិងការបែកបាក់ពីក្រុមគ្រួសាររបស់គាត់ជានិច្ច ។

## សេចក្តីបញ្ចប់

ចំណុចដែលគួរឲ្យចាប់អារម្មណ៍ចំពោះវេទិកាពិភាក្សានៅម៉ាឡៃនេះគឺជាការចូលរួមដ៏សកម្មរបស់ ហាវ សុភា ដែលជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ និងសមត្ថភាពរបស់គាត់ក្នុងការទាក់ទាញអ្នកភូមិឲ្យធ្វើការពិភាក្សាគ្នា ។ វត្តមានរបស់គាត់ជំរុញឲ្យមានកិច្ចពិភាក្សាចំពោះឧក្រិដ្ឋកម្មរបស់ ឌុច ដែលកើតឡើងនៅមន្ទីរស-២១ និងបង្ហាញមុខនៅចំពោះជនរងគ្រោះដែលកំពុងទន្ទឹងចាំយុត្តិធម៌ពីកិច្ចដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហម ។ យ៉ាងណាក៏ដោយ អ្នកភូមិដែលចូលរួមភាគច្រើនមិនមានយោបល់ច្រើនអំពីសាលក្រមរបស់ ឌុច ទេ នេះប្រហែលដោយសារតែគាត់មិនបានស្គាល់ ឌុច ដោយផ្ទាល់ ។ ក៏ប៉ុន្តែអ្នកចូលរួមភាគច្រើនហាក់ដូចជាយល់ស្របថាអ្នកជិតខាងរបស់គាត់ដែលជាមេដឹកនាំជាន់ខ្ពស់ទាំងបួននាក់នោះគួរតែទទួលទោសស្រាល ពីព្រោះថាអ្នកទាំងនេះបានធ្វើរឿងល្អផង និងរឿងអាក្រក់ផង ហើយម្យ៉ាងទៀតអ្នកទាំងនោះមានវ័យចាស់ជរាអស់ទៅហើយ ។ បើទោះបីជាកុនឯកសារនិងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហាវ សុភា បានធ្វើឲ្យឧក្រិដ្ឋកម្មខ្មែរក្រហមនេះមើលទៅជាក់ស្តែងយ៉ាងណាក៏ដោយ ក៏អ្នកភូមិដែលមកចូលរួមទាំងនេះនៅតែបដិសេធពីការដឹងឮផ្ទាល់របស់មេដឹកនាំទាំងបួនទាក់ទងទៅនឹងមន្ទីរស-២១ដែររបៀបដូចជាបដិសេធថាមិនមានអ្វីទាក់ទៅនឹងបទឧក្រិដ្ឋទូទៅរបស់ខ្មែរក្រហម ។ ដើម្បីបង្កើតឲ្យមានការឆ្លុះបញ្ចាំងពីខ្លួនឯងថែមទៀតនោះ ក្រុមការងារមានគម្រោងនឹងបញ្ចាំងឈុតវីដេអូខ្លីរបស់ ឌុច ដែលបានសារភាពពីការទទួលខុសត្រូវរបស់គាត់ចំពោះអំពើសាហាវយង់ឃ្នងដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ នៅវេទិកាពិភាក្សាលើកក្រោយទៀត ។

**អាន ហាញឌុល**



អ្នកភូមិនៅលើគ្រាក់ទំព័រអានទស្សនាវដ្តីស្វែងរកការពិត

## ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធិភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា គេហទំព័រ *www.cambodiatribunal.org* ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណតវ៉េស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រត្តិបត្តិការជាមួយ *Illinois Holocaust Museum and Educational Center* ។ មុននិងផ្សព្វផ្សាយគេហទំព័រនេះ ត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ *David Scheffer* អតីតឯកអគ្គរដ្ឋទូតគោចរណ៍របស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល ក្លីនតុន និងលោក ឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា ។

# ពាក្យស្លោកដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍និងជំរុញឱ្យមានការផ្សះផ្សា

សិស្សានុសិស្សខ្មែរនិងចាមនៅឯវិទ្យាល័យបុស្សីកែវ រាជធានីភ្នំពេញបានអបអរសាទរក្រោយពីបានឃើញពាក្យស្លោកជាលើកដំបូងនៅក្នុងបរិវេណវិទ្យាល័យរបស់ខ្លួន ក្នុងគោលបំណងអប់រំក្មេងជំនាន់ក្រោយឲ្យចេះអត់ឱនអធ្យាស្រ័យគ្នា និងដើម្បីទប់ស្កាត់របបប្រល័យពូជសាសន៍នាថ្ងៃអនាគត ។ អត្ថន័យនៃពាក្យស្លោកទាំងពីរនេះបានរៀបរាប់ថា «និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហមគឺនិយាយពីការផ្សះផ្សា អប់រំកូនចៅ អត់ឱនអធ្យាស្រ័យគ្នា» និង «រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍» ។ ពាក្យស្លោកទាំងពីរនេះត្រូវបានតាក់តែងឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងត្រូវបានទទួលការអនុញ្ញាតឲ្យដាក់នៅតាមសាលាមធ្យមសិក្សាទូទាំងប្រទេសដោយក្រសួងអប់រំ យុវជន និង កីឡា ។

ពាក្យស្លោកទាំងពីរនេះគឺជាគ្រឿងលើកទឹកចិត្តដល់សិស្សានុសិស្សឲ្យចេះសួរនាំឪពុកម្តាយអំពីរបបខ្មែរក្រហមនិងដើម្បីជំរុញឲ្យមានការពិភាក្សាគ្នាក្នុងចំណោមអ្នកដែលធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហម ។

កាលពីខែមេសា ឆ្នាំ២០១០កន្លងទៅ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើការបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រថ្នាក់មូលដ្ឋានអំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គោលបំណងនៃការបណ្តុះបណ្តាលនេះគឺដើម្បីឲ្យគ្រូប្រវត្តិសាស្ត្រទាំងនោះយកចំណេះដឹងដែលបានរៀនរួចហើយទៅបង្រៀនដល់សិស្សានុសិស្សបន្តទៀតនៅថ្នាក់កម្រិតមធ្យមសិក្សា ។ គោលបំណងសំខាន់គឺមិនត្រឹមតែដើម្បីឲ្យក្មេងជំនាន់ក្រោយយល់ដឹងពីរបបខ្មែរក្រហមប៉ុណ្ណោះទេ តែដើម្បីឲ្យក្មេងជំនាន់ក្រោយចេះទប់ស្កាត់របបស្រដៀងគ្នានេះកុំឲ្យកើតឡើងជាថ្មីម្តងទៀត ។ ស្រដៀងគ្នានេះដែរ ពាក្យស្លោកដែលដាក់នៅតាមសាលាមធ្យមសិក្សានេះគឺដើម្បីឲ្យសិស្សយល់អំពីផលប្រយោជន៍នៃការរៀនពីរបបខ្មែរក្រហមក្នុងគោលបំណងទប់ស្កាត់របបនេះកុំឲ្យកើតមាននាថ្ងៃអនាគត ។

ការដាក់តាំងពាក្យស្លោកទាំងពីរត្រូវបានសម្ពោធជាផ្លូវការក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា លោកអនុប្រធានមន្ទីរអប់រំរាជធានីភ្នំពេញ លោក វីលៀម ស្មីត សហព្រះរាជអាជ្ញារងរបស់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ក្រោយពីសិស្សានុសិស្សអានពាក្យស្លោកដែលដាក់តាំងនៅពីមុខទីចាត់ការនៃវិទ្យាល័យបុស្សីកែវរួចមក សិស្សម្នាក់ៗបានទទួលនូវសៀវភៅមួយក្បាលនិងផ្ទាំងរូបភាពដែលរៀបរាប់ពីពាក្យស្លោកទាំងពីរនេះ ។ សៀវភៅដែលសិស្សានុសិស្សទទួលបានគឺសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

សម្រាប់សិស្សានុសិស្សនិងលោកគ្រូ-អ្នកគ្រូនៅវិទ្យាល័យបុស្សីកែវ ពាក្យស្លោកទាំងពីរនេះជាគ្រឿងជំរុញយ៉ាងសំខាន់ដើម្បីឲ្យរៀនសូត្រពីរបបខ្មែរក្រហមនិងការអត់ឱន ។

លោកនាយកវិទ្យាល័យបុស្សីកែវ ចៅ វីរយុទ្ធ បាននិយាយទៅកាន់សិស្សានុសិស្សជាងមួយពាន់នាក់ក្នុងពិធីសម្ពោធពាក្យស្លោកទាំងពីរនេះថា «ប្អូនៗកើតមិនទាន់របបខ្មែរក្រហមទេ ដូច្នេះជារឿងចាំបាច់ណាស់ក្នុងការរៀនសូត្រដើម្បីឲ្យចេះអត់ឱនគ្នាទៅវិញទៅមក» ។ សិស្សថ្នាក់ទី១២ម្នាក់ឈ្មោះ ប៊ុត សុក័ណ្ណារី បាននិយាយថា «ខ្ញុំមានក្តីរីករាយដែលទទួលបានសៀវភៅនេះ ។ ខ្ញុំនឹងយកទៅអានដើម្បីដឹងពីសម័យខ្មែរក្រហមបន្ថែមទៀត» ។ សុក័ណ្ណារី ធ្លាប់ដឹងពូពីរបបខ្មែរក្រហមតាមតែម្តាយប្រាប់ប៉ុណ្ណោះ ហើយ សុក័ណ្ណារី យល់ពីផលលំបាកដែលឪពុកម្តាយបានជួបប្រទះ ។ សុក័ណ្ណារី និយាយបន្ថែមទៀតថា «ខ្ញុំនឹងខំរៀនដើម្បីកុំឲ្យរបបនេះវិលត្រឡប់មកវិញម្តងទៀត» ។

គ្រូបង្រៀនម្នាក់ឈ្មោះ ទូន រ៉ាវី អាយុ៤៧ឆ្នាំ យល់ស្របឲ្យមានការសិក្សាអំពីរបបខ្មែរក្រហមនៅក្នុងថ្នាក់រៀនព្រោះសិស្សានុសិស្សអាចរៀនពីអតីតកាលដែលឪពុកម្តាយរបស់ខ្លួនធ្លាប់ឆ្លងកាត់ ។ ទូន រ៉ាវី បាននិយាយថា «ការអប់រំមានសារសំខាន់

ណាស់ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍» ។

កាលពីពាក់កណ្តាលខែកញ្ញាកន្លងទៅ សាលាក្តីខ្មែរក្រហម បានបញ្ជូនជនជាប់ចោទទាំងបួនរូបមាន អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និង នួន ជា ទៅកាត់ក្តីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយចោទប្រកាន់ពីបទប្រល័យពូជសាសន៍លើជនជាតិចាមនិងជនជាតិវៀតណាម ។ អើល លីសា ដែលជាសិស្សចាមម្នាក់នៅវិទ្យាល័យប៊ុស្សរីកែវមិនបានដឹងច្រើនទេថាខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញដល់ជនជាតិចាមយ៉ាងណានោះ ។ ប៉ុន្តែ លីសា ដឹងថា ខ្លួនធ្លាប់ឃើញម្តាយរបស់ខ្លួនយំពេលដែលគាត់រៀបរាប់ពីរបបខ្មែរក្រហមម្តងៗ ។ លីសា បាននិយាយថា «ខ្ញុំដឹងថា ជីវិតម្តាយរបស់ខ្ញុំមានការលំបាកណាស់កាលពីជំនាន់ខ្មែរក្រហម» ។ នៅពេលដែលសួរថាតើធ្វើដូចម្តេចដើម្បីទប់ស្កាត់របបនេះមិនឲ្យវិលត្រឡប់មកវិញ លីសា បាននិយាយថា «យើងត្រូវស្រឡាញ់គ្នា រួបរួមគ្នា និងសាមគ្គីគ្នាដោយមិនត្រូវប្រកាន់ពូជសាសន៍ឡើយ» ។

ការរៀនពីរបបកម្ពុជាប្រជាធិបតេយ្យមិនត្រឹមតែដើម្បី


លោកជីតាវ ទន់ សាអ៊ីម ចែកសៀវភៅដល់សិស្សានុសិស្សនៅវិទ្យាល័យប៊ុស្សរីកែវ


លោក វីលៀម ស្មីត ចែកសៀវភៅដល់សិស្សានុសិស្សនៅវិ



សិស្សានុសិស្សឡើងអានពាក្យស្លោក


សិស្សានុសិស្សថតរូបជុំគ្នានៅខាងមុខពាក្យស្លោក

យល់ដឹងពីអតីតកាលប៉ុណ្ណោះទេ តែដើម្បីយកចំណេះដឹងនេះមកប្រឡងក្នុងអំឡុងពេលប្រឡងទុតិយភូមិជារៀងរាល់ឆ្នាំផង ។ សិស្សថ្នាក់ទី១២ម្នាក់ឈ្មោះ ទេព ស្រីនិច បាននិយាយថា «ខ្ញុំរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីត្រៀមប្រឡងឆ្នាំនេះ» ។

លោក ចៅ វីរយុទ្ធ អាយុ៤១ឆ្នាំ ដែលត្រូវបានតែងតាំងជានាយកវិទ្យាល័យឫស្សីកែវកាលពីឆ្នាំ២០០៨ បានឲ្យដឹងថា «ពាក្យស្លោកនេះពិតជាល្អណាស់ដែលត្រូវបានដំឡើងនៅទីនេះ ដូច្នេះសិស្សានុសិស្សអាចអាននិងរៀនពីពាក្យស្លោកទាំងនេះដែរ ។ ពាក្យស្លោកនិងសៀវភៅប្រវត្តិសាស្ត្រនឹងលើកទឹកចិត្តដល់សិស្សឲ្យជឿថារបបខ្មែរក្រហមពិតជាកើតមានមែន ព្រោះសិស្សខ្លះមិនជឿថាមានរបបខ្មែរក្រហមទេ» ។

សម្រាប់លោកគ្រូ ដេន ដៃ ពាក្យស្លោកនេះពិតជាមានសារសំខាន់ណាស់ដើម្បីឲ្យសិស្សចេះអត់ឱននិងយល់គ្នាទៅវិញទៅមក ។ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងប្រាប់ពីភាពពិតរបស់ខ្មែរក្រហម ។ លោកគ្រូ ដេង ដៃ បានមានប្រសាសន៍ថា «ម្នាក់ៗត្រូវតែចងចាំពីរបបខ្មែរក្រហម» ។ **ញាណ សុជាតិ**


...ានុសិស្សនៅវិទ្យាល័យឫស្សីកែវ


សិស្សានុសិស្សនៅវិទ្យាល័យឫស្សីកែវ


...ក



ពាក្យស្លោកដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍

# សំបុត្រហៅឱ្យត្រឡប់ទៅផ្ទះ

ពេលរសៀលមួយក្នុងទសវត្សរ៍៩០ សែម បានទទួលសំបុត្រមួយច្បាប់ពីមន្ត្រីកាកបាទក្រហមម្នាក់ ខណៈពេលដែលគាត់កំពុងឃ្វាលគោនៅក្នុងព្រៃនៅស្រុកសំឡូត ។ ខ្លឹមសារនៃសំបុត្រនោះបានរៀបរាប់ថា «កូនជាទីស្រឡាញ់ សូមកូនត្រឡប់មកផ្ទះវិញនៅពេលកូនទទួលបានលិខិតនេះហើយ ។ ឪពុកមានជំងឺធ្ងន់និងមានការនឹករឭកកូនជាពន់ពេក ។ សូមកូនត្រឡប់មកផ្ទះយើងវិញដើម្បីជួបជុំគ្រួសារយើងម្តងទៀត» ។ សែម មិនដែលបានជួបឪពុកម្តាយនិងបងប្អូនបង្កើតរបស់គាត់អស់រយៈពេលជាយូរណាស់មកហើយ តាំងពីឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមបានដឹកគាត់ទៅធ្វើការភ្នំពេញនៅក្រោមបទបញ្ជារបស់អង្គការ ។ ពេលអានសំបុត្រនោះចប់ ទើប សែម ដឹងថាសំបុត្រនោះផ្ញើមកពីឪពុករបស់គាត់ដែលគាត់មិនដែលបានជួបជាយូរមកហើយ ។

ជាយុវជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាអតីតទាហានសាធារណរដ្ឋប្រជាមានិតកម្ពុជា និងក្រោយមកជាយោធាខ្មែរក្រហមក្រោយឆ្នាំ១៩៧៩ សែម ធ្លាប់បានហែលឆ្លងកាត់ជីវិតដូចមិត្តរួមអាវុធដទៃទៀតដែរ គឺការរស់នៅឆ្ងាយពីឪពុកម្តាយ ការអត់ឃ្លានដោយសាររស់នៅក្នុងព្រៃ និងការនឹករឭកដល់ឪពុកម្តាយ បងប្អូន ដោយរស់នៅពិភពពីរផ្សេងគ្នារវាងរដ្ឋាភិបាល និងកងទ័ពខ្មែរក្រហមនៅក្នុងព្រៃ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) ខ្មែរក្រហមបានចាត់ទុកយុវជនជាកម្លាំងដ៏សំខាន់របស់បដិវត្តន៍ ។ យុវជនត្រូវបានបំបែកចេញពីឪពុកម្តាយ និងចាត់តាំងឲ្យទៅធ្វើការនៅកងចល័តដែលតម្រូវឲ្យធ្វើការធ្ងន់ជាងក្រុមដទៃ ។ យុវជនត្រូវបានផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយដោយមិនចាំបាច់សុំការអនុញ្ញាតពីឪពុកម្តាយ ព្រោះឪពុកម្តាយមិនមានសិទ្ធិគ្រប់គ្រងកូនរបស់ខ្លួនទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។



អ្នកភូមិមកពីឃុំតាសាញ់ ស្រុកសំឡូតកំពុងស្តាប់ការពិភាក្សាអំពីសាលាក្តីខ្មែរក្រហម

សែម ជាយុវជនម្នាក់ក្នុងចំណោមយុវជនរាប់សែននាក់ដែលត្រូវបានផ្លាស់ឲ្យទៅរស់នៅកន្លែងឆ្ងាយដោយមិនមានការយល់ព្រមពីឪពុកម្តាយ ។ នៅដើមទសវត្សរ៍៧០ ឪពុកម្តាយរបស់ សែម ជាកសិករក្រីក្រក្នុងភូមិមួយក្នុងតំបន់រំដោះក្នុងខេត្តព្រះវិហារ ។ ភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ សែម ជាយុវជនម្នាក់ក្នុងចំណោមយុវជនមួយចំនួនដែលត្រូវបានជ្រើសរើសឲ្យទៅធ្វើការនៅភ្នំពេញ ។ ដំបូង សែម ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅស្ថានីយវិទ្យុស្ទឹងមានជ័យ ក្រោយមកទៅធ្វើការនៅរោងចក្រកែវដែលជាកន្លែងដែលគាត់ធ្វើការរហូតដល់ឆ្នាំ១៩៧៩ ពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ។

នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ សែម និងអ្នកធ្វើការជាមួយគាត់បានរត់ទៅជាមួយទាហានខ្មែរក្រហមដើម្បីគេចពីកងទ័ពវៀតណាម ។ ដោយមិនមានគោលដៅច្បាស់លាស់ សែម បានត្រឡប់មកស្ម័គ្រចិត្តចូលបម្រើកងទ័ពវៀតណាមដើម្បីវាយជាមួយខ្មែរក្រហមវិញ ហើយមួយរយៈក្រោយមកបានសម្រេចចិត្តផ្តាច់ខ្លួន ហើយធ្វើដំណើរទៅព្រំដែនជាមួយប្រជាជនដទៃទៀត ។

នៅព្រំដែន សែម មិនមានជម្រើសអ្វីក្រៅពីចូលបម្រើខ្មែរក្រហមទេ ពីព្រោះគាត់ភ័យខ្លាចមិនហ៊ានត្រឡប់ទៅតំបន់ដែលគ្រប់គ្រងដោយរដ្ឋាភិបាលវិញ ។ ប៉ុន្តែ គាត់តែងតែចង់ត្រឡប់ទៅស្រុកកំណើតនៅព្រះវិហារវិញជានិច្ច ។ គាត់មានភាពស្ទាក់ស្ទើរដោយសារតែខ្មែរក្រហមបានគំរាមគាត់ថា គាត់នឹងត្រូវធ្វើទារុណកម្ម ប្រសិនបើទាហានវៀតណាមចាប់បាន ។

សន្ធិសញ្ញាទីក្រុងប៉ារីសនៅខែតុលា ឆ្នាំ១៩៩១ បានបញ្ឈប់សង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ។ ប្រជាជនអាចត្រឡប់ទៅស្រុកកំណើតវិញបន្ទាប់ពីបែកបាក់គ្រួសារអស់រយៈពេលដប់ពីរឆ្នាំ ។ ដូចគ្នានឹងទាហានខ្មែរក្រហមដទៃទៀតដែរ សែម សង្ឃឹមថាគាត់អាចត្រឡប់ទៅផ្ទះដើម្បីស្វែងរកឪពុកម្តាយ ។ ប៉ុន្តែ អ្វីៗបានផ្លាស់ប្តូរនៅពេលដែលខ្មែរក្រហមធ្វើពហិការក្នុងការមិនចូលរួមជាមួយរដ្ឋាភិបាល ហើយចាប់ផ្តើមកាន់អាវុធម្តងទៀត ។

មកដល់ពេលនេះ សែម ធុញទ្រាន់នឹងសង្គ្រាមណាស់ ។ អ្នកដែលបានត្រឡប់ទៅស្រុកកំណើតវិញបានប្រាប់ឪពុកម្តាយរបស់ សែម អំពីស្ថានភាពរបស់គាត់នៅក្នុងព្រៃ ទើបមួយរយៈខ្លីក្រោយមកឪពុកគាត់ក៏សរសេរសំបុត្រមួយច្បាប់ផ្ញើមកគាត់ដើម្បីឲ្យត្រឡប់ទៅផ្ទះវិញ ។ សែម មានក្តីរំភើបជាខ្លាំងដែលដឹងថាឪពុកម្តាយរបស់គាត់នៅរស់ ហើយនិយាយថា «នៅពេលដែលខ្ញុំអានសំបុត្រនេះ ខ្ញុំយំ ។ ខ្ញុំចង់ទៅជួបឪពុកម្តាយខ្ញុំខ្លាំងណាស់ ពីព្រោះខ្ញុំបានបែកពីគាត់យូរណាស់មកហើយ» ។

សែម បានដឹកគោទៅផ្ទះវិញបន្ទាប់ពីទទួលបានសំបុត្រ ។ បន្ទាប់មក គាត់បានអានសំបុត្រនោះឲ្យប្រពន្ធគាត់ដែលបានរៀបការនៅពាក់កណ្តាលទសវត្សរ៍៨០ស្តាប់ ។ សែម មានក្តីរីករាយចង់ត្រឡប់ទៅផ្ទះណាស់ ។ ដោយសារតែនៅពេលនោះគាត់ជាទាហានខ្មែរក្រហម គាត់អាចប្រឈមមុខនឹងការចាប់ខ្លួននិងការសួរចម្លើយដោយរដ្ឋាភិបាលដែលគ្រប់គ្រងនៅតំបន់នោះ ។ សែម បានចាប់ផ្តើមសួរព័ត៌មានពីអ្នកដទៃអំពីថាតើវាមានសុវត្ថិភាពអាចត្រឡប់ទៅផ្ទះដែរឬទេ ។ នៅទីបញ្ចប់ សែម បានលួចធ្វើដំណើរដោយសម្ងាត់ត្រឡប់ទៅស្រុកកំណើតនៅខេត្តព្រះវិហារ ដែលនៅទីនោះគាត់បានជួបឪពុកម្តាយ និងបងប្អូនបង្កើតរបស់គាត់ ។ នេះជាឱកាសដ៏រីករាយមួយដែលសមាជិកគ្រួសារចង់បានយូរណាស់មកហើយ ហើយក៏ប្រហែលជាមិនដឹងថាមានឱកាសបែបនេះដែរ ។ នៅជាមួយឪពុកម្តាយបានមួយសប្តាហ៍ ក្រោយមក សែម បានត្រឡប់ទៅផ្ទះរបស់គាត់នៅសំឡូតវិញ ហើយប៉ុន្មានឆ្នាំក្រោយមកគាត់ត្រូវពិការដៃនិងជើងម្ខាងដោយសារមីន ។ ដំណឹងនេះបានធ្វើឲ្យឪពុកម្តាយរបស់គាត់មានភាពតក់ស្លុតម្តងទៀត ។

ទោះបីជាយ៉ាងណាក៏ដោយ សែម អាចជួបជុំជាមួយគ្រួសារម្តងទៀតបន្ទាប់ពីបែកបាក់គ្នាអស់រយៈពេល១៥ឆ្នាំ ។ ឪពុករបស់ សែម មិនដែលស្គាល់សំឡូតដែលជាកន្លែងកូនរបស់គាត់រស់នៅអស់រយៈពេលជិតពីរទសវត្សរ៍នោះទេ ។ សែម បាននិយាយអំពីការបែកបាក់គ្នានេះថា «ជាកេរដំណែលនៃសង្គ្រាម» ។ សែម ចង់ឲ្យឪពុករបស់គាត់មកលេងសំឡូត តែ សែម បាននិយាយដោយក្រៀមក្រំថា «ឪពុករបស់ខ្ញុំមានវ័យចំណាស់ណាស់ទៅហើយ ដូច្នេះគាត់កម្រមកមើលខ្ញុំណាស់ ។ នៅពេលដែលខ្ញុំនឹកគាត់ ខ្ញុំទៅលេងគាត់» ។ **ញាណ សុជាតិ**

# ក្លាយជាកុមារកំព្រាឪពុក

មុនរបបខ្មែរក្រហម ខូយ រីដា មានក្រុមគ្រួសារដ៏កក់ក្តៅមួយ ។ គ្រាន់តែខ្មែរក្រហមបានចូលមកគ្រប់គ្រងខេត្តពោធិ៍សាត់ភ្លាម អ៊ីៗបានផ្លាស់ប្តូរទាំងស្រុង ព្រោះរយៈពេលពីរថ្ងៃក្រោយមកឪពុករបស់គាត់ឈ្មោះ ខូយ នឿម ត្រូវខ្មែរក្រហមចាប់ខ្លួនយកទៅសម្លាប់នៅក្នុងព្រៃដោយចោទថា ផ្ទះដែលក្រុមគ្រួសារគាត់រស់នៅគឺជាបន្ទាយទាហាន ។

រីដា បន្តថា នៅពេលដែលម្តាយរបស់គាត់បានឃើញប្តីត្រូវអង្គការចាប់ខ្លួន គាត់ដឹងច្បាស់ថា «ប្តីរបស់គាត់ប្រាកដជាមិនអាចវិលត្រឡប់មកវិញឡើយ» ។ ប៉ុន្តែ ដោយសារតែមិនអស់ចិត្តម្តាយរបស់ រីដា ក៏លួចសួរអ្នកជិតខាងនៅទីនោះទៀត ។ ប៉ុន្តែចម្លើយដែលទទួលបានគឺថា «ប្តីរបស់អ្នកត្រូវកងឈ្លបពីរនាក់សម្លាប់ចោលនៅក្នុងទួលកោះហើយ» ។ ពេលដែលឮភ្លាម ម្តាយរបស់គាត់យំរហូត ។

បន្ទាប់មក ប្រជាជនរាប់រយគ្រួសារដែលភាគច្រើនមកពីខេត្តស្វាយរៀងត្រូវបានខ្មែរក្រហមយកទៅសម្លាប់ស្ទើរតែរៀងរាល់ថ្ងៃ ។ សកម្មភាពនេះចេះតែបន្តរហូតដោយខ្មែរក្រហមតែងតែហៅប្រជាជនតម្រង់ជួរនៅលើស្ពានឈើ រួចបាញ់សម្លាប់ចោលដែលក្នុងមួយថ្ងៃមានមនុស្សប្រហែលពី២០ទៅ៣០នាក់ ។ រីដានៅចាំហេតុការណ៍នោះយ៉ាងច្បាស់ ជាពិសេសខ្មែរក្រហមបានសម្លាប់ប្រជាជនយ៉ាងសាហាវព្រៃផ្សៃ ដោយបានវះពោះប្រជាជនទាំងនោះយកថ្លើមមកធ្វើម្ហូបថែមទៀតផង ។ លើសពីនេះទៅទៀតខ្មែរក្រហមបានយកប្រជាជនដែលប្រព្រឹត្តខុសទៅដាក់ក្នុងគុកដោយដាក់ខ្នោះដៃនិងខ្នោះជើងរួចធ្វើទារុណកម្មដើម្បីឲ្យឆ្លើយថាក្បត់នឹងអង្គការ ។ ដូច្នេះជារៀងរាល់ថ្ងៃ រីដា តែងតែឮសូរសំឡេងស្រែកថ្ងូររបស់ប្រជាជននិងឃើញសាកសពជាច្រើនដែលអណ្តែតតាមទឹកនិងតាមព្រៃនៅតាមដងស្ទឹងពោធិ៍សាត់ ។

អង្គការបានចាត់តាំង រីដា ឲ្យចូលកងកុមារដែលមានគ្នាប្រហែលជា២០០នាក់ដោយស្នាក់នៅក្នុងអគារឈើមួយ ។ ខ្មែរក្រហមបានបង្ខំឲ្យ រីដា និងក្មេងៗទាំងអស់ធ្វើការស្ទើរគ្មានពេលសម្រាក ចំណែកការហូបចុកវិញមិនបានគ្រប់គ្រាន់ទេ ។ ដូច្នេះ មួយរយៈក្រោយមក កុមារមួយចំនួនបានធ្លាក់ខ្លួនឈឺ និងខ្លះទៀតស្លាប់ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏គ្មាននរណាម្នាក់ហ៊ានប្រឆាំងនឹងបញ្ហានេះដែរ ព្រោះបើមិនអីចឹងទេអង្គការនឹងដាក់ទណ្ឌកម្មជាមិនខាន ។

នៅក្នុងឆ្នាំ១៩៧៧ អង្គការបានផ្លាស់ រីដា ឲ្យទៅរស់នៅក្នុងសហករណ៍កណ្តៀងវិញដែលមានចម្ងាយពីភូមិរបស់គាត់ប្រហែលជាបីគីឡូម៉ែត្រ ។ នៅទីនេះ ការងារមានការលំបាកជាងកន្លែងមុនទៅទៀត ព្រោះអង្គការបង្ខំឲ្យធ្វើការធ្ងន់ៗដូចជា កាប់ដី និងលើកទំនប់នៅក្នុងស្រែជាដើម ។

លើសពីនេះទៅទៀត អង្គការមិនអនុញ្ញាតឲ្យនរណាម្នាក់មកលេងឪពុកម្តាយឡើយ ទោះបីជាធ្វើការគ្រប់ផែនការក៏ដោយ ។ មិត្តភក្តិរបស់គាត់បានមកប្រាប់គាត់ថា «កុមារម្នាក់ដែលធ្វើការនៅក្នុងកងជាមួយយើងត្រូវអង្គការបាញ់សម្លាប់ហើយព្រោះកុមារនេះបានលួចទៅលេងម្តាយរបស់ខ្លួននិងបានលួចមាន់របស់អង្គការហូប» ។

បន្ទាប់ពីបានដឹងដំណឹងនេះ រីដា មានការតក់ស្លុតយ៉ាងខ្លាំងនិងគិតថាមិនត្រូវធ្វើអ្វីខុសនឹងវិន័យរបស់អង្គការទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែឃ្លានខ្លាំងពេកនៅពេលដែលរីដា ទៅចាំចាបនៅស្រែ គាត់ក៏លួចចាប់សត្វកណ្តុរយកមកអាំងហូបដោយមិនឲ្យអង្គការដឹងឡើយ ។

រីដា បានបន្តថា នៅក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមមានការរឹតបន្តឹងជាខ្លាំងដោយបានយកមនុស្សទៅសម្លាប់ជាបន្តបន្ទាប់ ។ ជាក់ស្តែង គាត់បានឃើញនារីកាត់ដេរនៅក្នុងខេត្តពោធិ៍សាត់ត្រូវបានគណៈតំបន់មកពីខេត្តកំពង់ឆ្នាំងបញ្ជាឲ្យស្លៀកពាក់ពណ៌ខ្មៅរួចហើយក៏យកទៅចាប់រំលោភនិងសម្លាប់ចោល ។ ក្រោយពីគណៈតំបន់នេះស្លាប់ ខ្មែរក្រហមបានឲ្យបុរសម្នាក់ឈ្មោះ តាទ្រី មក

ជំនួសតំណែងរបស់គាត់ ។ ទ្រី ជាមនុស្សចិត្តល្អតែងតែយកចិត្តទុកដាក់ក្នុងការរស់នៅរបស់ប្រជាជនជានិច្ច ។ រីដា បន្តថា ដោយសារតែឃើញអ្នកគ្រប់គ្រងមុនធ្វើបាបប្រជាជនខ្លាំងពេក តាទ្រី បានបញ្ជាឲ្យយកអ្នកទាំងនោះទៅសម្លាប់ចោលទាំងអស់ ។ បន្ទាប់មក តាទ្រី បានបញ្ជាឲ្យប្រជាជនមកប្រជុំនៅវត្តកំពង់ក្រសាំង ហើយប្រកាសប្រាប់ថា «បើមានបាយត្រូវហូបបាយ បើមានមាន់កាប់មាន់ បើមានជ្រូកកាប់ជ្រូកហូបទៅ» ។ ពេលនោះ ប្រជាជនមានការត្រេកអរយ៉ាងខ្លាំង ដោយម្នាក់ៗបានទះដៃអបអរសាទរចំពោះគាត់ ។ ប៉ុន្តែមិនបានប៉ុន្មានថ្ងៃផង អង្គការក៏បានចាប់ខ្លួនគាត់ទៀត (ពេលនោះស្លាប់នៅទួលស្លែង) ។

ចំណែកការរស់នៅរបស់បងប្រុស រីដា ក៏ទទួលរងការលំបាកខ្លាំងណាស់ដែរដោយសារគាត់ត្រូវផ្លាស់ទៅរស់នៅតំបន់ដាច់ស្រយាលមួយដាច់ដោយឡែកពីបងប្អូននិងមានជំងឺជាប់ខ្លួនផង ។

លើសពីនេះទៅទៀត ខ្មែរក្រហមមានបំណងយកគាត់និងប្រជាជននៅទីនោះទៅសម្លាប់ចោលទាំងអស់ដោយឲ្យគាត់និងប្រជាជននៅក្នុងភូមិជីករណ្តៅដែលមានប្រវែងប្រហែលមួយរយម៉ែត្រដើម្បីសម្លាប់ដាក់ក្នុងរណ្តៅនោះ ។ ប៉ុន្តែសំណាងល្អដែលគាត់អាចរស់រានមានជីវិត ព្រោះពេលនោះចំពេលដែលទាហានវៀតណាមចូលមករំដោះឲ្យរួចផុតពីសេចក្តីស្លាប់ ។

ដោយសារខឹងនឹងខ្មែរក្រហមដែលសម្លាប់មនុស្សយ៉ាងសាហាវឃោរឃៅបែបនេះ ក្រោយមក គាត់ក៏ចូលបម្រើកងទ័ពវៀតណាមដើម្បីប្រយុទ្ធនឹងកងទ័ពខ្មែរក្រហមវិញ ។ ប៉ុន្តែ ពេលបំពេញការងារនេះបងប្រុសរបស់ រីដា បានត្រូវរបួសត្រង់ចង្កេះ ។ ពេលម្តាយរបស់គាត់ឮដំណឹងនេះភ្លាម គាត់បានធ្វើដំណើរពីស្រុកកណ្តៀងដើម្បីមកសួរសុខទុក្ខ និងយកគាត់មកព្យាបាលនៅមន្ទីរពេទ្យពោធិ៍សាត់ ។ ដោយសារតែបារម្ភពីបងប្រុសខ្លាំងពេក រីដា បានមកសួរសុខទុក្ខគាត់នៅទីនោះដែរ ។ រីដា មានការតក់ស្លុតជាខ្លាំងពេលដែលឃើញបងប្រុសរបស់គាត់ចេញឈាមតាមមាត់ ច្រមុះនិងពោះយ៉ាងច្រើន ។ ពេលនោះ ទាហានពេទ្យវៀតណាមម្នាក់បាននិយាយប្រាប់ថា បើមិនវះកាត់នៅក្នុងអំឡុងពេលបីថ្ងៃគាត់នឹងស្លាប់ជាមិនខាន ។ មិនយូរប៉ុន្មាន ទាហានវៀតណាមបានយកបងប្រុសរបស់គាត់ទៅព្យាបាលនៅប្រទេសវៀតណាមវិញ ។

នៅក្នុងឆ្នាំ១៩៧៩ គ្រួសាររបស់ រីដា បានធ្វើដំណើរត្រឡប់មកលំនៅឋានវិញ ។ ពេលនោះ ម្តាយរបស់ រីដា អស់សង្ឃឹមជាខ្លាំងព្រោះគិតថា កូនរបស់គាត់ដែលចូលធ្វើទាហានជាមួយវៀតណាមបានស្លាប់ទៅហើយ ។ ប៉ុន្តែ មួយឆ្នាំក្រោយមក គ្រួសាររបស់ រីដា បានជួបជុំគ្នាទាំងអស់ ដោយឃើញគាត់បានវិលត្រឡប់មកស្រុកកំណើតវិញ ។

នៅក្នុងឆ្នាំ១៩៨៦ រីដា បានក្លាយជាគ្រូបង្រៀនម្នាក់ ។ ដោយសារតែការខិតខំប្រឹងប្រែងធ្វើការ ក្រោយមក រីដា ត្រូវបានតែងតាំងឲ្យធ្វើជានាយកសាលានៅអនុវិទ្យាល័យខេត្តពោធិ៍សាត់ ។ ទោះបីជារយៈពេលជាង៣១ឆ្នាំបានកន្លងផុតទៅក៏ដោយ ប៉ុន្តែបទពិសោធន៍ដែលគាត់បានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមនៅតែដក់ជាប់នៅក្នុងអារម្មណ៍របស់គាត់ជានិច្ច ។ ឥឡូវនេះ នៅពេលដែលតុលាការបានកាត់ទោសមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រីដា សប្បាយចិត្តជាខ្លាំងព្រោះអាចរកយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់ទៅ ជាពិសេសអាចផ្សះផ្សារបួសផ្លូវចិត្តរបស់ប្រជាជនផងដែរ ។

**ស៊ិន សុធីតា**

# ដំណឹងស្វែរកឪពុក

ខ្ញុំបាទឈ្មោះ លាភ ចាន់ភារម្យ អាយុ៣៩ឆ្នាំ រស់នៅភូមិអ្នកលឿង ឃុំអ្នកលឿង ស្រុកពាមរ៍ ខេត្តព្រៃវែង ។ ខ្ញុំបាទសូមប្រកាសស្វែរកឪពុកឈ្មោះ ម៉ុច ចាន់ណារី ហៅ លាភ មានស្រុកកំណើតនៅភូមិបឹងព្រះ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង ដែលបានបាត់ខ្លួនពីស្រុកពាមជរ ឃុំកោះរកា នៅខែមេសា ឆ្នាំ១៩៧៧ ដោយសារអង្គការបញ្ជូនឲ្យទៅយកអង្ករ ។ ចាប់តាំងពីពេលនោះមកគាត់បាត់ខ្លួនរហូត ។

ដូច្នេះប្រសិនបើអ្នកណាបានដឹង ឬឮឈ្មោះខាងលើនេះ សូមទំនាក់ទំនងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើ ឬទូរស័ព្ទលេខ ០១៥ ៦៧៣ ០០០ ឬ ០៩៧ ៨៧៧ ៧០០៦ ។ **សូមអរគុណ!**

# គ្រួសារ ហេង ផៃហុង ក្នុងរបបខ្មែរក្រហម

ហេង ផៃហុង កើតនៅភូមិញ្ញៅ ឃុំញ្ញៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ។ បច្ចុប្បន្ន ផៃ ហុង មានអាយុ៣៩ឆ្នាំ និងជាគ្រូបង្រៀនប្រវត្តិសាស្ត្រនៅវិទ្យាល័យតាំងក្រសាំង ខេត្តកំពង់ធំ ។

ផៃហុង ជាកូនទីមួយក្នុងចំណោមបងប្អូនប្រាំមួយនាក់ ដែលមានម្ដាយឈ្មោះ ខូវ សេងអ៊ាង និងឪពុកឈ្មោះ កៅ អៀងទ័រ ធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាត្នោតជុំ នៅសម័យ លន់ នល់ ។


ហេង ផៃហុង

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសគ្រួសារ ផៃហុង ឲ្យទៅទួលព្រះខ្វបដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់អាមេរិក ។ ក្រោយមក ខ្មែរក្រហមបានជម្លៀសគ្រួសារ ផៃហុង និងប្រជាជនដែលរស់នៅភូមិបុស្សឹ ឲ្យទៅរស់នៅភូមិត្រពាំងព្រីង ឃុំក្រយា (ដែលសុទ្ធសឹងជាព្រៃ) វិញ ។ នៅទីនោះបានមួយរយៈ ស្រាប់តែមានយន្តហោះមកទម្លាក់គ្រាប់បែកបណ្ដាលឲ្យប្រជាជនស្លាប់ និងរបួសជាច្រើននាក់ ។

រហូតដល់ខ្មែរក្រហមទទួលជ័យជម្នះ ទើបគ្រួសារគាត់ត្រូវបានអនុញ្ញាតឲ្យត្រឡប់មករស់នៅភូមិញ្ញៅវិញ ។ មិនយូរប៉ុន្មាន ខ្មែរក្រហមចាប់ផ្ដើមប្រមូលទ្រព្យសម្បត្តិដាក់ជារបស់សមូហភាព រួចហើយចាត់តាំងឲ្យប្រជាជនធ្វើការរួម និងហូបរួម ។ ដោយឃើញការរស់នៅមានការលំបាកដូច្នេះ ផៃហុង បានសួរឪពុកគាត់ថា ហេតុអ្វីបានជាខ្មែរក្រហមឲ្យយើងមកហូបដូច្នេះ? ពេលនោះ ឪពុកគាត់មិនបាននិយាយអ្វីច្រើនទេ គ្រាន់តែឆ្លើយថា «អង្គការតម្រូវឲ្យមកហូបបាយរួម» ប៉ុណ្ណោះ ។ ក្រោយមក ខ្មែរក្រហមបានឲ្យប្រជាជនហូបបបរ ហើយនៅរដូវខ្វះខាតអង្ករខ្លាំង ចុងភៅធ្វើបបរលាយដើមត្រកួនវិញ បណ្ដាលឲ្យប្រជាជនហូបមិនគ្រប់គ្រាន់ និងបាក់កម្លាំងគ្រប់ៗគ្នា ។

នៅពេលនោះ ខ្មែរក្រហមក៏បានជម្លៀសគ្រួសារអ្នកនៅភ្នំពេញជាច្រើនឲ្យមករស់នៅភូមិញ្ញៅនេះដែរ ដែលគ្រួសារទាំងនោះភាគច្រើនត្រូវទទួលរងទណ្ឌកម្មជាមួយនឹងការងារធ្ងន់ធ្ងរ និងហូបមិនបានគ្រប់គ្រាន់ ។ ផៃហុង រៀបរាប់ថា គ្រួសារយាយម្នាក់ (ផៃហុង តែងតែហៅឈ្មោះគាត់ថា យាយអយ) មានសមាជិកប្រាំបីនាក់មករស់នៅភូមិញ្ញៅ ប៉ុន្តែក្រោយរបបខ្មែរក្រហមដួលរលំ គ្រួសារគាត់នៅសល់សមាជិកតែបីនាក់ប៉ុណ្ណោះ ។ ចំណែកពូរបស់ ផៃហុង ដែលជាអ្នកមូលដ្ឋានក៏ឈ្លបឃុំឈ្មោះ នៅ និងឈ្លបពីរនាក់ទៀត (មិនចាំឈ្មោះ) ចងស្លាបសេក រួចចងព្យួរឡើងលើនៅព្រៃមួយកន្លែង (ក្បែររោងបាយរួម) ។ ខណៈនោះ ផៃហុង ដើរទៅហូបបាយ ស្រាប់តែឃើញ និងឮពូរបស់គាត់ស្រែក «ជួយផងៗ!» ។ ប៉ុន្តែ ផៃហុង មិនហ៊ានទៅជួយទេព្រោះមានឈ្លបយាមនៅទីនោះ ។ ក្រោយមក ពូរបស់គាត់បានខាំបណ្ដាច់ខ្សែនីឡុងធ្លាក់មកដី រួចរត់ទាំងដៃនៅជាប់ចំណង កាត់ស៊ីងទៅលាក់ខ្លួននៅស្រុកបារាយណ៍ អស់រយៈពេលកន្លះឆ្នាំ ទើបគាត់រួចពីការតាមចាប់ខ្លួន ។

នៅក្នុងភូមិ អង្គការចាត់តាំងឪពុករបស់ ផៃហុង ឲ្យទៅនៅក្នុងកងភ្ជួរស្រែ ប៉ុន្តែដោយសារឪពុក ផៃហុង ជាកូនកាត់ចិនមានសម្បុរស និងរៀនជាប់សញ្ញាប័ត្រឌីប្លូម និងជាគ្រូបង្រៀន ទើបឈ្លបឃុំឈ្មោះ លី, សន, ណាល់ រាយការណ៍ទៅថ្នាក់លើថា «ឪពុកគាត់ជា សេ.អ៊ី.អា» ។ បន្ទាប់ពីរាយការណ៍រួច នៅពេលល្ងាចមួយ ឈ្លបទាំងនោះបានមកចាប់ឪពុក ផៃហុង យកទៅសួរចម្លើយនៅវាលក្រោម ឬ បឹងសន្ទួច (ជាកន្លែងធ្វើស្រែ) និងបម្រុងយកទៅសម្លាប់ចោល ។ ពេលនោះ ឈ្មោះ ចេត ជាឈ្លបភូមិ (ត្រូវបងប្អូនរបស់ ណាល់) និងត្រូវជាមិត្តភក្តិឪពុកគាត់បានទៅសុំឈ្លបឃុំឲ្យលើកទោសឲ្យឪពុកគាត់ ហើយម្យ៉ាងទៀតដោយសារនៅពេលមេឃុំបានទៅស៊ើបសួរប្រវត្តិរូបឪពុកគាត់ដឹងថាមិនមែនជា សេ.អ៊ី.អា ទើបកងឈ្លបដោះលែងឪពុកគាត់ឲ្យរួចខ្លួន ។ ប៉ុន្តែមេឃុំមិនអនុញ្ញាតឲ្យឪពុក ផៃហុង ត្រឡប់មកផ្ទះជួបជុំគ្រួសារវិញទេ ដោយបានបញ្ជូនគាត់ឲ្យទៅកាប់ឈើ និងឫស្សីសម្រាប់ធ្វើ

ក្បូនទៅភ្នំដី ដែលជាតំបន់គ្រុនចាញ់ ដោយមិនបានផ្តល់ដំណឹងឲ្យ ប្រពន្ធនិងកូនដឹងឡើយ ។ នៅភ្នំដីរយៈពេលបីឆ្នាំ ខ្មែរក្រហម បានចាត់តាំងឪពុក ឆៃហុង ទៅកាប់ឆ្ការព្រៃ និងពង្រាបដីដំបូក ដើម្បីធ្វើស្រែនៅចម្ការឡូង (ស្ថិតនៅខាងកើតភ្នំសន្ទុក) វិញ ដែល នៅទីនោះ ឪពុកគាត់ចាប់ផ្តើមឈឺជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ។

ចំណែកម្តាយ ឆៃហុង ធ្វើការក្នុងកងលើកភ្លឺស្រែ និងជីក ប្រឡាយនៅក្នុងសហករណ៍ឃុំញ៉ោ ក៏ត្រូវឈ្លបខ្មែរក្រហមឈ្មោះ ធី បម្រុងចាប់យកទៅសម្លាប់ដែរ ដោយចោទថា «ខ្ជិលមិនទៅធ្វើ ការ» ព្រោះពេលនោះម្តាយ ឆៃហុង មកមើលកូនទីពីរ និងទីបីដែល មានជំងឺនៅកងកុមារ ហើយមិនត្រឡប់ទៅធ្វើការងារនៅកងវិញ ។ ប៉ុន្តែក្រោយដឹងរឿងពិត ទើប ធី លើកលែងទោសឲ្យម្តាយគាត់ ។ នៅពេលនោះ ដោយសារ ឆៃហុង មានអាយុប្រាំពីរឆ្នាំ មិនទាន់គ្រប់ អាយុចូលកងកុមារ ទើបខ្មែរក្រហមឲ្យគាត់នៅមើលប្អូនស្រីទីពីរ នៅផ្ទះ ចំណែកប្អូនទីបីខ្មែរក្រហមឲ្យម្តាយគាត់យកទៅដាក់ក្នុងកង កុមារឲ្យយាយៗមើលវិញ ។ ឆៃហុង នៅចាំថា ខ្មែរក្រហមបាន បែកស្បែកជើង និងអាវដល់កុមារគ្រប់ៗគ្នា ចំណែកគាត់នៅ ផ្ទះអង្គការបែកអាវឲ្យមួយដែរ ប៉ុន្តែគាត់មិនព្រមយក ព្រោះអាវ នោះ សម្រាប់កុមារីពាក់ ។ រាល់ថ្ងៃ ពេលម្តាយមិននៅផ្ទះ ឆៃហុង តែងតែយកកាទៅដាក់បបរមកទុកឲ្យប្អូនហូបជានិច្ចនៅពេលចុងភៅ បើករបបម្តងៗ ។ ពេលខ្លះ ឆៀតពេលទំនេរពីមើលប្អូន ឆៃហុង បាន ដើរលេងក្នុងភូមិ និងទៅលួចមើលកងកុមារចូលរៀននៅក្នុងថ្នាក់ ប៉ុន្តែស្រាប់តែពេលនោះគ្រូឈ្មោះ ឡៃ មិនបង្រៀនអក្សរទេ បែរជាបិទទ្វារបន្ទប់រួចយករំពាត់ផ្តៅវាយក្មេងៗទាំងនោះទៅវិញ ដែលក្នុងនោះមានមីងរបស់ ឆៃហុង ផងដែរ ។ បន្ទាប់ពីវាយរួច ទើបគ្រូ ឡៃ ចាត់តាំងឲ្យក្មេងៗទាំងនោះទៅកាប់ទន្ទ្រានខែត្រ និងដើររើសអាចម៍គោធ្វើជីវិញ (ក្រោយរបបខ្មែរក្រហមដួលរលំ គ្រូ ឡៃ ត្រូវកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបាញ់ សម្លាប់ចោល) ។ នៅថ្ងៃមួយ ឆៃហុង និងក្មេងៗ នៅក្នុងភូមិបាន នាំគ្នាទៅហែលទឹកអូរ ស្រាប់តែកងឈ្លបម្នាក់ឈ្មោះ ធី (ដែលពី មុនគំរាមចាប់ម្តាយគាត់) បានជិះកង់ដេញចាប់ ពេលនោះគាត់រត់ កាត់វាលស្រែទើបបានរួចខ្លួន ។

ក្រោយរបបខ្មែរក្រហមដួលរលំ ទើប ឆៃហុង ឃើញឪពុក របស់គាត់ត្រឡប់មកជួបជុំគ្រួសារវិញ (ព្រោះឪពុកគាត់ឈឺជំងឺគ្រុន ចាញ់ទើបខ្មែរក្រហមអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ) ។ នៅពេល នោះ ដោយសារពុំមានអាហារបរិភោគ ឪពុក ឆៃហុង បាននាំ ប្រពន្ធទៅប្រូតស្រូវនៅវាលស្រែក្រោមទុកសម្រាប់ហូប ព្រោះ របស់របរសម្ភារភាពដូចជា ស្រូវអង្ករ និងគោ ក្របី ជ្រូក មាន់ ទា ត្រូវប្រជាជនយកមកធ្វើជាកម្មសិទ្ធិរៀងៗខ្លួនអស់ហើយ ។ ក្រោយ ពីកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរៀបចំរដ្ឋអំណាច គ្រប់គ្រងភូមិរួចរាល់ហើយ ឪពុក ឆៃហុង ក៏ចូលធ្វើជាបុគ្គលិក ពេទ្យប្រចាំឃុំញ៉ោ ចំណែកម្តាយគាត់មកប្រកបមុខរបរធ្វើស្រែ ។

នៅឆ្នាំ១៩៨០ ឆៃហុង បានចូលរៀនអក្សរនៅក្រោមកុដិ លោកព្រោះសាលារៀនក្នុងភូមិត្រូវខ្មែរក្រហមរុះរើចោលអស់ ។ ក្រោយមក ឆៃហុង បានផ្លាស់ទៅរៀននៅសាលាបឋមសិក្សា ញ៉ោវិញ ។ នៅឆ្នាំ១៩៨៤ ឆៃហុង បានចូលរៀននៅវិទ្យាល័យ តាំងក្រសាំង និងវិទ្យាល័យកំពង់ថ្ម រហូតបានប្រឡងជាប់គ្រូ ប្រវត្តិវិទ្យានៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

សព្វថ្ងៃ ឆៃហុង បង្រៀនប្រវត្តិវិទ្យាថ្នាក់ទី១១ និងថ្នាក់ ទី១២ នៅវិទ្យាល័យតាំងក្រសាំង ខេត្តកំពង់ធំ ។ ឆៃហុង រៀប រាប់ថា នៅពេលបង្រៀន គាត់តែងតែរៀបរាប់ពីការបាត់បង់ពូ (ខាងឪពុក) ពីរនាក់ និងបងប្អូនខាងម្តាយពីរនាក់ និងជីវិតក្រុម គ្រួសារគាត់នៅក្នុងរបបខ្មែរក្រហមប្រាប់ដល់សិស្សជានិច្ច ដើម្បី ឲ្យសិស្សចងចាំ និងយល់ដឹងកាន់តែច្បាស់ពីរបបនោះដែលបានធ្វើ បាបប្រជាជន ក៏ដូចជាបងប្អូន និងឪពុកម្តាយរបស់គេដែរ ។

ឆៃហុង បានបន្តថា ទោះបីជាអតីតកម្មាភិបាលខ្មែរក្រហម ឈ្មោះ ធី និងឈ្មោះ ម៉េត ដែលសព្វថ្ងៃរស់នៅក្នុងស្រុកជាមួយ គាត់ និងធ្លាប់ធ្វើអំពើអាក្រក់មួយចំនួនមកលើក្រុមគ្រួសារគាត់ក៏ ដោយ ក៏គាត់មិនខឹងនឹងអ្នកទាំងពីរដែរ ។ ប៉ុន្តែដោយសារការខ្មាស អៀនចំពោះអំពើអាក្រក់របស់ខ្លួនដែលបានប្រព្រឹត្តមកលើប្រជាជន ទើបនៅពេលឃើញរំពុកពីរបបខ្មែរក្រហមម្តងៗ ម៉េត តែងតែឱនមុខ ចុះ និងមិននិយាយស្តីអ្វីទាំងអស់ ។ ឆៃហុង គិតថា ម៉េត និងកម្មាភិបាល ខ្មែរក្រហមផ្សេងទៀតគួរតែនិយាយរឿងផ្ទាល់ខ្លួនឲ្យក្មេងៗបានដឹង ដើម្បីរួមចំណែកក្នុងការថែរក្សាប្រវត្តិសាស្ត្រ ។ **សោម ប៊ុនថន**

# អ្នករៀបចំអាហារនៅមន្ទីរក-៦

ប្រាក់ ភៅ កើតនៅភូមិពោធិ៍ដុះ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅពេលមានអាយុ១១ឆ្នាំ ភៅ ត្រូវប្រធានកងចាត់តាំងឲ្យចូលធ្វើការងារនៅក្នុងកងចល័តនារី ក្រោយមកដោយសារការងារលំបាកខ្លាំងពេក ភៅ បានសុំប្រធានកងមកធ្វើការនៅមន្ទីរក-៦ ក្រុងភ្នំពេញវិញ ។

កាលពីនៅតូច ភៅ មិនបានរៀនសូត្រជ្រៅជ្រះទេ ព្រោះតែឪពុកម្តាយគាត់ពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទិញសម្ភារៈសិក្សាឲ្យគាត់ ។ នៅឆ្នាំ១៩៧៥ ក្រោយពីកងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះ គ្រួសាររបស់ ភៅ ត្រូវបានជម្លៀសឲ្យទៅរស់នៅភូមិត្រពាំងក្រសាំង ។ នៅទីនោះ ម្តាយរបស់ ភៅ ត្រូវបានចាត់តាំងឲ្យធ្វើជាចុងភៅនៅរោងបាយរួម ចំណែក ភៅ និងប្អូនៗរបស់គាត់ត្រូវបានប្រធានភូមិជ្រើសរើសឲ្យទៅធ្វើការនៅកងកុមារ ។ នៅពេលនោះ គ្មានអ្នកណាម្នាក់ហ៊ានប្រឆាំងនឹងបញ្ជារបស់ប្រធានភូមិឡើយ ក្រោយពីប្រធានភូមិបានគំរាមថា «ប្រសិនបើមានអ្នកណា មិនព្រមទៅធ្វើការ យើងមិនឲ្យហូបបាយទេ» ។

នៅក្នុងកងកុមារ ភៅ ត្រូវក្រោកតាំងពីម៉ោង៤យប់ ដើម្បីទៅដឹកប្រឡាយ និងរើសអាចម៍គោរហូតដល់ម៉ោង៦ល្ងាច ទើបឈប់សម្រាកបាន ។ ដោយសារតែថ្ងៃខ្លះគាត់រកមិនបានគ្រប់ចំនួន១៥ទៅ២០គីឡូក្រាម ប្រធានកងមិនអនុញ្ញាតឲ្យគាត់ឈប់សម្រាកទេ ដោយបញ្ជាឲ្យគាត់ទៅកាប់ទន្រ្ទានខែត្របន្ថែម និងដាក់ទណ្ឌកម្មឲ្យឈរហាលថ្ងៃរយៈពេលមួយម៉ោងទៀតផង ។ ប៉ុន្តែអាហារដែលគាត់ទទួលបានគឺមិនគ្រប់គ្រាន់ឡើយ ។

ភៅ នៅចាំបានថា អង្គការតែងតែលើកឡើងថា «មិនត្រូវឲ្យកុមារហូបបបរទេ ពីព្រោះត្រូវបំពាក់បំប៉នដើម្បីឲ្យមានកម្លាំងធ្វើការងារ» ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏នៅរៀងរាល់ថ្ងៃទី១០និងថ្ងៃទី២០ អង្គការនឹងចែកដំឡូងស្ងោរ និងបាយដំណើបម្នាក់មួយដុំឲ្យហូបបន្ថែមទៀតដែរ ។ ដោយសារតែ ភៅ មិនដែលទទួលបានរបបទាំងនេះ នៅពេលដែលធ្វើការលំបាក ឬក៏ហត់អស់កម្លាំងម្តងៗ គាត់តែងតែនឹកឃើញស្ថានភាពដែលរស់នៅជាមួយឪពុកម្តាយ និងចង់មកលេងផ្ទះ ។ ភៅ បន្តថា ព្រោះតែនឹកផ្ទះខ្លាំងពេក នៅពេលដែលប្អូនប្រុសរបស់គាត់លួចមកជួបឪពុកម្តាយ ឈ្លបខ្មែរក្រហមបានចាប់ប្អូនរបស់គាត់ រួចវាយទម្លាក់ពីលើរទេះ ។

នៅឆ្នាំ១៩៧៦ ហៃ ជាប្រធានកងនារីបានប្រកាសជ្រើសរើស ភៅ ឲ្យទៅធ្វើការនៅកងនារី ដែលមានបែងចែកជាបីក្រុម គឺក្រុម១ ក្រុម២ និងក្រុម៣ ។ ភៅ ស្ថិតនៅក្នុងក្រុមទី២ មានសមាជិកចំនួន១០នាក់ មានភារកិច្ចដឹកប្រឡាយ ស្ទូងស្រូវ និងរែកដី ដែលការងារនេះគាត់ត្រូវតែធ្វើឲ្យហើយតាមផែនការកំណត់របស់អង្គការ ។ ប៉ុន្តែទោះបីជាធ្វើការនេះហើយក៏ដោយ ក៏ក្រោយពីស្ទូងរួច ក្រុមរបស់ ភៅ ត្រូវតែដឹកប្រឡាយឲ្យបាន១០ម៉ែត្រក្នុងមួយថ្ងៃថែមទៀត ។ ក្រុមរបស់ ភៅ បានធ្វើទាន់តាមផែនការ ចំណែកក្រុមណាដែលធ្វើមិនហើយអង្គការស្តីបន្ទោស និងត្រូវហៅទៅកសាង ដោយលើកឡើងថា «ក្រុមគេធ្វើហើយ ចុះម៉េចក្រុមយើងធ្វើមិនហើយ ថ្ងៃមុខថ្ងៃក្រោយខំប្រឹងធ្វើការឲ្យដូចក្រុមគេ» ។

ជារៀងរាល់ថ្ងៃ អង្គការចែករបបអង្ករពីរកំប៉ុងសម្រាប់មនុស្ស១០នាក់ ដូច្នេះ ភៅ មិនមានអាហារហូបគ្រប់គ្រាន់ទេ ដោយហូបតែបបររាវៗលាយជាមួយសម្លម្ជូរព្រលិតប៉ុណ្ណោះ ។ លើសពីនេះទៅទៀត ពេលហូបម្តងៗ បើមានអ្នកណាម្នាក់នៅក្នុងក្រុមធ្វើឲ្យបាក់ស្លាបព្រា អង្គការនឹងចោទថាជាខ្មាំង ហើយយកទៅកសាង ឬធ្វើទារុណកម្មជាមិនខាន ។ ដូច្នេះ ភៅ តែងតែប្រុងប្រយ័ត្នខ្លួន និងមិនដែលឲ្យអង្គការយកទោសពៃរ៍បានឡើយ ។

ភៅ ធ្លាប់បានសុំប្រធានកងទៅលេងឪពុកម្តាយនៅផ្ទះ ពេលនោះប្រធានកងក៏អនុញ្ញាតឲ្យទៅ ប៉ុន្តែបានព្រមានថា «ត្រូវកាត់ចិត្តពីឪពុកម្តាយខ្លះទៅ ព្រោះគាត់មានអ្នកមើលថែហើយ និងត្រូវត្រឡប់មកកងវិញនៅម៉ោង៤ព្រឹក» ។ ភៅ មិនហ៊ានប្រកែកនឹងបញ្ជារបស់ប្រធានកងឡើយ បើមិនអ៊ីចឹងទេគាត់នឹងត្រូវដាក់ទណ្ឌកម្មឲ្យរែកដី ឬយកក្រដោកចងភ្ជាប់នឹងក រួចដើរនិយាយ

ប្រាប់មនុស្សនៅក្នុងកងថា «សូមកុំយកតម្រាប់តាមខ្ញុំ» ។ នៅកងនារី អង្គការបានចែកខោអាវមួយកំប្លេឲ្យ ភៅ ប៉ុន្តែត្រូវចោរលួចយកទៅបាត់ នៅពេលគាត់ដាក់ហាលខាងក្រោរោងស្នាក់នៅ ។

នៅឆ្នាំ១៩៧៧ ប្រធានកងរងឈ្មោះនារី ស៊ីម បានជ្រើសរើសកុមារចំនួន១០នាក់ឲ្យទៅធ្វើការនៅទីក្រុងភ្នំពេញ ពេលនោះ ភៅ ក៏សុំអនុប្រធានកងទៅដែរ ព្រោះគាត់គិតថា នៅកងធ្វើការគ្មានពេលសម្រាក អាហារក៏ហូបមិនគ្រប់គ្រាន់ ហើយសម្លៀកបំពាក់ក៏មិនមាន ។ មកដល់ភ្នំពេញ អង្គការបានបញ្ជូន ភៅ ឲ្យទៅធ្វើការនៅមន្ទីរក-៦ ដែលមានទីតាំងនៅបុរីកីឡា ចំណែកកុមារដទៃទៀតត្រូវទៅធ្វើការនៅរោងចក្រទឹកក្រូចនិងរោងចក្រសាប៊ូ ។ នៅទីនោះ ប្រធានមន្ទីរបានចាត់តាំង ភៅ ឲ្យរៀបចំបាយសម្រាប់ភ្ញៀវដែលអញ្ជើញមកពីគ្រប់ឃុំទាំងអស់នៅក្នុងប្រទេសដែលមានចំនួនសរុបប្រមាណ១,០០០នាក់ ដើម្បីរៀនសូត្រ ។ ពេលធ្វើការ ភៅ ត្រូវស្លៀកពាក់ខោអាវពណ៌ខ្មៅជានិច្ច លើកលែងតែទៅទទួលភ្ញៀវមកពីប្រទេសចិនដែលតម្រូវឲ្យស្លៀកសម្លៀកបំពាក់ពណ៌ និងពាក់ស្បែកជើងក្រវាត់កែង ។ ពេលភ្ញៀវចិនមកដល់ ភៅ ត្រូវគ្រវីផ្កាដែលប្រធានមន្ទីរបានចែកឲ្យ ហើយស្រែកថា «អបអរ តឹង យិនឆាវ» ដែលមកទស្សនកិច្ចនៅស្រុកខ្មែរ ។ ប្រសិនបើមានអ្នកណាម្នាក់ស្រែកខុសពីឃ្លានេះ ប្រធានមន្ទីរក-៦នឹងយកទៅរៀនសូត្រមិនខាន ។


សហករណ៍ដាំស្ល នៅក្នុងសម័យខ្មែរក្រហម

ក្រៅពីរៀបចំអាហារឲ្យភ្ញៀវ ភៅ បានចូលរៀនអំពីបរិស្ថាន និងព្រៃឈើរយៈពេល៩ខែ ។ នៅឆ្នាំ១៩៧៩ ប្រធានមន្ទីរបានបញ្ជូន ភៅ និងនារីជាច្រើននាក់ទៀតឲ្យទៅបាត់ដំបងដោយប្រាប់ថា «អង្គការតម្រូវឲ្យមិត្តទៅច្រូតស្រូវនៅទីនោះមួយសប្តាហ៍ ទើបត្រឡប់មកវិញ» ។ ភៅ ធ្វើដំណើរដោយជិះរទេះភ្លើង ចំណែកអ្នកនៅសេសសល់ត្រូវធ្វើដំណើរដោយថ្មើរជើង ។ ពេលរថភ្លើងចេញផុតពីទីក្រុងភ្នំពេញបានបន្តិច កងទ័ពវៀតណាមបានបាញ់ផ្លោង និងទម្លាក់គ្រាប់ពេញទីក្រុងភ្នំពេញ ។ អ្នកដំណើរក្នុងរថភ្លើងទាំងអស់ភ័យខ្លាចយ៉ាងខ្លាំងដោយសារតែឮសូរសន្ធឹកគ្រាប់ក្នុងក្តាំងទាំងនេះ ហើយមួយចំនួនបានរត់គៀសខ្លួនទៅនៅស្តោ (សព្វថ្ងៃស្ថិតនៅក្នុងខេត្តប៉ៃលិន) ចំណែក ភៅ មិនបានរត់គេចខ្លួនទេ ។ នៅតាមផ្លូវ ភៅ មិនមានអាហារហូបឡើយ ។ ក្រោយមក ភៅ បានជួបជាមួយបុរសបីនាក់ ដែលរត់គេចពីការវាយប្រយុទ្ធគ្នា ហើយក៏បបួលគ្នាវិលត្រឡប់ទៅលាច ខេត្តពោធិ៍សាត់ ហើយក៏បានជួបជាមួយបងប្អូនគាត់វិញ ។

នៅសម័យខ្មែរក្រហម ភៅ ធ្លាប់បានជួប ប៉ុល ពត ប៉ុន្តែគាត់មិនបានដឹងថា ប៉ុល ពត ជាអ្នកណាទេ ។ ភៅ ក៏មិនបានដឹងថា ប៉ុល ពត អាចបញ្ជាឲ្យសម្លាប់មនុស្សអស់ជាច្រើននាក់ដែរ ។ រហូតដល់ឆ្នាំ១៩៧៩ ពេល ភៅ ត្រឡប់មកស្រុកកំណើតវិញ ទើបឃើញគំនរឆ្អឹង និងលលាដ៏ក្បាលជាច្រើននៅតាមផ្លូវ ។

សព្វថ្ងៃនេះ ភៅ ប្រកបមុខរបរធ្វើស្រែ ហើយគាត់ក៏មិនចង់រំឭករឿងរ៉ាវក្នុងរបបខ្មែរក្រហមទៀតដែរ ។ ភៅ ចង់ឲ្យតុលាការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមប៉ុណ្ណោះ ព្រោះគាត់គិតថា ថ្នាក់ក្រោមទទួលបញ្ជាពីថ្នាក់លើតែប៉ុណ្ណោះ ។

**ចាន ផល្លា**

# ជួបប្អូនប្រុសវិញបន្ទាប់ពីបែកគ្នាជាងបីទសវត្សរ៍

ឆ្នាំមុន នាក់ ហោន បានជួបជាមួយ នាក់ ធី ជាប្អូនប្រុសតែម្នាក់គត់ដែលបានបែកគ្នាអស់រយៈពេល៣៦ឆ្នាំមកហើយ ។ ជាទូទៅយុវជនជាច្រើនបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម ដូច្នេះការបាត់ខ្លួនរបស់ នាក់ ធី ដែលបានចូលជាមួយបដិវត្តន៍ខ្មែរក្រហម នៅឆ្នាំ១៩៧៣ បានធ្វើឲ្យមនុស្សជាច្រើនតែងតែយល់ថាគាត់ស្លាប់បាត់ទៅហើយ ។ នាក់ ហោន បានរស់នៅតែម្នាក់ឯងអស់រយៈពេលជាងបីទសវត្សរ៍មកហើយរហូតមកដល់ឆ្នាំ២០០៩ ទើបគាត់រកឃើញ នាក់ ធី វិញ តាមរយៈទំព័រស្វែងរកគ្រួសារ ដែលជាផ្នែកមួយនៅក្នុងទស្សនាវដ្ដីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ការជួបជាមួយគ្នាវិញគឺជារឿងមិនធម្មតាមួយ ។


នាក់ ហោន

នាក់ ហោន បានចងចាំយ៉ាងច្បាស់នូវពេលដែលឪពុកម្ដាយរបស់គាត់ស្លាប់ ។ ម្ដាយរបស់ ហោន បានស្លាប់ដោយសារជំងឺនិងមិនមានថ្នាំព្យាបាល នៅទសវត្សរ៍៧០ ។ ក្រោយមកឪពុករបស់ ហោន ឈ្មោះ សុន យេន បានរៀបការប្រពន្ធថ្មីឈ្មោះ ទូច ។ មិនយូរប៉ុន្មាន គាត់ក៏ត្រូវទាហានវៀតណាមខាងត្បូងធីវគីបាញ់ស្លាប់ ។ ហោន ដែលកើតក្នុងទសវត្សរ៍៥០ នៅស្រុកបន្ទាយមាស ខេត្តកំពត បានរៀបរាប់ពីជីវិតជាក្មេងកំព្រាដ៏លំបាករបស់គាត់ថា «ឪពុកម្ដាយរបស់ខ្ញុំបានស្លាប់នៅពេលដែលខ្ញុំនៅក្មេង ដូច្នេះជីវិតខ្ញុំពិតជាលំបាកវេទនាណាស់» ។ នាក់ ហោន បានបន្តទៀតថា «ពេលវេលាដ៏ឈឺចាប់មួយទៀតរបស់ខ្ញុំគឺនៅពេលដែលឪពុកខ្ញុំស្លាប់» ។ នាក់ ហោន នៅចាំយ៉ាងច្បាស់ថា នៅឆ្នាំ១៩៧៣ នៅពេលដែលទាហានវៀតកុង (រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង) នៅមានសកម្មភាពនៅក្នុងភូមិ កងទ័ពធីវគីតែងតែចូលមកអុកឡុកនៅក្នុងភូមិជានិច្ច ។ ថ្ងៃមួយ ហោន បានឃើញកងទ័ពជាច្រើនចូលមកដល់ក្នុងភូមិ គាត់ក៏ប្រាប់ឪពុកគាត់ថាកុំឲ្យទៅឡើងត្នោត ប៉ុន្ដែឪពុករបស់គាត់នៅតែទៅ ពីព្រោះគាត់បានសន្យានឹងអ្នកភូមិថានឹងយកទឹកត្នោតឲ្យគេនៅថ្ងៃនេះ ។

ឪពុករបស់ ហោន បាននិយាយប្រាប់គាត់ថា «ឪពុកដឹងហើយ កូនឯងទៅឃ្វាលគោទៅ» ។ មួយម៉ោងក្រោយមក ហោន បានឮសំឡេងកាំភ្លើងចេញពីកន្លែងដែលឪពុករបស់គាត់ឡើងត្នោត ។ បន្ទាប់មក ហោន ឮគេនិយាយថា ទាហានធីវគីបានបាញ់វៀតកុងបីនាក់ និងខ្មែរម្នាក់ស្លាប់ ហើយខ្មែរនោះគឺជាឪពុករបស់ ហោន ។ ហោន បាននិយាយថា «ខ្ញុំយំជាខ្លាំងនៅពេលដែលខ្ញុំឮដំណឹងថាឪពុករបស់ខ្ញុំត្រូវធីវគីចាក់នឹងកាំបិតស្លាប់ ហើយវៀតកុងបីនាក់ទៀតត្រូវទាហានធីវគីខ្វេះប្រមាត់ចេញមកក្រៅ» ។

បន្ទាប់ពីឪពុករបស់ ហោន ស្លាប់ សោម ហេង ដែលជាមីងបានមកចិញ្ចឹមបីបាច់ថែរក្សា ហោន និង ធី ។ ប៉ុន្ដែអ្នកទាំងបីនៅតែមិនអាចរស់នៅដោយមានសេចក្ដីសុខឡើយ ពីព្រោះនៅក្នុងភូមិតែងតែមានការប្រទាញប្រទង់គ្នាជានិច្ចដូចជា វាយគ្នា និងបាញ់គ្នាដែលធ្វើឲ្យអ្នកទាំងបីត្រូវផ្លាស់ប្ដូរទីលំនៅជាច្រើនលើកច្រើនសា ។ ប៉ុន្មានខែក្រោយមក មីងរបស់ អ៊ុន ពៅ ដែលជាឆ្មបឃុំនៅស្រុកកំពង់ត្រាចបានមកយកប្អូនរបស់ ហោន ទៅរស់នៅជាមួយ ។ គាត់បានប្រាប់ ហោន ថាគាត់នឹងចិញ្ចឹម ធី ហើយនិងបញ្ជូនទៅរៀនសូត្រទៀត ។ ដោយ ហោន មិនដែលបានទៅរៀននិងមិនចេះអក្សរ គាត់ក៏យល់ព្រមឲ្យ ធី ចាកចេញពីគាត់ ។ ចាប់ពីពេលនោះមក ហោន មិនដែលបានឮដំណឹងអ្វីពី ធី ទៀតទេ ។

នៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានឡើងកាន់អំណាចនិងគ្រប់គ្រងប្រទេសទាំងមូល ។ នៅពេលនោះ ហោន ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅកងចល័តស្រុកទូកមាស ។ ដំបូង អង្គការបានចាត់តាំងឲ្យ ហោន ទៅលើកដីដំបូកយកទៅចាក់នៅវាលស្រែ

និងធ្វើការបន្ទាប់បន្សំជាច្រើនផ្សេងទៀត។ ក្រោយមក អង្គការបានឲ្យ ហោន ទៅធ្វើខាងសេដ្ឋកិច្ច ដូចជារកក្តាម ខ្យង និងត្រី មកដាំស្ល នៅសហករណ៍។ រហូតដល់ឆ្នាំ១៩៧៩ នៅពេលដែលរបបខ្មែរក្រហមដួលរលំ ហោន បានទៅរស់នៅក្នុងភូមិកំណើតជាមួយឪពុកមាដោយសង្ឃឹមថា ធី ដែលជាប្អូនប្រុសនឹងមករកគាត់។ ប៉ុន្តែ ហោន មិនដែលបានឮដំណឹងអ្វីពី ធី សោះ។


នាក់ ធី

រហូតដល់ឆ្នាំ២០០៨ នៅពេលដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មកដល់ខេត្តកំពត ហោន បានស្នើឲ្យក្រុមការងារជួយចេញផ្សាយអត្ថបទស្វែងរកប្អូននៅក្នុងទំព័រស្វែងរកគ្រួសាររបស់ទស្សនាវដ្តីស្វែងរកការពិត។

ប៉ុន្មានខែក្រោយមក នាក់ ធី ដែលបច្ចុប្បន្នរស់នៅខេត្តពោធិ៍សាត់ និងបានប្តូរឈ្មោះទៅជា ភោគ កុសល្យ បានឃើញអត្ថបទស្វែងរកប្អូនប្រុសរបស់ ហោន នៅក្នុងទស្សនាវដ្តីស្វែងរកការពិត លេខ១០៨ ខែធ្នូ ឆ្នាំ២០០៨ នៅក្នុងសាលាឃុំ។ នាក់ ធី បានទូរស័ព្ទទៅតាមលេខដែលចុះផ្សាយនៅក្នុងទស្សនាវដ្តី ហើយក៏បានជួបនិយាយជាមួយ មិន ឈុំ ដែលជាមេភូមិ។ ធី បានសួរសំណួរជាច្រើនទាក់ទងនឹង ហោន។ មិន ឈុំ បាននិយាយថា «ដំបូង ធី មិនសូវជាជឿថា ហោន ពិតជាបងស្រីរបស់គាត់ឡើយ ហើយ ហោន ក៏ដូច្នោះដែរ។ ក្រោយមកខ្ញុំក៏សម្រេចចិត្ត ជូន ហោន ទៅជួបជាមួយ ធី នៅពោធិ៍សាត់»។ នៅពេលនោះ ហោន ជឿថា ធី ពិតជាប្អូនដែលបានបែកគ្នាតាំងពីឆ្នាំ១៩៧៣មម្ល៉េះ។ ហោន បាននិយាយថា «ខ្ញុំមានអារម្មណ៍សប្បាយចិត្តណាស់នៅពេលដែលខ្ញុំឮដំណឹងពី ធី។ ខ្ញុំជឿជាក់ថា ធី គឺជាប្អូនប្រុសរបស់ខ្ញុំ ពីព្រោះរូបរាង ជាពិសេសមាត់របស់ ធី ដូចនឹងឪពុកខ្ញុំណាស់»។ ហោន បន្តទៀតថា «ខ្ញុំមានសេចក្តីសប្បាយរីករាយក្រៃលែងដែលបានជួបជាមួយ ធី វិញបន្ទាប់ពីបែកគ្នា៣៦ឆ្នាំ»។

**ថា ផល្លា**



# អ្នកដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម

តុលាការខ្មែរក្រហមបានបង្កើតឡើងរយៈពេលបួនឆ្នាំមកហើយ ដែលរហូតមកដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០នេះ ឌុច អតីតប្រធានមន្ទីរ (ស-២១) ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ដោយដក១១ឆ្នាំសម្រាប់អំឡុងពេលដែលបានឃុំខ្លួនគាត់រួចហើយ និង៥ឆ្នាំទៀតសម្រាប់ការឃុំខ្លួនមិនស្របច្បាប់ ។ នៅដើមឆ្នាំ២០១១ ខាងមុខនេះ តុលាការនឹងធ្វើការកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបួនរូបទៀតគឺ អៀង សារី, ខៀវ សំផន, នួន ជា និង អៀង ធីរិទ្ធ ដែលរហូត មកដល់ពេលនេះ មានអ្នកដាក់ពាក្យបណ្តឹងត្រូវបានទទួលស្គាល់ចំនួន ២១២៣នាក់ ។

ប្រាក់ ស៊ីណាន អាយុ៥៥ឆ្នាំ ជាកសិកររស់នៅឃុំល្អាង ស្រុកដងទង់ ខេត្តកំពត បានរៀបរាប់ថា «ពួកខ្ញុំដាក់ពាក្យបណ្តឹងទៅតុលាការដោយគ្មានបាតដៃប្រឡាក់ឈាមទេ ប៉ុន្តែអ្នកដែលមានបាតដៃប្រឡាក់ឈាមមិនចង់ដាក់បណ្តឹងជាមួយខ្ញុំទេ ។ ខ្ញុំយល់ថា អ្នកមានបាតដៃប្រឡាក់ឈាមក៏ជាជនរងគ្រោះដែរ ប៉ុន្តែគេបែរជាមិនចង់ដាក់ពាក្យបណ្តឹងទៅវិញ ។ ចំណែកខ្ញុំដែលតស៊ូដាក់ពាក្យបណ្តឹងទៅតុលាការនេះគឺជាការរួមចំណែកជាមួយតុលាការ ប៉ុន្តែចំពោះតុលាការហាក់ដូចជាធុញថប់នឹងពួកខ្ញុំដែលដាក់ពាក្យបណ្តឹងទាមទារសំណងជាសមូហភាព និងគិតថាដើមបណ្តឹងរដ្ឋប្បវេណីជាមនុស្សធម្មតា ។ ចំណែកអ្នកធ្លាប់បម្រើឲ្យមេដឹកនាំខ្មែរក្រហមដែលធ្លាប់ប្រព្រឹត្តអាក្រក់ក៏មិនពេញចិត្តនិងស្អប់ខ្ញុំដែរ ព្រោះខ្ញុំបានតតាំងជាមួយគេ» ។

ស៊ីណាន បានរៀបរាប់ពីប្រវត្តិផ្ទាល់ខ្លួនរបស់គាត់ថា ៖ នៅក្នុងសម័យខ្មែរក្រហម គ្រួសារខ្ញុំមានសមាជិកប្រាំពីរនាក់ ប៉ុន្តែក្រោយរបបខ្មែរក្រហមដួលរលំនៅសល់តែខ្ញុំនិងម្តាយខ្ញុំប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧២ ខ្មែរក្រហមបានយកខ្ញុំទៅរៀនវាយអង្គុលីលេខនៅបុស្សតាជង់ ក្នុងស្រុកជុំគិរី ខេត្តកំពត ។ ក្រោយពីរៀនចេះស្ទាត់ហើយ ខ្ញុំរៀបចំវាយឯកសារដែលនិយាយពី «ការជិះជាន់របស់ពួកសក្តិភូមិនាយទុន» ដើម្បីយកទៅចែកឲ្យប្រជាជន ។ នៅកន្លែងរៀបចំឯកសារបានមួយឆ្នាំ ខ្មែរក្រហមបានដកខ្ញុំមកឃ្វាលគោនៅកំពង់ទ្រារហូតដល់ឆ្នាំ១៩៧៤ ទើបខ្ញុំរៀនត្បាញ ។

ក្រោយរំដោះឆ្នាំ១៩៧៥ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅដេរខោអាវសម្រាប់យោធានៅខេត្តកំពតរហូតដល់ឆ្នាំ១៩៧៧ ទើបដកខ្ញុំឲ្យមកធ្វើស្រែអំបិលវិញ ។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានរៀបចំឲ្យខ្ញុំមានប្តីដោយមិនបានប្រាប់ឲ្យដឹងមុនឡើយ ព្រោះពេលខ្ញុំកំពុងលើកភ្លឺស្រែ អង្គការប្រាប់ឲ្យខ្ញុំឡើងទៅប្រជុំ ។ ព្រដូច្នេះ ខ្ញុំនិងស្រីៗក្នុងកងក៏នាំគ្នាទៅ ។ ស្រាប់តែទៅដល់កន្លែងប្រជុំ អង្គការហៅឈ្មោះខ្ញុំនិងនារីផ្សេងទៀតឲ្យចូលអង្គុយនៅក្រោមម្លប់ដើមស្វាយមួយកន្លែង បន្ទាប់មកហៅឈ្មោះប្រុសម្តងដែលសរុបទាំងអស់ចំនួន៣៨គូ ។ នៅខណៈនោះ អង្គការក៏ប្រកាសថា «ថ្ងៃនេះជាថ្ងៃរៀបអាពាហ៍ពិពាហ៍» ទើបខ្ញុំភ្ញាក់ខ្លួនថា អង្គការឲ្យខ្ញុំយកប្តីឈ្មោះ សាន ជាយុទ្ធជនពិការដៃម្ខាង ប៉ុន្តែខ្ញុំក៏មិនហ៊ានប្រកែកតវ៉ានឹងការរៀបចំនេះដែរ ។ នៅយប់ថ្ងៃនោះ ខ្ញុំបាននិយាយជាមួយប្តីថា «យើងកុំរស់នៅជាមួយគ្នា ព្រោះខ្ញុំធ្វើការនៅកងចល័តមិនមានលទ្ធភាពចិញ្ចឹមកូនទេ» ប៉ុន្តែខ្ញុំបានសន្យាជាមួយប្តីខ្ញុំថា «ប្រសិនបើស្រុកបានសាន្តត្រាណ សូមឲ្យគាត់មករកខ្ញុំនៅស្រុកកំណើត» ។ ក្រោយពីស្តាប់ខ្ញុំនិយាយរួច ប្តីខ្ញុំក៏ដកកាំភ្លើងខ្លីមកគំរាម និងវាយក្បាលខ្ញុំដែលនៅមានស្លាកស្នាមមកទល់សព្វថ្ងៃនេះ រួចហើយគាត់ចេញទៅបាត់រហូត ។ ក្រោយមក ខ្ញុំក៏មកធ្វើការងារនៅកងចល័តស្វាយធំ ។ ថ្ងៃមួយ ពេលខ្ញុំកំពុងបោកស្រូវនៅជិតចំណតរថភ្លើង ស្រាប់តែកងទ័ពវៀតណាមវាយចូលមកដល់ ហើយខ្ញុំក៏រត់គេចខ្លួនមួយរយៈទើបត្រឡប់មកភូមិកំណើតវិញ ។

ដោយសារតែកុំឲ្យខុសពាក្យសន្យាដែលបាននិយាយជាមួយប្តី ខ្ញុំក៏បានចាំគាត់ត្រឡប់មករកខ្ញុំវិញដែរ ។ ប៉ុន្តែដោយសារតែនៅតែគ្មានដំណឹងពីគាត់សោះ ទើបខ្ញុំដាច់ចិត្តរៀបការជាមួយប្តីក្រោយជាអតីតភារធារីប្រចាំនៅប្រទេសអាហ្វ្រិកខាងត្បូងតាមរយៈក្រុមគ្រួសារផ្សំផ្គុំឲ្យ ។ ពេលនោះ ខ្ញុំក៏បានយករឿងដែលខ្ញុំរៀបការរួចទៅប្រាប់ប្តីរបស់ខ្ញុំឲ្យដឹងដែរ ហើយគាត់មិនប្រកាន់នឹងខ្ញុំទេ ។ ឥឡូវនេះ ខ្ញុំបានរស់នៅយ៉ាងមានសុភមង្គលជាមួយប្តីក្រោយនេះ ។

**គាត លក្ខិណា**

# ការនិយាយផ្ទាល់មាត់
# និងការអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យជាស្ពានផ្សះផ្សា

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ របបនេះបានបន្សល់ទុកនូវកេរដំណែលបែកបាក់គ្រួសារ និងភាពខ្ទេចខ្ទាំនៅក្នុងសង្គមជាតិទាំងមូល ។ ប្រជាពលរដ្ឋបានក្រោកឈរឡើងយ៉ាងលំបាកដើម្បីតស៊ូចិញ្ចឹមជីវិត និងប្រយុទ្ធប្រឆាំងជាមួយនឹងភាពឈឺចាប់ទាំងអស់នោះ ។ ប្រជាជនខ្មែរគ្រប់រូបគ្មាននរណាម្នាក់អាចរួចផុតពីការបាត់បង់សាច់ញាតិដូចជាឪពុកម្តាយ បងប្អូន និងកូនជាទីស្រឡាញ់របស់ខ្លួនឡើយ ។ មិនតែប៉ុណ្ណោះ អ្នកនៅរស់រានមានជីវិតបានរង់ចាំយុត្តិធម៌តាមផ្លូវតុលាការអស់រយៈពេលជាង៣០ឆ្នាំមកហើយ មុនពេលមានការបង្កើតតុលាការខ្មែរក្រហមនេះទៅទៀត ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ។ នៅពេលនោះ អ្នករស់រានមានជីវិតទាំងនោះខំព្យាយាមចែករំលែករឿងរ៉ាវដ៏ឈឺចាប់នេះទៅឲ្យអ្នកជំនាន់ក្រោយក្នុងក្តីសង្ឃឹមថានឹងបានធូរស្រាលក្នុងចិត្តខ្លះ ។ ប៉ុន្តែកូនចៅរបស់គាត់មួយចំនួនគិតថា រឿងនេះជារឿងមិនពិត ហើយពេលខ្លះចាត់ទុកជាការសើចសប្បាយទៅវិញ ។




លោកពូ អ៊ឹ វ៉ា មានវ័យ ៦៥ឆ្នាំ រស់នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ បានរៀបរាប់ឲ្យដឹងថា គាត់ធ្លាប់និយាយប្រាប់កូនចៅរបស់គាត់ថាក្នុងរបបខ្មែរក្រហម ជីវិតរបស់គាត់មានការលំបាកខ្លាំងណាស់ ព្រោះត្រូវបានបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ចំណែកការហូបចុកវិញគឺមិនគ្រប់គ្រាន់ឡើយ ប៉ុន្តែកូនៗរបស់គាត់បែរជាមិនជឿ ហើយថែមទាំងនិយាយថា «ហេតុអ្វីបានជាមិនព្រមក្រោកឈរតតាំងនឹងខ្មែរក្រហមវិញ ព្រោះយើងមានគ្នាច្រើនបែរជាបណ្តោយឲ្យខ្មែរក្រហមសម្លាប់ធ្វើទារុណកម្ម និងបង្អត់អាហារបែបនេះទៅវិញ?» ។

អ៊ឹ វ៉ា មានអារម្មណ៍រឹតតែឈឺចាប់ និងគិតថាខ្លួនរបស់គាត់កាន់តែមានកំហុសខ្លាំងឡើងប្រៀបដូចជាគាត់កំពុងតែបង្កើតរឿងរ៉ាវបំផ្លើសការពិត ។ ដូច្នេះ អ៊ឹតែងតែលាក់ទុករឿងរ៉ាវដ៏ឈឺចាប់នេះតែម្នាក់ឯង ។ អ៊ឹ វ៉ា មានសេចក្តីសប្បាយរីករាយណាស់ចំពោះកម្មវិធីបណ្តុះបណ្តាលពីរបបខ្មែរក្រហម ពីព្រោះរឿងរ៉ាវរបស់គាត់កំពុងត្រូវបានគេយកចិត្តទុកដាក់និងទទួលស្គាល់នូវអ្វីដែលកើតឡើងនៅក្នុងសម័យបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ។ ម្យ៉ាងទៀត កម្មវិធីអប់រំនេះនឹងជួយបកស្រាយ និងពន្យល់ក្មេងជំនាន់ក្រោយឲ្យយល់ពីហេតុការណ៍ពិតនាសម័យនោះ ។ ប៉ុន្តែ នេះមិនមានន័យថា គាត់មានអារម្មណ៍អវិជ្ជមានជាមួយនឹងអតីតកម្មាភិបាលជំនាន់នោះទេ ។ នៅពេលសួរថាតើគាត់ចងគំនុំនឹងជនដៃដល់ឬទេ? និងថាតើគាត់បង្រៀនកូនចៅរបស់គាត់ឲ្យស្អប់ខ្ពើម និងកាត់ផ្តាច់ទំនាក់ទំនងមិត្តភាពចំពោះកូនជនដៃដល់ដែរឬទេ? អ៊ឹ វ៉ា ឆ្លើយថា រឿងអតីតកាលបានកន្លងផុតទៅហើយ ក្មេងជំនាន់ក្រោយប្រៀបដូចជាក្រដាស-សស្អាត មិនដែលបានដឹងនូវអំពើព្រៃផ្សៃរបស់ឪពុកម្តាយគេទេ ថែមទាំងមិនដែលបានប្រព្រឹត្តតាមគន្លងឪពុកម្តាយរបស់គេដែរ ។ ដូច្នេះ «រឿងរបស់ឪពុកគឺរឿងរបស់ឪពុករឿងរបស់កូន គឺរឿងរបស់កូន» ។ វ៉ា មិនដែលគិតថានឹងបង្រៀនកូនចៅរបស់គាត់ឲ្យរើសអើងចំពោះកូនជនដៃដល់នោះទេ ។ ផ្ទុយទៅវិញ គាត់នឹងបង្រៀនកូនរបស់គាត់ឲ្យចេះស្រឡាញ់រាប់អាន និងចេះជួយគ្នាទៅវិញទៅមក ព្រោះការគុំកួន និងការសងសឹក វាមិនចេះចប់ មិនចេះហើយនោះទេ ។ វ៉ា គិតថា ប្រសិនបើនៅតែចងកំហឹងនឹងគ្នាតទៅទៀត តើពេលណាទើបចប់សង្គ្រាម ហើយសង្គមនឹងកាន់តែវឹកវរមិនអាចរកសន្តិភាពបានទេ ។ កិច្ចការដ៏សំខាន់នោះគឺត្រូវប្រើប្រាស់ការអប់រំដើម្បីបណ្តុះការយល់ដឹងដល់មនុស្សជំនាន់ក្រោយក្នុងការទប់ស្កាត់អំពើឃោរឃៅនេះមិនឲ្យកើតមានឡើងម្តងទៀត ។

ចំណែក ទុយ សាវី អាយុ២០ឆ្នាំ រស់នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ បានរៀបរាប់ពីការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការ

បណ្តុះបណ្តាលអំពី «របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ពីព្រោះកម្មវិធីនេះធ្វើឲ្យក្មេងជំនាន់ក្រោយបានដឹងពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ជាពិសេសការសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃរបស់មេដឹកនាំខ្មែរក្រហម ។ ទោះបីជា សារី កើតមិនទាន់របបខ្មែរក្រហមក៏ដោយ ក៏ប៉ុន្តែតាមរយៈភស្តុតាងដែលបានបន្សល់ទុក និងការរៀបរាប់របស់ឪពុកម្តាយ សារី ពិតជាជឿថារបបនេះបានសម្លាប់មនុស្សដោយគ្មានការវិនិច្ឆ័យទោសមែន ហើយថែមទាំងមិនអាចឲ្យមេដឹកនាំខ្មែរក្រហមប្រកែកបានឡើយ ។ ដូច្នេះហើយ សារី មានការសប្បាយរីករាយបំផុតចំពោះការបង្រៀនជាផ្លូវការអំពីរបបនេះ និងចង់ឲ្យមានការផ្សព្វផ្សាយឲ្យបានកាន់តែច្រើនតាមរយៈទូរទស្សន៍ ទស្សនាវដ្តី និងការអប់រំនៅតាមបណ្តាគ្រឹះស្ថានសិក្សានានាដើម្បីឲ្យយុវជននិងយុវនារីជំនាន់ក្រោយបានដឹងនិងទទួលស្គាល់ថាពិតជាមានរបបឃោរឃៅកើតឡើងប្រាកដមែន ។ សារី បន្តថា ទោះបីជាថ្ងៃក្រោយគាត់បានដឹងថា មិត្តភក្តិរបស់គាត់ជាកូនជនដៃដល់ដែលបានធ្វើឲ្យជីវិតម្តាយគាត់មានការលំបាកក៏ដោយ ក៏គាត់ប្តេជ្ញាចិត្តថាមិនស្អប់ខ្ពើម ឬចងគំនុំជាមួយនឹងមិត្តភក្តិរបស់គាត់នោះទេ ។ ផ្ទុយទៅវិញ គាត់នឹងស្រឡាញ់រាប់អានឲ្យដូចជាមិត្តភក្តិដទៃទៀតដែរ ។ សារី បន្ថែមទៀតថា ការចងគំនុំនិងគុំកួនគ្នាមានតែធ្វើឲ្យសង្គមកាន់តែបែកបាក់ប៉ុណ្ណោះនិងមិនអាចធ្វើប្រទេសមានសុខសន្តិភាពបានឡើយ ។




ទោះបីជាការចែករំលែកប្រវត្តិរឿងរ៉ាវរបស់ឪពុកម្តាយមកឲ្យកូនមានសារសំខាន់ ប៉ុន្តែការពន្យល់ណែនាំបន្ថែមពីសំណាក់លោកគ្រូ-អ្នកគ្រូក៏ជាចំណុចស្នូលមួយដើម្បីធ្វើឲ្យកិច្ចការនេះកាន់តែមានជោគជ័យផងដែរ ។




លោកគ្រូ ឃឹម វន សព្វថ្ងៃរស់នៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ក៏បានចែករំលែកនូវការយល់ដឹងស្រដៀងគ្នានៅនឹង លោកគ្រូ អ៊ឹង រ៉ា និង ទុយ សារី ដែរ ។ វន បានរៀបរាប់ថា គាត់ពិតជាសប្បាយរីករាយណាស់ដែលបានចូលរួមដោយផ្ទាល់នៅក្នុងវគ្គបណ្តុះបណ្តាលអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានការសហការពីក្រសួងអប់រំ យុវជន និង កីឡា ។ វន ក៏បានបន្ថែមថា គាត់ពេញចិត្តជាខ្លាំងចំពោះកម្មវិធីសិក្សានេះ ព្រោះគាត់អាចយករឿងអតីតកាលពីរបបខ្មែរក្រហមប្រាប់ឲ្យក្មេងជំនាន់ក្រោយបានដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួននិងត្រូវរកវិធីទប់ស្កាត់កុំឲ្យរបបនេះកើតឡើងជាលើកទីពីរទៀត ។ នៅពេលដែលសួរថាតើគាត់នឹងអត់ឱនឲ្យមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងកម្មាភិបាលថ្នាក់ក្រោមដែរឬទេ? គាត់បានរៀបរាប់ឲ្យដឹងថា គាត់ព្រមលើកលែងទោសឲ្យកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ព្រោះអ្នកទាំងនេះទទួលបញ្ជាពីថ្នាក់លើតែប៉ុណ្ណោះ ហើយបើអ្នកទាំងនេះមិនធ្វើតាមបញ្ជានេះ អង្គការនឹងយកទៅសម្លាប់ជាមិនខាន ។ ចំណែកមេដឹកនាំជាន់ខ្ពស់ គឺគាត់មិនអាចអត់ឱនទោសឲ្យទេ ព្រោះថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងនេះជាអ្នកដឹកនាំប្រទេសឈានទៅរកភាពមហន្តរាយ ។ ដូច្នេះ មេដឹកនាំទាំងនេះគួរតែទទួលការកាត់ទោសចំពោះបទឧក្រិដ្ឋទៅតាមផ្លូវច្បាប់ដែលបានប្រព្រឹត្ត ។

លោកគ្រូ ឃឹម វន បានបន្តថា គាត់នឹងអប់រំក្មេងជំនាន់ក្រោយកុំឲ្យចងគំនុំនឹងគ្នា ឲ្យចេះស្រឡាញ់គ្នា មិនត្រូវរើសអើងឬសងសឹកចំពោះកូនជនដៃដល់ទេព្រោះយើងជាជាតិសាសន៍ដូចគ្នា ។

ដូច្នេះ ការរួមគ្នានៅក្នុងការនិទានប្រាប់ពីសំណាក់ឪពុកម្តាយ និងការបង្រៀនរបស់លោកគ្រូ-លោកគ្រូនៅតាមសាលារៀន គឺជាការរួមចំណែកដ៏មានតម្លៃដែលមិនអាចកាត់ថ្លៃបាន ដើម្បីនាំឆ្ពោះទៅរកការផ្សះផ្សាជាតិបន្ថែមមួយកម្រិតទៀត ។ ចំណែកការស្អប់ខ្ពើម ការចងគំនុំ និងការសងសឹក គឺមិនមែនជាដំណោះស្រាយ ឬការរំសាយកំហឹងទេ ព្រោះមិនអាចធ្វើឲ្យអ្នកដែលស្លាប់មានជីវិតរស់ឡើងវិញបានទេ ថែមទាំងអាចបង្កឲ្យមានអស្ថិរភាពក្នុងសង្គមទៀតផង ។

**លី សុខចំរើន**

# ការចោទប្រកាន់អំពីការអនុវត្តផ្នែកសុខាភិបាលរបស់ខ្មែរក្រហមថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

## ១) *សេចក្តីផ្តើម*

បក្សកុម្មុយនីស្តកម្ពុជាដែលស្គាល់ថាជាខ្មែរក្រហមបានឡើងកាន់អំណាចនៅកម្ពុជានៅឆ្នាំ១៩៧៥ ក្នុងគោលបំណងចាប់ផ្តើមបង្កើតដំណើរការ «បដិវត្តន៍ជាតិប្រជាធិបតេយ្យ» និង «រំដោះប្រជាជាតិកម្ពុជា និងវណ្ណៈកសិករក្រីក្រ» ពីរបបចក្រពត្តិនិយមរបស់អាមេរិក និងរបបសក្តិភូមិ ។ បដិវត្តន៍សង្គមដ៏បរិសុទ្ធពឹងផ្អែកទៅលើយុត្តិសាស្ត្រមូលដ្ឋានបីគឺឯករាជភាព អធិបតេយ្យភាព និងការពឹងផ្អែកលើខ្លួនឯង ដែលយុត្តិសាស្ត្រទាំងនេះអាចសម្រេចទៅបានអាស្រ័យទៅលើការរើបម្រះចេញពីខ្សែសង្វាក់នៃរបបកុម្មុយនីស្ត និងចាប់ផ្តើមជីវិតថ្មីពី «ឆ្នាំសូន្យ» ។ ចាប់តាំងពីការចាប់ផ្តើមរបបខ្មែរក្រហមបានអនុវត្តគោលនយោបាយសង្គមនិយមដ៏តឹងរ៉ឹង ដែលមានគោលបំណងចង់រៀបចំសង្គមកម្ពុជាសាជាថ្មី ។ គណៈមជ្ឈិមបក្សដែលស្គាល់ថាជា «អង្គការ» ជឿថា «បក្សដែលអាចដឹកនាំបដិវត្តន៍ត្រូវតែជាបក្សនៃវណ្ណៈកសិករ» ។ ជាលទ្ធផលត្រូវតែមានការលុបបំបាត់និងផ្លាស់ប្តូរបញ្ញវន្ត និងអភិជនកម្ពុជាដែលមានការបណ្តុះបណ្តាលផ្នែកជំនាញវេជ្ជសាស្ត្រ ច្បាប់ និងហិរញ្ញវត្ថុ ដោយយកជនបដិវត្តន៍ដែលមានប្រភពពីវណ្ណៈកសិករមកជំនួសវិញ ។ បន្ទាប់មក ប្រជាជនត្រូវបានបែងចែកជាពីរក្រុមគឺៈ «ប្រជាជនចាស់» និង «ប្រជាជនថ្មី» ។ «ប្រជាជនចាស់» ឬ «ប្រជាជនមូលដ្ឋាន» គឺជាអ្នកដែលធ្លាប់រស់នៅក្នុងតំបន់ដែលខ្មែរក្រហមគ្រប់គ្រងនៅក្នុងអំឡុងពេលសង្គ្រាម ដូច្នេះអ្នកទាំងនោះត្រូវបានរដ្ឋាភិបាលខ្មែរក្រហមពេញចិត្ត រីឯ «ប្រជាជនថ្មី» ឬ «ប្រជាជន១៧មេសា» គឺជាអ្នកដែលធ្លាប់រស់នៅទីក្រុងនិងត្រូវបាន «រំដោះ» ពីចំណងរបស់បស្ចិមប្រទេសដោយការចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របស់យោធាខ្មែរក្រហម ។ ដោយសង្កត់ធ្ងន់ទៅលើឯករាជភាព និងម្ចាស់ការ ដែលមិនទទួលរងឥទ្ធិពលបរទេស ខ្មែរក្រហមបានលុបបំបាត់បច្ចេកទេសទំនើបការប្រើប្រាស់គ្រឿងម៉ាស៊ីន ការអប់រំ និងប្រព័ន្ធសុខាភិបាលដើម្បីប្រែក្លាយប្រទេសឲ្យទៅជាសង្គមកសិកម្មដែលពឹងផ្អែកទៅលើកម្លាំងពលកម្មរបស់ប្រជាជន ។

ឥទ្ធិពលនៃការលុបបំបាត់ដើម្បីជំរុញឲ្យមានអង្គការ «មហាលោតផ្លោះ មហាអស្ចារ្យ» របស់ខ្មែរក្រហមបានដក់ជាប់ក្នុងវិស័យសុខាភិបាលរបស់កម្ពុជាដែលត្រូវបានបំផ្លិចបំផ្លាញដោយគោលនយោបាយរបស់របបនេះតាមវិធីពីរយ៉ាង ។ ទីមួយ មិនអនុញ្ញាតឲ្យប្រើប្រាស់ឧបករណ៍ព្យាបាលតាមវិធីបស្ចិមប្រទេស និងថ្នាំវិទ្យាសាស្ត្រឡើយ ។ មន្ទីរពេទ្យត្រូវបានខ្មែរក្រហមយកឧបករណ៍ព្យាបាលចេញ និងបិទទ្វារ ។ បុគ្គលិកមន្ទីរពេទ្យដែលបានទទួលការបណ្តុះបណ្តាលត្រូវបានយកទៅសម្លាប់ ឬជម្លៀសទៅជនបទដើម្បីធ្វើការងារកសិកម្ម ។ ពេទ្យក្មេងៗដែលភាគច្រើនក្នុងចំណោមអ្នកទាំងនោះ គឺជាអ្នកដែលមិនចេះអក្សរ និងមិនដែលទទួលបានការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រ ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកថែទាំសុខភាពជំនួសវេជ្ជបណ្ឌិត និងគិលានុបដ្ឋាក ។ ការប្រើប្រាស់ការព្យាបាលតាមបែបវិទ្យាសាស្ត្រត្រូវបានហាមឃាត់ពីព្រោះវិធីនេះត្រូវចាត់ទុកថាមានកំណើតនៅបស្ចិមប្រទេស ដូច្នេះវាផ្ទុយពីគោលនយោបាយដែលថាត្រូវពឹងផ្អែកទៅលើខ្លួនឯងរបស់ខ្មែរក្រហម ។ ប៉ុន្តែ ពេទ្យក្មេងៗបានផលិតថ្នាំដោយខ្លួនឯងចេញពីរុក្ខជាតិនិងសារធាតុធម្មជាតិផ្សេងទៀត ។ ខ្មែរក្រហមបានបដិសេធមិនទទួលជំនួយជាថ្នាំពេទ្យ និងស្បៀងអាហារពីអង្គការអន្តរជាតិ និងរដ្ឋាភិបាលបរទេសឡើយពីព្រោះ «ខ្មែរក្រហមជឿស៊ប់លើទស្សនៈឯករាជ្យម្ចាស់ការ ហើយគិតថាអ្នកដែលចង់ផ្តល់ជំនួយគឺចង់ប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីគ្រប់គ្រង និងបំផ្លាញប្រទេសកម្ពុជាតែប៉ុណ្ណោះ» ។

ទីពីរ អ្នកដឹកនាំរបស់ខ្មែរក្រហមបានប្រើប្រាស់ការពិសោធន៍ផ្នែកវេជ្ជសាស្ត្រទៅលើអ្នកជំងឺ ដែលបណ្តាលឲ្យមនុស្សស្លាប់ជាច្រើននាក់ ។ ការប្រើប្រាស់ថ្នាំដែលផលិតនៅក្នុងស្រុកដើម្បីព្យាបាលជំងឺ និងរបួសទូទៅ គឺជាការពិសោធន៍ដោយខ្លួនឯង

ពីព្រោះសារធាតុផ្សំថ្នាំទាំងអស់មិនត្រូវបានយកមកពិសោធតាមបែបវិទ្យាសាស្ត្រ ហើយមិនមានការត្រួតពិនិត្យលើការប្រើប្រាស់ថ្នាំត្រឹមត្រូវទេ ។ កម្មាភិបាលខ្មែរក្រហមក៏បានបញ្ជាឲ្យពេទ្យក្មេងៗធ្វើការពិសោធទៅលើអ្នកជំងឺដែលបានស្ម័គ្រចិត្ត ដើម្បីសិក្សាទៅលើសារពាង្គកាយរបស់មនុស្ស និងដកសរីរាង្គខ្លះចេញពីរាងកាយរបស់ខ្លួនសម្រាប់ធ្វើថ្នាំ ។ នៅទីបញ្ចប់ការពិសោធផ្នែកវេជ្ជសាស្ត្រត្រូវបានធ្វើឡើងទៅលើអ្នកទោសខ្មែរក្រហមដែលជាប់នៅមន្ទីរឃុំឃាំង តាមរយៈការធ្វើទារុណកម្ម និងការបូមឈាមចេញពីអ្នកទោសសម្រាប់យកទៅព្យាបាលឲ្យយោធាខ្មែរក្រហម ។

អ្នកដែលទទួលរងគ្រោះខ្លាំងជាងគេបំផុតដោយប្រព័ន្ធសុខាភិបាលនៅកម្ពុជា គឺប្រជាជនទូទៅ ហើយខ្មែរក្រហមយកអ្នកនោះជាការពិសោធដើម្បីកសាងបដិវត្តន៍របស់ខ្លួន ។ ប្រជាជនប្រមាណពីរលាននាក់ ដែលស្មើនឹងមួយភាគបីនៃប្រជាជនកម្ពុជាបានស្លាប់នៅក្នុងរបបខ្មែរក្រហម (ខែមេសា ១៩៧៥ ដល់ខែមករា ១៩៧៩) ។ ប្រជាជនកម្ពុជាពីប្រាំសែនទៅមួយលាននាក់ត្រូវគេជឿជាក់ថាត្រូវបានគេយកទៅសម្លាប់ រីឯអ្នកផ្សេងទៀតស្លាប់ដោយសារភាពអត់ឃ្លាន ជំងឺនិងគោលនយោបាយវេជ្ជសាស្ត្រនិងការអនុវត្តរបស់ខ្មែរក្រហម ។

ការលុបបំបាត់សេវាកម្មថែទាំសុខភាព និងបទពិសោធន៍វេជ្ជសាស្ត្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមែនជាលទ្ធផលធ្វើឡើងភ្លាមៗស្របពេលដែលប្រទេសកំពុងជួបចលាចលសង្រ្គាមស៊ីវិលនោះទេ ។ កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់បានអនុវត្តគោលនយោបាយវេជ្ជសាស្ត្រទាំងនេះទុកជាយុត្តិសាស្ត្រមួយដើម្បីធ្វើឲ្យកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈឯករាជ្យម្ចាស់ការ ។ ប៉ុល ពត មេដឹកនាំខ្ពស់បំផុតនៅក្នុងរបបខ្មែរក្រហមបានអនុម័តឲ្យប្រើប្រាស់ថ្នាំដែលផលិតក្នុងស្រុកជាជាងថ្នាំដែលមានការពិសោធតាមបែបវិទ្យាសាស្ត្រ ដោយនិយាយថា «យើងត្រូវតែបង្កើតក្រុមស្រាវជ្រាវ និងដឹកនាំការពិសោធទៅលើថ្នាំបុរាណ ។ ទោះបីជាយើងមិនមានរូបមន្តច្បាស់លាស់ក៏ដោយ ក៏យើងនៅតែអាចផលិតថ្នាំបានដែរ ។ យើងទាំងអស់គ្នាកំពុងតែអនុវត្តការផលិតថ្នាំដោយឯករាជ្យម្ចាស់ការ» ។ នួន ជា បងធំទីពីរនៃរបបខ្មែរក្រហមបាននិយាយជាសាធារណៈអំពីតម្រូវការនៃការថែទាំសុខភាពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីឆ្លុះបញ្ចាំងពីគោលដៅបដិវត្តន៍របស់របបនោះ ។ ចំពោះបក្ស ពេទ្យដែលស្មោះត្រង់នឹងមនោគមន៍វិជ្ជាបក្សមានសារសំខាន់ជាងពេទ្យដែលមានសមត្ថភាពនិងការបណ្តុះបណ្តាល ។ ការណែនាំដោយមេដឹកនាំដ៏មានអំណាចទាំងពីរទៅដល់មេដឹកនាំបក្សផ្សេងទៀតនៅពេលធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ និងសេចក្តីណែនាំផ្សេងទៀតមានរៀបរាប់នៅក្នុងអនុស្សរណៈខាងក្រោមបង្ហាញថា សេចក្តីសម្រេចកែប្រែការពិសោធផ្នែកវេជ្ជសាស្ត្រ និងសុខាភិបាលត្រូវបានគណៈមជ្ឈិមបក្សដឹងឮទាំងអស់ ហើយក៏ត្រូវបានផ្សព្វផ្សាយដល់កម្មាភិបាលថ្នាក់ទាបដើម្បីអនុវត្តដែរ ។

បុគ្គលដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះការធ្វើសេចក្តីព្រាងគោលនយោបាយវេជ្ជសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជារួមមាន ប៉ុល ពត និង នួន ជា គឺជាអ្នកបង្កើតបក្ស និងគណៈកម្មាធិការពាក់ព័ន្ធដូចជាគណៈមជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍បក្ស ។ មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាបីរូបក្នុងចំណោមមេដឹកនាំបួនរូបកំពុងតែរង់ចាំទទួលការជំនុំជម្រះនៅក្នុងករណី០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីព្រោះជនត្រូវចោទ នួន ជា, អៀង សារី និង ខៀវ សំផន គឺជាមេដឹកនាំគណៈកម្មាធិការទាំងនេះនៅក្នុងរបបខ្មែរក្រហម ។ នួន ជា ដែលស្គាល់ជា «បងធំទីពីរ» បន្ទាប់ពី ប៉ុល ពត គឺជាអនុលេខានៃគណៈមជ្ឈិមបក្សចាប់ពីឆ្នាំ១៩៦០មក ។ នួន ជា ក៏ជាប្រធានគណៈអចិន្ត្រៃយ៍ដែលគ្រប់គ្រងលើ «ការងាររបស់បក្ស កិច្ចការសង្គម វប្បធម៌ ឃោសនាការ និងការអប់រំជាដូវការ» ។ ការទទួលខុសត្រូវទាំងនេះទំនងជាមានរួមបញ្ចូលទាំងប្រព័ន្ធគ្រប់គ្រងផ្នែកសុខាភិបាលផង ។ អៀង សារី គឺជាសមាជិកនៃគណៈមជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍បក្ស ហើយគាត់មានតួនាទីគ្រប់គ្រងកិច្ចការបរទេសនិងផ្ទៃក្នុងបក្ស ។ ខៀវ សំផន បានចូលក្នុងគណៈមជ្ឈិមបក្សនៅឆ្នាំ១៩៧១ ដោយធ្វើជាសមាជិកត្រៀម ហើយគាត់បានក្លាយទៅជាសមាជិកពេញសិទ្ធិនៅក្នុងអង្គមិទ្ទីងបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៧៦ ។ នៅឆ្នាំដដែល ខៀវ សំផន បានប្រកាសជាសាធារណៈថាខ្លួនជាគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យដែលអនុញ្ញាតឲ្យគាត់ក្លាយទៅជាអ្នកនាំពាក្យគោលនយោបាយ

របស់បក្ស ។ នៅឆ្នាំ១៩៧៧ ខៀវ សំផន បានក្លាយទៅជាអ្នកគ្រប់គ្រង «មន្ទីរ៨៧០» ដែលជាកន្លែងប្រតិបត្តិការងាររបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ។

អៀង ធីរិទ្ធ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទីបួនដែលកំពុងរង់ចាំការជំនុំជម្រះនៅសាលាក្តីខ្មែរក្រហមគឺជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជា អៀង ធីរិទ្ធ មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមក៏ដោយ ក៏គាត់ត្រូវទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយសុខាភិបាលនិងការផ្តល់របបអាហារដែលបណ្តាលឲ្យប្រជាជនកម្ពុជារាប់សែននាក់កើតជំងឺហើម និងស្លាប់ជាបន្តបន្ទាប់ ។ ជាងនេះទៅទៀត អៀង ធីរិទ្ធ ធ្លាប់ត្រូវបាន ប៉ុល ពត ចាត់តាំងឲ្យទៅធ្វើការស៊ើបអង្កេតនិងរាយការណ៍អំពីបញ្ហាសុខាភិបាលនៅភូមិភាគពាយ័ព្យ ដូច្នេះគាត់ប្រហែលជាដឹងថាប្រជាជនកម្ពុជាជាច្រើននាក់ដែលរស់នៅក្នុងរបបនោះកំពុងតែស្រេកឃ្លាន និងឈឺស្ទើរគ្រប់គ្នា ។

អត្ថបទនេះនឹងធ្វើការបង្ហាញដោយសង្ខេបអំពីលទ្ធផលធំៗពីរដែលកើតឡើងដោយសារគោលនយោបាយឯករាជ្យម្ចាស់ការទៅលើផ្នែកវេជ្ជសាស្ត្រនៅក្នុងប្រទេសគឺការបដិសេធមិនឲ្យមានការថែទាំសុខភាព និងការពិសោធផ្នែកវេជ្ជសាស្ត្រទៅលើអ្នកដែលជាមនុស្សមិនស្ម័គ្រចិត្ត ។ បន្ទាប់មក អត្ថបទនេះនឹងពិនិត្យទៅលើតួនាទីរបស់ជនត្រូវចោទទាំងបួនដែលបានបង្កើតនិងអនុវត្តគោលនយោបាយទាំងនេះ ។ ជាទីបញ្ចប់ អត្ថបទនេះនឹងវិភាគទៅលើលទ្ធភាពដែលសាលាក្តីខ្មែរក្រហមអាចធ្វើការចោទប្រកាន់ទៅលើជនត្រូវចោទចំពោះការស្លាប់ដែលបណ្តាលមកពីគោលនយោបាយរបស់របបខ្មែរក្រហម ។

## ២) ការបដិសេធមិនផ្តល់ថ្នាំ និងការថែទាំសុខភាព

### ក) ការបិទមន្ទីរពេទ្យ និងការបំផ្លិចបំផ្លាញរចនាសម្ព័ន្ធសុខាភិបាល

ការរៀបចំរចនាសម្ព័ន្ធផ្នែកសុខាភិបាលរបស់ប្រទេសសាជាថ្មីរបស់ខ្មែរក្រហមបានចាប់ផ្តើមចេញពីការផ្លាស់ប្តូរមន្ទីរពេទ្យ និងការបំផ្លិចបំផ្លាញបច្ចេកវិទ្យា និងសម្ភារៈវេជ្ជសាស្ត្រទំនើប ។ បញ្ញត្តិមួយក្នុងចំណោម «បញ្ញត្តិទាំងប្រាំបី» ដែលខ្មែរក្រហមបានបង្កើតឡើងដើម្បីប្រែក្លាយកម្ពុជាទៅជាប្រទេសដ៏ល្អឥតខ្ចោះបានចែងថា «អង្គការមានតួនាទីលុបបំបាត់មន្ទីរពេទ្យ និងបុគ្គលិកពេទ្យដែលសេសសល់ពីរបបមុនដើម្បីបង្កើតមន្ទីរពេទ្យដែលមានបែបបទសង្គមនិយមគឺភាពបរិសុទ្ធនិងស្អាតស្អំ» ។ ការអនុវត្តបទបញ្ញត្តិនេះគឺនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅប្រទេសកម្ពុជា ខ្មែរក្រហមបានបណ្តេញអ្នកជំងឺ វេជ្ជបណ្ឌិត និង គិលានុបដ្ឋាកចេញពីមន្ទីរពេទ្យនៅភ្នំពេញនិងខេត្ត ព្រមទាំងបង្ខំឲ្យប្រជាជនផ្លាស់ទៅរស់នៅកន្លែងដែលគ្រប់គ្រងដោយខ្មែរក្រហម ។ អ្នកជំងឺខ្លះដែលជាពីជំងឺ និងរបួសត្រូវបានបង្ខំឲ្យរស់នៅជាមួយ «ប្រជាជនថ្មី» ដែលត្រូវបានជម្លៀសពីទីក្រុង ។ សូម្បីតែស្ត្រីមានផ្ទៃពោះក៏តម្រូវឲ្យចាកចេញពីមន្ទីរពេទ្យ និងធ្វើដំណើរទៅខេត្តឆ្ងាយៗដែរ ។

នៅពេលមន្ទីរពេទ្យត្រូវបានបិទនិងរុះរើសម្ភារៈវេជ្ជសាស្ត្រត្រូវបានបំផ្លាញ ឬបោះបង់ចោលឧបករណ៍ដែលប្រកបដោយអនាម័យនិងសម្រាប់ដាក់ឲ្យអ្នកជំងឺសម្រាកត្រូវបានផ្លាស់ប្តូរដោយកម្រាលកន្ទក់ និងគ្រែសាមញ្ញ បន្ទប់ទឹកឯកជនដែលមានអនាម័យត្រូវផ្លាស់ប្តូរទៅជាបន្ទប់ទឹកសាធារណៈ ទ្វារ និងបង្អួចមានលក្ខណៈមិនដូចគ្នាដោយផ្នែកដែលត្រូវបានដួលដុល ។ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតដែលជាអំណោយពីសហភាពសូវៀតទៅឲ្យកម្ពុជាកាលនោះគឺជារដ្ឋអព្យាក្រឹត ។ នៅពេលនោះកម្ពុជាមានសម្ភារៈដ៏ទំនើបបំផុតនៅក្នុងអាស៊ីអាគ្នេយ៍ ដែលមានដូចជាម៉ាស៊ីនភ្លើង ទូទឹកកកសម្រាប់ដាក់ថ្នាំ និងឧបករណ៍សុខាភិបាលត្រូវបានបំផ្លិចបំផ្លាញ បន្ទប់វះកាត់ត្រូវបានកម្ទេចចោល ។ មន្ទីរពេទ្យផ្សេងទៀតដូចជា មន្ទីរពេទ្យឆ្កួតនៅតាខ្មៅក្នុងខេត្តកណ្តាល ឬ (ជំរំព្រែកត្នោត) ត្រូវបានប្រែក្លាយទៅជាមន្ទីរឃុំឃាំង ។

បន្ថែមពីលើនេះទៅទៀត សាលាពេទ្យត្រូវបានបំផ្លាញ ។ បណ្ណាល័យពេទ្យនៅភ្នំពេញ ដែលផ្ទុកទៅដោយកំណត់ហេតុវេជ្ជសាស្ត្រ សៀវភៅ និងទស្សនាវដ្តីត្រូវបានបំផ្លាញនិងដុតចោល ។ សាលាពេទ្យនៅភ្នំពេញត្រូវបានបំបរបង់ចោលដោយសិស្សទាំងអស់ត្រូវបានជម្លៀសពីទីក្រុង ហើយឧបករណ៍ពិសោធន៍ត្រូវបោះចោលនៅតាមផ្លូវ ។ ឧបករណ៍បច្ចេកទេសព្យាបាលដែលមានតម្លៃខ្ពស់ត្រូវបានបញ្ជូនទៅឃ្លាំងស្តុកដែលបាក់បែក ។ នៅក្នុងរយៈពេលដ៏ខ្លី ជំនាញដ៏ប៉ិនប្រសប់របស់វេជ្ជបណ្ឌិតនៅកម្ពុជានិងបច្ចេកទេស

ដ៏ទំនើបនៃមន្ទីរពេទ្យធំជាងគេត្រូវកម្ទេចចោល ហើយត្រូវបានជំនួសវិញដោយប្រព័ន្ធសុខាភិបាលបដិវត្តន៍ឯករាជ្យម្ចាស់ការ ។

### ១) ការធ្វើវិសុទ្ធកម្មទៅលើបុគ្គលិកពេទ្យ

នៅពេលរបបខ្មែរក្រហមធ្លាក់ពីអំណាចនៅខែមករា ឆ្នាំ១៩៧៩ មានតែគ្រូពេទ្យតិចជាង៥០នាក់ប៉ុណ្ណោះដែលនៅរួចរស់ពីការធ្វើវិសុទ្ធកម្មរបស់ខ្មែរក្រហម ។ បុគ្គលិកពេទ្យដែលទទួលការបណ្តុះបណ្តាលបានក្លាយទៅជាជនរងគ្រោះនៃគោលនយោបាយផ្លាស់ប្តូរ «ប្រជាជនថ្មី» ដោយ «ប្រជាជនមូលដ្ឋាន» របស់ខ្មែរក្រហម ពីព្រោះភាពស្មោះត្រង់នឹងបក្សត្រូវបានឲ្យតម្លៃខ្ពស់ជាងបទពិសោធន៍និងគុណភាពនៃការព្យាបាល ។ យោងទៅតាមនួន ជា «ពេទ្យបដិវត្តន៍ត្រូវតែជាអ្នកដែលចេញពីវណ្ណៈកម្មករ-កសិករ ពីព្រោះគឺជាវណ្ណៈដែលធំជាងគេ និងដំណើរការលឿនជាងគេ ។ បក្សត្រូវការជំហរជាជាងសមត្ថភាពដើម្បីកសាងប្រទេស» ។

ការធ្វើវិសុទ្ធកម្មទៅលើបុគ្គលិកពេទ្យដែលទទួលការបណ្តុះបណ្តាលបានចាប់ផ្តើមនៅថ្ងៃទី១៧មេសា ១៩៧៥ នៅពេលដែលខ្មែរក្រហមឡើងគ្រប់គ្រងអំណាច ។ យោធាខ្មែរក្រហមបានបញ្ជាឲ្យមានការជម្លៀសគ្រូពេទ្យ គិលានុបដ្ឋាក ឆ្មប និងបុគ្គលិកពេទ្យផ្សេងទៀតចេញពីទីក្រុង ហើយពេលខ្លះត្រូវបង្ខំឲ្យចេញពីការងាររបស់ខ្លួននៅពេលដែលអ្នកទាំងនោះកំពុងវះកាត់ឬព្យាបាលអ្នកជំងឺ ។ អ្នកទាំងនោះ ត្រូវបានជម្លៀសពីភ្នំពេញជាមួយនឹង «ប្រជាជនថ្មី» ផ្សេងទៀត ហើយធ្វើដំណើរទៅ «តំបន់រំដោះ» ដែលស្ថិតនៅជនបទ ។ នៅពេលធ្វើដំណើរ គ្រូពេទ្យដែលកម្មាភិបាលខ្មែរក្រហមស្គាល់ត្រូវបានចាប់ខ្លួនហើយបន្ទាប់មកបាត់ខ្លួនសូន្យឈឹង ។

ការជម្លៀស និងការកម្ចាត់គ្រូពេទ្យដែលធ្លាប់ទទួលការបណ្តុះបណ្តាល និងគិលានុបដ្ឋាកមិនមែនកើតឡើងតែនៅទីក្រុងភ្នំពេញទេ ។ ឈុតឆាកនៃការឡើងកាន់អំណាចនៅតាមទីក្រុងមានកើតឡើងនៅទូទាំងប្រទេស គឺថាគ្រូពេទ្យត្រូវបានបង្ខំឲ្យធ្វើការបញ្ចេញពលកម្មឲ្យខ្មែរក្រហម ។ ប្រជាជនទីក្រុងបាត់ដំបងត្រូវបានជម្លៀសនៅថ្ងៃទី២៥ ខែមេសា ហើយបុគ្គលិកពេទ្យត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យ និងឱសថដ្ឋាន ។ មួយថ្ងៃមុន គឺថ្ងៃទី២៤ ខែមេសា ខ្មែរក្រហមបានជួបប្រជុំជាមួយបុគ្គលិកពេទ្យនៅខេត្តបាត់ដំបង និងប្រកាសថា «វណ្ណៈកសិករគឺជាវណ្ណៈនាំមុខដែលអាចដឹកនាំគ្រប់ផ្នែកនៅក្នុងប្រទេស ។ អង្គការប្រកាសឲ្យបណ្តេញនាយកមន្ទីរពេទ្យនៅពេលនោះ និងស្នើឲ្យមានការជ្រើសរើសអ្នកបោសសម្អាត និងអ្នកថែទាំអគារធ្វើជានាយកថ្មី ពីព្រោះអ្នកទាំងនេះក៏មានប្រភពចេញពីវណ្ណៈកសិករដែរ» ។ បទបញ្ជារបស់អង្គការត្រូវបានយកមកអនុវត្ត ហើយនាយកថ្មីត្រូវបានជ្រើសរើសចេញពីអ្នកថែទាំអគារ ។ «គ្រូពេទ្យបដិវត្តន៍» ដែលជំនួសបុគ្គលិកពេទ្យចាស់តម្រូវឲ្យទទួលការបណ្តុះបណ្តាលតែមួយអាទិត្យប៉ុណ្ណោះ ។

នៅពេលដែលបុគ្គលិកពេទ្យត្រូវបានបោសសម្អាតចេញពីមន្ទីរពេទ្យ និង ឱសថដ្ឋាន ក្មេងៗដែលមិនបានទទួលការអប់រំជាផ្លូវការ ឬមានទំនាក់ទំនងជាមួយសត្រូវរបស់របបខ្មែរក្រហម «ក្មេងដែលស្អាតស្អំ» ត្រូវបានជ្រើសរើសឲ្យធ្វើជាបុគ្គលិកពេទ្យបដិវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យ ។ នារីដែលមានអាយុចន្លោះពី ១១ ទៅ១៥ឆ្នាំ ដែលមិនធ្លាប់សិក្សាពីការព្យាបាល និងមិនចេះអក្សរត្រូវបានជ្រើសរើសឲ្យធ្វើជាគិលានុបដ្ឋាយិកា ពីព្រោះនៅឆ្នាំ១៩៧៨ ប៉ុល ពត បាននិយាយថា មិនមានការថែទាំសុខភាពនៅក្នុងរបបមូលធននិយមឬពួកបស្ចិមប្រទេសទេ ។ តាមការពិតក្មេងស្រីៗជាច្រើនចង់ក្លាយទៅជាគិលានុបដ្ឋាក ខណៈពេលដែលខ្មែរក្រហមបានចាត់ទុកវិស័យសុខាភិបាលជាវិស័យសំខាន់ទីពីរបន្ទាប់ពីវិស័យការពារជាតិ ។ ជាងនេះទៅទៀត បុគ្គលិកពេទ្យអាចចៀសផុតពីការធ្វើស្រែ និងការគាបសង្កត់ពីកម្មាភិបាលនៅតាមសហករណ៍ ។

ការបណ្តុះបណ្តាលនារីក្មេង (ពេលខ្លះបុរស) មានរយៈពេលតែបីខែប៉ុណ្ណោះ បន្ទាប់មកអ្នកទាំងនោះត្រូវបានចាត់ទុកថាជាពេទ្យ ។ សេចក្តីណែនាំផ្នែកសុខាភិបាលភាគច្រើនរួមមានការបង្រៀនក្មេងៗឲ្យស្គាល់ថ្នាំដែលមានប្រភេទផ្សេងៗគ្នា និងវិធីចាក់ថ្នាំ ។ ដោយសារតែគិលានុបដ្ឋាក និងពេទ្យមិនចេះអក្សរភាគច្រើននៃអ្នកទាំងនោះគ្រាន់តែស្គាល់ថ្នាំដោយចំណាំរូបរាង និងពណ៌ប៉ុណ្ណោះ ហើយមិនយល់ពីឯកសារណែនាំ (ដែលសរសេរជាភាសាបារាំង) ឬអានឬសរសេរវេជ្ជបញ្ជាផងទេ ។ មានការហាត់ចាក់ថ្នាំលើដើមចេក និងខ្ទើយ ។ ***(នៅមានត)*** **ឡូរ៉ា ទីលីម**

# ថិរវេលាកំណត់បីឆ្នាំលើការឃុំខ្លួនបណ្តោះអាសន្ននៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងបួនរូបរួមមាន នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន កំពុងត្រូវជាប់ឃុំជាបណ្តោះអាសន្ននៅអង្គជំនុំជម្រះវិសាមញ្ញពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ អ្នកទាំងបួននេះនឹងត្រូវនាំខ្លួនមកកាត់ទោសរួមគ្នានៅក្នុងសំណុំរឿងករណី០០២របស់សាលាក្តីខ្មែរក្រហម ។

**ថិរវេលាកំណត់សម្រាប់ការឃុំខ្លួននៅអង្គបុរេជំនុំជម្រះ**

នៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានចែងថា «ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយមានថិរវេលាមិនឲ្យលើសពីមួយឆ្នាំ ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នបន្ថែមម្តងបានមួយឆ្នាំ» ។ ហើយក្នុងអនុវិធានបន្ទាប់ទៀតបានកំណត់ថា «ទោះបីជាយ៉ាងណាក៏ដោយ ការពន្យារពេលមិនត្រូវឲ្យលើសពីពីរដងបានឡើយ» ។ អាស្រ័យហេតុនេះ ច្បាប់កំណត់ឲ្យមានតែរយៈពេលបីឆ្នាំប៉ុណ្ណោះសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ននេះ ។

ការឃុំខ្លួនឆ្នាំទីបីរបស់ នួន ជា នៅអង្គបុរេជំនុំជម្រះនឹងផុតកំណត់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១០ ។ ចំណែកឯរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជនជាប់ចោទបីនាក់ផ្សេងទៀតនឹងផុតកំណត់នៅខែវិច្ឆិកា ឆ្នាំ២០១០នេះដែរ ។ ប្រសិនបើមិនមានការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះមុនថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១០ ទេ នួន ជា នឹងអាចត្រូវបានដោះលែងនៅពេលនោះ ។ ដូចគ្នាផងដែរ នៅខែវិច្ឆិកា ឆ្នាំ២០១០ ជនជាប់ចោទបីនាក់ផ្សេងទៀតនឹងត្រូវបានដោះលែង ប្រសិនបើមិនមានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះអ្នកទាំងបីទេ ។ ប្រសិនបើជនជាប់ចោទទាំងនេះត្រូវបានដោះលែង តុលាការនឹងមិនមានអង្គច្បាប់ណាមួយដើម្បីធ្វើការឃុំខ្លួនជនទាំងនោះម្តងទៀតបានទេ ប្រសិនបើជនត្រូវចោទទាំងបួនត្រូវបានតុលាការចោទប្រកាន់នៅពេលក្រោយមកទៀត លើកលែងតែពួកគេមិនមានវត្តមានក្នុងសវនាការ ។

នៅក្នុងសំណុំរឿង០០១ (ករណី ឌុច នៅមន្ទីរស-២១) សវនាការកើតឡើងមុនថិរវេលាកំណត់នៃការឃុំខ្លួនបណ្តោះអាសន្នរយៈពេលបីឆ្នាំរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ ដោយសារតែដូច្នេះហើយ ទើបតុលាការត្រូវតែធ្វើការសម្រេចចិត្តថា



អតីតយុទ្ធនារីខ្មែរក្រហម និង ហាវ សុភា បង្ហាញរូបថតមេដឹកនាំខ្មែរក្រហមនៅក្នុងសៀវភៅសំណុំរឿង០០២

តើស្ថិតក្រោមកាលៈទេសៈណានៃវិធានផ្ទៃក្នុងដែលអាចអនុញ្ញាតឲ្យធ្វើការឃុំខ្លួនជនជាប់ចោទបានច្រើនជាងបីឆ្នាំដែរឬយ៉ាងណា ។

## ការឃុំខ្លួនបន្ទាប់ពីការចេញដីកាដំណោះស្រាយ

ការចេញដីកាដំណោះស្រាយគឺបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នដោយស្វ័យប្រវត្តិដូចដែលបាន ចែងនៅក្នុងវិធានផ្ទៃក្នុងថា «ការចេញដីកាដំណោះស្រាយមានអានុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននិងដីកាសម្រេចដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅពេលដែលរយៈពេលកំណត់នៃការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់» ។ ប៉ុន្តែរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នថ្មីមួយទៀត ប្រហែលជាអាចធ្វើឡើងបាន ។

នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ឬរក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការនៅតែតម្រូវនោះ សហចៅក្រមស៊ើបអង្កេតអាចបន្តឃុំខ្លួនជនជាប់ចោទតទៅទៀត ឬរក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែល នៅក្នុងដីកាដំណោះស្រាយរហូតដល់ជនជាប់ចោទនេះត្រូវបាននាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង ។

ថិរវេលានៃការឃុំខ្លួន ឬការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលមានដាក់នៅក្នុងដីកាដំណោះស្រាយ «គឺត្រូវអស់អានុភាពក្នុងរយៈពេលបួនខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ» ឬមួយក៏ «ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អានុភាពនៃសេចក្តីសម្រេចរក្សាជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេតត្រូវបន្តមានអានុភាពអនុវត្តរហូតមានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ ។ អង្គបុរេជំនុំជម្រះត្រូវសម្រេចក្នុងអំឡុងពេលបួនខែ» ។

នេះគឺអាចអះអាងបានថា ថិរវេលាថ្មីនៃការឃុំខ្លួនបណ្តោះអាសន្នរបស់អង្គបុរេជំនុំជម្រះមិនយោងទៅតាមរយៈពេលកំណត់បីឆ្នាំដែលមានចែងនៅក្នុងវិធាន៦៣នៃវិធានផ្ទៃក្នុងនោះទេ ។ វិធានផ្ទៃក្នុងគឺគ្រាន់តែសំដៅទៅលើថិរវេលាដែលសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះអាច «បន្តឃុំខ្លួនជនជាប់ចោទតទៅទៀត ឬរក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែល» ។ នៅក្នុងសេចក្តីប្រកាសមួយខែមេសា ឆ្នាំ២០១០ អង្គជំនុំជម្រះវិសាមញ្ញបានបកស្រាយវិធានថា អនុញ្ញាតឲ្យមានការឃុំខ្លួនរយៈពេលបីឆ្នាំ ហើយថែមបួនខែទៀតបន្ទាប់ពីមានចេញដីកាដំណោះស្រាយ ដោយនិយាយថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយមុនកាលបរិច្ឆេទផុតរលត់សម្រាប់ថិរវេលាឃុំខ្លួនដែលបានលើកឡើងនោះដីកានេះនឹងធ្វើឲ្យថិរវេលានៃការឃុំខ្លួន បច្ចុប្បន្នលែងមានអានុភាពតទៅទៀត ។ ប្រសិនបើនៅក្នុងដីកាដំណោះស្រាយរួមបញ្ចូលទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើជនជាប់ចោទ ហើយសហចៅក្រមស៊ើបអង្កេតយល់ឃើញថាលក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឲ្យមានការឃុំខ្លួនបណ្តោះអាសន្ននៅក្រោមវិធាន ៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនៅតែតម្រូវនោះសហចៅក្រមស៊ើបអង្កេតអាចបន្តឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នដដែលរហូតទាល់តែជនជាប់ចោទនេះត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ក្នុងករណីនេះ លើកលែងតែជនជាប់ចោទត្រូវបាននាំយកមកជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលបួនខែបន្ទាប់ពីកាលបរិច្ឆេទនៃការចេញដីកាដំណោះស្រាយ បើមិនអ៊ីចឹងទេ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននឹងមិនមានអានុភាពទៀតទេ ។

នៅក្នុងវិធានក៏បានសង្កត់ធ្ងន់ផងដែរថា «នៅគ្រប់ករណីណាក៏ដោយ សេចក្តីសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន ឬរក្សាលក្ខខណ្ឌនៃការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេតឬអង្គបុរេជំនុំជម្រះ ត្រូវអស់អានុភាពក្នុងអំឡុងពេលបួនខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ» ។ ពាក្យពេចន៍នៃភាសានេះមើលទៅដូចជាត្រូវបានតុលាការបកស្រាយថា អនុញ្ញាតឲ្យទាំងសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះធ្វើការឃុំខ្លួនជនចោទជាប់រយៈពេលបួនខែ ។ នៅក្នុងសំណុំរឿង ០០១ ដីកាដំណោះស្រាយចេញនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ដោយសម្រេចថាឌុចគួរតែត្រូវ

បានឃុំខ្លួនរហូតទាល់តែគាត់ត្រូវបាននាំយកទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ប៉ុន្តែ ឌុច មិនត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលបួនខែនោះទេ ។ តែផ្ទុយទៅវិញ នៅក្នុងអំឡុងពេលបួនខែបន្ទាប់ពីការចេញដីកាដំណោះស្រាយ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចដែលរួមបញ្ចូលដីកាមួយទៀតដើម្បីឃុំខ្លួន ឌុច រហូតទាល់តែគាត់ត្រូវបាននាំទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ឌុច មិនបានស្តាប់សវនាការបឋមរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេរហូតទាល់តែខែកុម្ភៈ ឆ្នាំ២០០៩ បន្ទាប់ពីដីកាឃុំខ្លួនរយៈពេលបួនខែរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានអស់សុពលភាព ។ ហេតុដូច្នេះ ទោះបីជាការឃុំខ្លួន ឌុច បណ្តោះអាសន្នមិនលើសពីរយៈពេលបីឆ្នាំដែលបានចែងនៅក្នុងវិធាន៦៣ក៏ដោយ ក៏ការបកស្រាយរបស់តុលាការវិញគឺដូចជាអនុញ្ញាតឲ្យមានការឃុំខ្លួនបណ្តោះអាសន្នជាអតិបរមាចំនួនបីឆ្នាំ ប្រាំបីខែមុនពេលដែលជនជាប់ចោទត្រូវបាន «នាំខ្លួនទៅចំពោះមុខ» អង្គជំនុំជម្រះសាលាដំបូងដែរ ។

ការវិភាគពាក្យពេចន៍នៃច្បាប់ គឺត្រូវបានធ្វើទៅតាមគោលការណ៍ច្បាប់អន្តរជាតិដែលបានគាត់តែងឡើងយ៉ាងត្រឹមត្រូវ ហៅថា «ការបកស្រាយដោយមានអានុភាព» ។ «ការបកស្រាយដោយមានអានុភាព» មានន័យថា ភាគីទាំងអស់បានគាត់តែងឯកសារឡើងដើម្បីឲ្យមានអានុភាពជាក់លាក់មួយ ហើយថា បទបញ្ញត្តិមួយមិនគួរត្រូវបានផ្តល់នូវការបកស្រាយមួយដែលធ្វើឲ្យវាមិនមានអត្ថន័យ ឬក៏មិនមានអានុភាពទេ ។ នៅក្នុងច្បាប់ព្រហ្មទណ្ឌ គោលការណ៍នេះមានសារសំខាន់ណាស់ ដោយសារតែការបកស្រាយរបស់តុលាការ «ផ្តល់នូវអានុភាពចំពោះសិទ្ធិ ឬគ្រប់គ្រងដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធី» ។ «គោលការណ៍នៃការបកស្រាយដោយមានអានុភាពបានកំណត់ថា វិធានត្រូវបានយកមកអានជាមួយគ្នា ហើយថាវិធាននោះនឹងត្រូវបានបកស្រាយយ៉ាងតឹងរ៉ឹង» ។ នៅក្នុងសេចក្តីសម្រេចនៃបណ្តឹងឧទ្ធរណ៍មួយនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា អង្គជំនុំជម្រះលើករណី កាដែលីដែលី បានកំណត់ថា វិធានពីរដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន «ត្រូវបានយកមកអានជាមួយគ្នា» ហើយ «ត្រូវបានបកស្រាយយ៉ាងតឹងរ៉ឹង» ។ ព្រះរាជអាជ្ញាបានអានវិធានទាំងពីរនោះដាច់ដោយឡែកពីគ្នា ។ ដោយធ្វើបែបនោះ ព្រះរាជអាជ្ញាអាចឃុំខ្លួនជនសង្ស័យក្នុងស្ថានភាពពន្យារពេលការឃុំខ្លួន (ហើយដែលជនសង្ស័យនោះមិនត្រូវបានបញ្ជាក់ប្រាប់ពីបទចោទមកលើខ្លួន ឬក៏នាំយកទៅចំពោះមុខចៅក្រមទេ) ជាជាងការធ្វើបត្យាប័នលើគាត់ឲ្យកាន់តែលឿនតាមដែលអាចធ្វើទៅបាន ។

អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានព្រមានខាងព្រះរាជអាជ្ញាចំពោះកាលដែលធ្វើការអាននូវបទបញ្ញត្តិមួយដោយឡែកពីគ្នាដើម្បីចៀសវាងចេតនាជាទូទៅនៃវិធានទាំងនោះក្នុងបំណងការពារសិទ្ធិរបស់ជនសង្ស័យ នៅក្នុងអំឡុងពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញថា រយៈពេលនៃការឃុំខ្លួននៅក្នុងអំឡុងពេលដែល កាដែលីដែលី ត្រូវបានឃុំខ្លួននៅក្រៅប្រទេសបានបំពារបំពានលើរយៈពេលកំណត់នៃការឃុំខ្លួនមុនការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅប្រទេសរ៉្វាន់ដា ។

នៅក្នុងការបកស្រាយនូវវិធានផ្ទៃក្នុងរបស់ខ្លួន អង្គជំនុំជម្រះវិសាមញ្ញគួរតែអានបទបញ្ញត្តិនៃការឃុំខ្លួនទាំងអស់របស់អង្គបុរេជំនុំជម្រះ ។ វិធីសាស្ត្របែបនេះបញ្ជាក់ថា រាល់ការឃុំខ្លួនបណ្តោះអាសន្ននៅអង្គបុរេជំនុំជម្រះទាំងអស់ រួមទាំងរយៈពេលដែលកំណត់ឡើងដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ត្រូវតែកម្រិតជាអតិបរមាត្រឹមបីឆ្នាំ ។ ម្យ៉ាងវិញទៀត ពាក្យពេចន៍នៅក្នុងវិធាន ៦៨ (១) ដែលបញ្ចប់រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមួយ ហើយអនុញ្ញាតឲ្យមានការឃុំខ្លួនមួយទៀត ប្រហែលជាត្រូវបានយកមកអានដើម្បីអនុញ្ញាតឲ្យមានការឃុំខ្លួនបន្ថែមរយៈពេលបួនខែ ដែលបន្ថែមទៅលើថិរវេលាឃុំខ្លួនជាអតិបរមាចំនួនបីឆ្នាំនៃវិធាន៦៣នោះ ។ ប៉ុន្តែ វាដូចជាមិនច្បាស់លាស់នោះទេថាតើវិធាននេះត្រូវបានយកមកបកស្រាយក្នុងន័យថា អនុញ្ញាតឲ្យទាំងសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះប្រើប្រាស់រយៈឃុំខ្លួនបួនខែដាច់ដោយឡែកពីគ្នាឬមួយយ៉ាងណា ។ ផ្ទុយទៅវិញ ពាក្យពេចន៍នៃភាសាក្នុងវិធាន៦៨ (៣) បញ្ជាក់ថា បួនខែគឺជាថិរវេលាអតិបរមានៃការឃុំខ្លួនបន្ទាប់ពីការចេញដីកាដំណោះស្រាយមិនខ្វល់ថាតើដីកានោះចេញដោយសហ

ចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះឬក៏ទាំងសងខាងនោះទេ ។

អាស្រ័យហេតុនេះ ទោះបីជាប្រសិនបើសហចៅក្រមស៊ើបអង្កេតដាក់ជូននូវដីកាដំណោះស្រាយសម្រាប់សំណុំរឿង ០០២ មុនកាលបរិច្ឆេទផុតរលត់នៃការឃុំខ្លួនបណ្តោះអាសន្នចំនួនបីឆ្នាំរបស់ នួន ជា នៅខែកញ្ញា ឆ្នាំ២០១០ យ៉ាងណាក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតត្រូវតែនាំខ្លួនជនជាប់ចោទទៅចំពោះអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលបួនខែនៃការចេញដីកានោះដែរ បើមិនអ៊ីចឹងទេ នួន ជា នឹងត្រូវបានដោះលែង ។

## ការ «នាំទៅចំពោះមុខ» អង្គជំនុំជម្រះសាលាដំបូង

វិធាន៦៨ (៣) បានចែងថា ការឃុំខ្លួន «ត្រូវអស់អានុភាពក្នុងរយៈពេលបួនខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅអង្គជំនុំជម្រះសាលាដំបូងនៅអំឡុងពេលនោះ» ។ នៅក្នុងដីកាដំណោះស្រាយរបស់សំណុំរឿង០០១ សហចៅក្រមស៊ើបអង្កេតបាន «សម្រេចរក្សា ឌុច ក្នុងឃុំបណ្តោះអាសន្នរហូតទាល់តែ ឌុច ត្រូវបាននាំយកទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង» ។ សហចៅក្រមស៊ើបអង្កេតមិនបានបញ្ជាក់ពីពេលវេលាកំណត់ជាក់លាក់នោះទេ ប៉ុន្តែក៏ឲ្យនិយមន័យនៃពាក្យ «នាំយកទៅចំពោះមុខ» ផងដែរ ។ នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គជំនុំជម្រះបានសម្រេចថា «ការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ននឹងត្រូវបន្ត រហូតទាល់តែជនជាប់ចោទចូលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង» ។ ការសម្រេចលើកទីពីរនេះបានបញ្ជាក់បន្ថែមទៅលើពាក្យពេចន៍នោះថា «នាំយកទៅចំពោះមុខ» គឺមានន័យថា «បង្ហាញខ្លួននៅចំពោះមុខ» អង្គជំនុំជម្រះសាលាដំបូង ។ ប្រយោគទាំងពីរនេះបង្ហាញថា ជនជាប់ចោទត្រូវមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមុនពេលកាលបរិច្ឆេទផុតរលត់នៃរយៈពេលអតិបរមាបួនខែសម្រាប់ការឃុំខ្លួនបន្ទាប់ពីការចេញដីកាដំណោះស្រាយ ។

នៅក្នុងវិធានច្បាប់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាវ៉ាន់ដា ការប្រើប្រាស់ពាក្យថា «នាំយកទៅចំពោះមុខ» គឺផ្តោតសំខាន់ដូចគ្នាទៅលើវត្តមាននៃជនជាប់ចោទ ៖ «បន្ទាប់ពីការផ្លាស់ប្តូររបស់ជនសង្ស័យមកកៅអីនៃអង្គជំនុំជម្រះ ជនសង្ស័យដែលមានជំនួយពីទីប្រឹក្សារបស់គាត់ត្រូវតែនាំយកទៅចំពោះមុខចៅក្រមដែលជាអ្នកសម្រេចលើដីកាបឋម ឬក៏ចៅក្រមផ្សេងទៀតរបស់អង្គជំនុំជម្រះសាលាដំបូងដូចគ្នាដោយមិនមានការពន្យារពេលឡើយ» ។ ចំណែកឯក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយវិញ ក៏បានគាំទ្រផងដែរនូវការបកស្រាយបែបនេះ ដោយនិយាយថា ៖ «ជនណាម្នាក់ដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនពីបទឧក្រិដ្ឋណាមួយត្រូវនាំយកទៅចំពោះមុខចៅក្រម ឬមន្ត្រីតុលាការផ្សេងទៀតដែលច្បាប់ផ្តល់អំណាចតុលាការឲ្យអនុវត្ត» ។ នៅអង្គជំនុំជម្រះវិសាមញ្ញនោះគឺមានន័យថា អង្គជំនុំជម្រះសាលាដំបូងមិនមែនគ្រាន់តែទទួលបណ្តឹងដើម្បីឲ្យជនជាប់ចោទយល់ឃើញថា «ត្រូវបានយកទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង» នោះទេ ។

នៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះបានចែងថា ៖ «ការជម្រះសេចក្តីចាប់ផ្តើមជាមួយនឹងសវនាការបឋម» ។ នេះគឺជាសវនាការសាធារណៈលើកទីមួយដែលដំណើរការឡើងដោយអង្គជំនុំជម្រះសាលាដំបូង ។ អង្គជំនុំជម្រះសាលាដំបូងក៏អាច «ពិគ្រោះយោបល់ជាមួយភាគីទាំងឡាយដោយធ្វើការប្រជុំរៀបចំសវនាការដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ។ កិច្ចប្រជុំនេះត្រូវធ្វើជាសម្ងាត់ លើកលែងតែអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្សេងពីនេះ ។ កិច្ចប្រជុំនេះគឺរួមទាំងវត្តមានរបស់ជនជាប់ចោទ ប៉ុន្តែមិនមែនជាសាធារណៈនោះទេ ។

ពាក្យពេចន៍ដែលថា «នាំយកទៅចំពោះមុខ» ទាមទារឲ្យមានវត្តមានជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមុនពេលកាលបរិច្ឆេទផុតរលត់នៃរយៈពេលឃុំខ្លួនបួនឆ្នាំដែលត្រូវបានអនុញ្ញាត បន្ទាប់ពីការចេញដីកាដំណោះស្រាយ ។ ដោយសារតែក្នុងវិធានមិនបានបញ្ជាក់ថាការ «នាំយកទៅចំពោះមុខ» អង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យមានសវនាការសាធារណៈនោះទេ នោះការរៀបចំសវនាការជាសម្ងាត់អាចបំពេញនូវតម្រូវការផ្សេងៗ និងអាចធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការចេញដីកាឃុំខ្លួនជនជាប់ចោទសម្រាប់រយៈពេលនៃការប្រព្រឹត្តទៅនៃសវនាការ ។ **អាមី ហាយនីស**

# លទ្ធភាពនៃការចោទប្រកាន់អំពើប្រល័យពូជសាសន៍ ដែលខ្មែរក្រហមបានធ្វើទៅលើខ្មែរក្រោម

## ១) សេចក្តីផ្តើម

ជនជាតិភាគតិចខ្មែរក្រោមបានរស់នៅក្នុងតំបន់ដីសណ្តទន្លេមេគង្គជាច្រើនសតវត្សរ៍មកហើយ គឺប្រហែលជា៥៥០ឆ្នាំនៃគ្រិស្តសករាជ ។ ខ្មែរក្រោមបានទទួលឥទ្ធិពលពីវប្បធម៌វៀតណាម ទោះបីជានៅថែរក្សាវប្បធម៌ខ្មែរក៏ដោយ ។ អ្វីដែលគួរឲ្យកត់សម្គាល់បំផុតគឺអ្នកទាំងនោះនិយាយភាសាបីដែលមានការលើកដាក់សំឡេងតាមវៀតណាម ។ អត្តសញ្ញាណចម្រុះនេះបានធ្វើឲ្យខ្មែរក្រោមស្ថិតនៅចន្លោះរវាងកម្ពុជានិងវៀតណាម ។ ដោយសារតែភាពស្មោះត្រង់ទៅលើប្រទេសទាំងពីរ ខ្មែរក្រោមបានក្លាយទៅជាគោលដៅសម្រាប់ការធ្វើបាបរបស់ខ្មែរក្រហម ។ អត្ថបទនេះនឹងរៀបរាប់ទៅលើបញ្ហាថាតើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងសម្រេចអំពីខ្មែរក្រោមដោយរបៀបណា? ជាពិសេសថាតើអ្នកទាំងនេះអាចជាក្រុមដែលទទួលបានការការពារនៅក្រោមអនុសញ្ញាអំពើប្រល័យពូជសាសន៍ឬទេ? អត្ថបទនេះនឹងចាប់ផ្តើមរៀបរាប់ពីប្រវត្តិសង្ខេបរបស់ខ្មែរក្រោម និងអំពើសាហាវឃោរឃៅដែលខ្មែរក្រោមត្រូវបានខ្មែរក្រហមធ្វើបាប បន្ទាប់មកនឹងលើកឡើងពីយុត្តិសាស្ត្រអន្តរជាតិដែលជាប់ពាក់ព័ន្ធស្តីពីការបែងចែកក្រុម និងការកំណត់សមាជិក ។ នៅទីបញ្ចប់ អត្ថបទនេះនឹងបកស្រាយពីមធ្យោបាយដែលសាលាក្តីខ្មែរក្រហមអាចប្រើប្រាស់ជាភស្តុតាងដែលខ្មែរក្រហមធ្វើទៅលើខ្មែរក្រោមដើម្បីធ្វើការចោទប្រកាន់អំពើប្រល័យពូជសាសន៍នៅក្នុងករណី០០២ ។

## ២) ប្រវត្តិសាស្ត្រ

រហូតដល់សតវត្សរ៍ទី១៨ ដីសណ្តទន្លេមេគង្គពោរពេញទៅដោយប្រជាជនខ្មែររស់នៅ ប៉ុន្តែវត្តមាននៃវៀតណាមបានកើនឡើងជាលំដាប់ ។ នៅចុងសតវត្សរ៍ទី១៩ អាជ្ញាធរបារាំងបានបញ្ចូលប្រជាជនខ្មែរដែលរស់នៅក្នុងតំបន់ដីសណ្តទន្លេមេគង្គទៅក្នុងទឹកដីកូសាំងស៊ីនដែលធ្វើឲ្យវៀតណាមក្លាយប្រជាជនភាគច្រើននៅក្នុងតំបន់នោះវិញ ។ នៅពេលចាប់ផ្តើម ខ្មែរក្រោមបានធ្វើអន្តោប្រវេសន៍បន្តិចម្តងៗចូលមកក្នុងតំបន់ដីសណ្តទន្លេមេគង្គដែលអាចជាទឹកដីកម្ពុជា ។ បច្ចុប្បន្ន ខ្មែរក្រោមដែលត្រូវបារាំងបែងចែកឲ្យនៅចន្លោះរវាងវៀតណាមនិងកម្ពុជាបានហៅដីសណ្តទន្លេមេគង្គថាជាកម្ពុជាក្រោមដែលការហៅនេះអាចបញ្ជាក់ពីទឹកដីនិងអត្តសញ្ញាណដែលមានជាប់ពាក់ព័ន្ធនឹងតំបន់នោះ ។

ការរួមបញ្ចូលគ្នា និងអត្តសញ្ញាណផ្សេងគ្នាបានធ្វើឲ្យខ្មែរក្រោមក្លាយជាធនធានដ៏ល្អសម្រាប់ផ្នែកយោធារបស់អាមេរិកនិងក្រុមនយោបាយស្តាំនិយមប្រឆាំងនឹងកុម្មុយនីស្ត ។ នៅអំឡុងសង្គ្រាមវៀតណាម កងកម្លាំងពិសេសអាមេរិកបានកេណ្ឌប្រជាជនខ្មែរក្រោមឲ្យធ្វើជាទ័ពសម្រាប់វាយជាមួយវៀតកុង ។ កងទ័ពទាំងនេះត្រូវបានគេហៅថាក្រុម «កន្សែងស» ហើយកងទ័ពទាំងនេះបានហៅខ្លួនឯងថាជាចលនាបះបោរកម្ពុជាក្រោម ។ ចន ឆរឆិអារី ទីប្រឹក្សាផ្នែកច្បាប់ជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយថាចលនាយោធាប្រឆាំងកុម្មុយនីស្តនៅកម្ពុជាដូចជា ចលនាខ្មែរសេរីក៏បានជ្រើសរើសខ្មែរក្រោមឲ្យធ្វើជាទ័ពដែរ ។ គោលដៅចម្បងរបស់ខ្មែរសេរីគឺរៀបចំរដ្ឋប្រហារប្រឆាំងនឹងស្តេច និងប្រឆាំងនឹងការរីកលូតលាស់នៃកុម្មុយនីស្ត ។ ជាងនេះទៅទៀត ឆរឆិអារី បានអះអាងថា បន្ទាប់ពីសេនាប្រមុខ លន់ នល់ បានឡើងកាន់អំណាចនៅខែមីនា ឆ្នាំ១៩៧០ កងទ័ពខ្មែរសេរីបានចូលរួមក្នុងសង្គ្រាមស៊ីវិលប្រឆាំងជាមួយនឹងខ្មែរក្រហម ។ ខណៈពេលដែលខ្មែរក្រោមបានគាំទ្រចលនាប្រឆាំងកុម្មុយនីស្ត ឬយោធាអាមេរិកដែលប្រឆាំងនឹង ប៉ុល ពត នៅក្នុងសង្គ្រាមស៊ីវិលជាសាធារណៈ ខ្មែរក្រោមទាំងអស់ត្រូវខ្មែរក្រហមចាត់ទុកថាអាចជាការគំរាមកំហែងមួយដល់ផ្នែកនយោបាយ ។ ឆរឆិអារី បាននិយាយថា បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ខ្មែរក្រហមនៅចងចាំពីសង្គ្រាមដែលទាហានខ្មែរក្រោមបានធ្វើមកលើខ្លួន ។ ខ្មែរក្រហមក៏បានចាត់ទុកខ្មែរក្រោមថា «មិនមានភាព

បរិសុទ្ធផ្នែកវប្បធម៌» ហើយជឿថាអត្តសញ្ញាណនយោបាយនិងវប្បធម៌ពីររបស់ខ្មែរក្រោមអាច «បង្កភាពស្មុគស្មាញដល់ការបង្កើតរដ្ឋកម្ពុជាថ្មី» ។ នៅឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ទំនាក់ទំនងរវាងវៀតណាម និងកម្ពុជាបានធ្លាក់ចុះជាខ្លាំង ។ ដោយសារតែលទ្ធភាពក្នុងការសម្រុបទៅនឹងសង្គមកម្ពុជា និងមានការស្មោះត្រង់ទៅប្រទេសពីរ ខ្មែរក្រោមត្រូវបានចាត់ទុកថាជាបណ្តាញយកការណ៍ និងជាជនក្បត់ដែលជាគោលដៅសម្រាប់ការធ្វើទុក្ខបុកម្នេញនិងការបោសសម្អាត ។

## ៣) ឧទាហរណ៍នៃការកំណត់គោលដៅទៅលើខ្មែរក្រោម

នៅក្នុងសៀវភៅរបស់លោក បែន គៀរនិន គាត់បានបញ្ជាក់យ៉ាងច្បាស់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រោមត្រូវបានជ្រើសរើស និងលើកជាឧទាហរណ៍សម្រាប់ធ្វើទុក្ខបុកម្នេញ ។ នៅក្នុងឧទាហរណ៍ទីមួយដែល បែន គៀរនិន បានលើកឡើង គឺនៅឆ្នាំ១៩៧៦ពេលដែលវៀតណាមបង្ខំឲ្យក្រុម «កន្ទែងស» មួយក្រុមដែលមានសមាជិក៦៨នាក់ចូលមកកម្ពុជា ។ ទាហានខ្មែរក្រោមបានស្នើរកកម្មាភិបាលខ្មែរក្រហមដើម្បីប្រមូលផ្តុំគ្នាវាយប្រឆាំងនឹងវៀតណាម ។ ប៉ុន្តែ ការស្នើនោះត្រូវបានខ្មែរក្រហមបដិសេធ ហើយទាហាន៦៧នាក់ដែលមិនប្រដាប់អាវុធត្រូវបានខ្មែរក្រហមបាញ់រះ ខណៈពេលដែលអ្នកទាំងនោះកំពុងរត់គេចខ្លួន ។ អ្វីដែលអាក្រក់ជាងនេះគឺមេបញ្ជាការរបស់ក្រុមនោះត្រូវខ្មែរក្រហមបញ្ជូនទៅគុកទួលស្លែង ។ បន្ទាប់ពីទទួលទារុណកម្មនិងមុនពេលសម្លាប់ មេបញ្ជាការនោះបានសារភាពថា ខ្លួនជា «សត្រូវខាងក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ» ។ ការសារភាពនេះបានត្រឹមតែធ្វើឲ្យការសង្ស័យរបស់ខ្មែរក្រហមចំពោះខ្មែរក្រោមកាន់រីកធំឡើង ។ ប៉ុន្មានខែក្រោយមក នៅក្នុងស្រុកគិរីវង្ស កម្មាភិបាលក្នុងតំបន់បានអួតសរសើរខ្លួនឯងថាបានសម្លាប់ «ក្រុមកន្ទែងស» ជាងពីរពាន់នាក់ ខ្មែរក្រោមដែលជា «បរិវាររបស់អាមេរិក» និងដែលត្រូវបានគេសម្គាល់តាមរយៈការទុក «សក់វែង» និងទម្លាប់ចូលចិត្តផឹកទឹកដោះគោ ។ «ក្រុមកន្ទែងស» ត្រូវបានសម្លាប់ដោយសារតែអ្នកទាំងនោះអាចក្លាយទៅជាសត្រូវរបស់កម្ពុជាប្រជាធិបតេយ្យនៅពេលអនាគត ។ មេដឹកនាំខ្មែរក្រហម និងកម្មាភិបាលតាមតំបន់បានអះអាងថា ការសម្លាប់រង្គាលខ្មែរក្រោមដោយសារតែខ្មែរក្រោមមិនមែនជាខ្មែរ ។ ខ្មែរក្រោមត្រូវបានគេចាត់ទុកថាជា «ក្បាលយួន ខ្លួនខ្មែរ» ដូច្នេះក្រុមនេះត្រូវតែបាត់ខ្លួន ។ ខ្មែរក្រោមដែលត្រូវបានគេស្មើរកក៏រួមមានវៀតណាមដែរ ។ នៅឆ្នាំ១៩៧៦ នៅស្រុកបាទី នៃភូមិភាគនិរតី គ្រួសារខ្មែរក្រោមទាំងអស់ (ដែលភាគច្រើននៃអ្នកទាំងនោះប្រហែលជារស់នៅប្រទេសកម្ពុជាបានមួយជំនាន់មកហើយ) ត្រូវបានសម្លាប់រង្គាលនៅក្នុងវត្ត ។ អាជ្ញាធរខ្មែរក្រហមបានអះអាងថា នេះដោយសារតែអ្នកទាំងនោះចេះនិយាយវៀតណាម ។

ខណៈពេលដែលជម្លោះជាមួយវៀតណាមកាន់តែរីករាលដាល ហើយស្ថានភាពរបស់ខ្មែរក្រហមបានចាប់ផ្តើមចុះខ្សោយ ការសង្ស័យទៅលើវត្តមាននៃភ្នាក់ងារវៀតណាមកាន់តែកើនឡើង ។ ខ្មែរក្រោមតែងតែត្រូវបានខ្មែរក្រហមសង្ស័យ ។ ឯកសារមកពីគុកក្រាំងតាចាន់នៅខេត្តតាកែវបង្ហាញថា ខ្មែរក្រោមតែងតែត្រូវបានសង្ស័យថាជាឈ្លបយកការណ៍ និងប្រព្រឹត្តសកម្មភាព «ប្រឆាំងនឹងបដិវត្តន៍» ។ លោក ចន ឆរឆីអារី បានរកឃើញថា ឯកសារមកពីគុកដែលរក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញថាអ្នកទោសភាគច្រើននៅគុកក្រាំងតាចាន់គឺជាខ្មែរក្រោម ។

នៅឆ្នាំ១៩៧៧ នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ កម្មាភិបាលតំបន់ដែលជាខ្មែរក្រោមត្រូវបានគេចោទប្រកាន់ថាជាជនក្បត់ ។ ខ្មែរក្រោមដែលនៅសេសសល់ត្រូវបានបំបែកចេញពីខ្មែរដទៃទៀតដោយសារតែពង្សាវតារ ។ ក្រោយមក អ្នកទាំងអស់នោះត្រូវបានគេសម្លាប់ដោយចោទប្រកាន់ថាជា «ជនក្បត់» ។ លោក ចន ឆរឆីអារី បាននិយាយថា អ្នកទាំងនោះត្រូវបានគេកំណត់ថាជាគោលដៅសម្លាប់ពីព្រោះអ្នកទាំងនោះមានទំនាក់ទំនងជាមួយវៀតណាម ។ លោក គៀរនិន បានលើកឡើងថា នៅតំបន់ខ្លះខ្មែរក្រោមត្រូវបានគេសម្គាល់តាមរយៈនាមត្រកូលដូចជា ថាច់, សុន ឬ ញៀង ។ នៅភូមិភាគបស្ចិម កម្មាភិបាលក្នុងតំបន់បាននិយាយថា «ខ្មែរក្រោមទាំងអស់បានក្លាយទៅជាវៀតណាម» ពីព្រោះខ្មែរក្រោមបានទទួលឥទ្ធិពលពីវៀតណាមប៉ុន្មានសតវត្សរ៍មកហើយ ។ ជាលទ្ធផល នៅក្នុងឆ្នាំដដែល កម្មាភិបាលខ្មែរក្រហមបានធ្វើសេចក្តីប្រកាសថា ខ្មែរក្រោមណាដែលបង្ហាញខ្លួននៅក្នុងតំបន់នឹងត្រូវយកទៅសម្លាប់ ។

### ៤) ការកំណត់ឲ្យខ្មែរក្រោមស្ថិតក្នុងក្រុមទទួលបានការការពារនៅក្រោមអនុសញ្ញាអំពើប្រល័យពូជសាសន៍

តាមមាត្រា៩នៃកិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិ សាលាក្តីខ្មែរក្រហមមានយុត្តាធិការលើកម្មវត្ថុនៃបណ្តឹងចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចដែលបានចែងនៅក្នុងអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៤៨។ មាត្រា៤នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់ថា អំពើប្រល័យពូជសាសន៍គឺជា «សកម្មភាពទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬដោយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា ៖

ក) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

ខ) ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកនៃក្រុម

គ) ការធ្វើដោយចេតនាឲ្យក្រុមណាមួយទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក

ឃ) ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតទារក

ង) ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយផ្សេងទៀត

អំពើប្រល័យពូជសាសន៍គឺជាការបំផ្លិចបំផ្លាញដោយចេតនាទៅលើក្រុមដែលទទួលបានការការពារជាក្រុម ឬដោយផ្នែក។ ប៉ុន្តែ បញ្ហាគឺជាការកំណត់ថាតើក្រុមណាដែលអនុសញ្ញាអំពើប្រល័យពូជសាសន៍ត្រូវការពារ ឬថាតើនៅពេលណាទើបក្រុមមនុស្សមួយក្រុមគឺជាក្រុមដែលទទួលបានការការពារ? អនុសញ្ញាអំពើប្រល័យពូជសាសន៍បានដាក់កំហិតទៅលើពាក្យបណ្តឹងមកត្រឹមតែក្រុមជាតិសាសន៍ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាប៉ុណ្ណោះ។ ប៉ុន្តែ អនុសញ្ញាអំពើប្រល័យពូជសាសន៍មិនបានធ្វើការកំណត់ក្រុមបែបនោះ ឬបង្កើតអ្វីមួយសម្រាប់ដាក់ឲ្យក្រុមនោះក្លាយជាសមាជិកទេ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលជាតុលាការ «ពិសេស» បានព្យាយាមធ្វើការកំណត់ក្រុមមនុស្សដែលទទួលបានការការពារ និងព្យាយាមប្រើប្រាស់ការកំណត់ក្រុមនោះទៅលើក្រុមមនុស្សជាក់លាក់។ ខណៈពេលដែលមនុស្សមួយចំនួនគឺជា «ក្រុម» មួយ វាមានការលំបាកក្នុងការដាក់ឲ្យក្រុមនោះស្ថិតនៅក្រោមការការពាររបស់អនុសញ្ញាអំពើប្រល័យពូជសាសន៍។

### ៥) តើក្រុមណាត្រូវទទួលបានការការពារ?

ក) ក្រុមនយោបាយមិនត្រូវបានទទួលការការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍ទេ

ក-១) ប្រសិនបើសមាជិកក្រុមត្រូវបានគេកំណត់ថាជាគោលដៅដោយសារតែទំនាក់ទំនងនយោបាយ ឬប្រសិនបើក្រុមនោះត្រូវបានគេកំណត់តាមរយៈលក្ខណៈនយោបាយ ក្រុមនោះមិនអាចទទួលបានការការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍ទេ

អនុសញ្ញាប្រល័យពូជសាសន៍មិនបានរួមបញ្ចូលមនុស្សគ្រប់ក្រុមនោះទេ។ តុលាការពិសេសបានអះអាងថា ក្រុមសេដ្ឋកិច្ច និងនយោបាយស្ថិតនៅក្រៅការការពាររបស់អនុសញ្ញាអំពើប្រល័យពូជសាសន៍។ នៅពេលអានកំណត់ហេតុការងារដែលបានរៀបចំទុក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា នៅក្នុងករណី រូតាហ្គេនដា បានអះអាងថា «ក្រុមជាក់លាក់មួយចំនួនដូចជាក្រុមសេដ្ឋកិច្ច និងនយោបាយ មិនត្រូវបានគេបញ្ចូលទៅក្នុងក្រុមដែលទទួលបានការការពារទេ ពីព្រោះអ្នកទាំងនោះត្រូវបានគេចាត់ទុកជា «ក្រុមចល័ត» ដែលសមាជិកក្រុមនោះចូលរួមដោយសារតែ «ឆន្ទៈនយោបាយ និងបុគ្គល»។ អាស្រ័យហេតុនេះ ប្រសិនបើជនណាដែលត្រូវបានគេកំណត់គោលដៅដោយសារតែជននោះមានទំនាក់ទំនងនយោបាយដោយស្ម័គ្រចិត្ត ជននោះនឹងមិនទទួលបានការការពារដោយអនុសញ្ញាអំពើប្រល័យពូជសាស៍ទេ។

ក-២) ក្រុមដែលទទួលបានការការពារត្រូវបានកំណត់គោលដៅដោយសារតែហេតុផលបន្ថែមមួយចំនួន

បញ្ហាដែលបានកើតឡើងនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាគឺថាតើក្រុមដែលទទួលបានការការពារដែលជនដៃដល់យល់ថាមានជាប់ពាក់ព័ន្ធនឹងក្រុមនយោបាយអាច

ទទួលបានការការពារឬទេ? ឬថាតើផ្នែកបន្ថែមនៃនយោបាយអាចធ្វើឲ្យក្រុមនោះមិនស្ថិតនៅក្រោមការការពារឬទេ? តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថាវត្តមាននៃហេតុផលបន្ថែមសម្រាប់បំផ្លាញក្រុមដែលទទួលបានការការពារមិនអាចរារាំងនូវស្ថានភាពដែលទទួលបានការការពារឡើយ ។ ជាឧទាហរណ៍ នៅក្នុងករណី ណាហ៊ីម៉ាណា តុលាការបានកំណត់ថា «ការសហការរបស់ទុតស៊ីជាមួយនឹងភ្នាក់ងារនយោបាយដែលរួមបញ្ចូលអត្តសញ្ញាណនយោបាយ និងជាតិពន្ធុជាមួយគ្នាមិនអាចធ្វើជាហេតុផលសម្អាងរបស់ជនត្រូវចោទទេ» ។ តាមការពិត តុលាការបានអះអាងថា «ការសម្គាល់ថាទុតស៊ីជាសត្រូវរបស់ប្រទេសជាមួយនឹងការប្រឆាំងនយោបាយដែលជនជាតិទុតស៊ីអាចធ្វើឡើង បង្ហាញថាភាពជាសមាជិកនៅក្នុងក្រុមគឺជាមូលហេតុដែលបណ្តាលឲ្យក្រុមនេះត្រូវបានគេកំណត់គោលដៅ ។

នៅក្នុងករណី ឌីនដាបាហ៊ីហ្សី ដែលជាករណីបន្ទាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានពិចារណាថាតើជនរងគ្រោះដោយសារគេរដិណែលអាចជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែរឬទេ? តុលាការបានស្តាប់សក្ខីកម្ម ហើយដឹងថា ជនរងគ្រោះឈ្មោះ ណរ ត្រូវបានសម្លាប់ដោយសារតែគាត់ជាជនជាតិទុតស៊ី ។ ជាងនេះទៅទៀត តុលាការបានស្តាប់សក្ខីកម្មថា គាត់ត្រូវបានសម្លាប់ដោយសារតែគាត់គឺជា «អ្នកចូលរួមពាក់កណ្តាល» ។ តុលាការបានសម្រេចថា «វត្តមាននៃហេតុផលដែលជំរុញឲ្យមានការសម្លាប់ ណរ ជាឧទាហរណ៍ ដោយសារតែគាត់មានលាយ (សញ្ជាតិប៊ែលហ្ស៊ិកខ្លះ) គឺជាចេតនាប្រល័យពូជសាសន៍របស់ឃាតករ» ។

ខ) ក្រុមដែលទទួលបានការការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍

នៅក្នុងករណី ក្រាទីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានរកឃើញថា ក្រុមដែលទទួលបានការការពារគឺជាក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ។ ប៉ុន្តែ តុលាការនៅ រូតាហ្គានដា បានលើកឡើងថា «ទស្សនៈនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ និងសាសនា ត្រូវបានគេយកទៅសិក្សាស្រាវជ្រាវយ៉ាងទូលំទូលាយ ប៉ុន្តែនៅពេលបច្ចុប្បន្ន មិនមាននិយមន័យច្បាស់លាស់ណាដែលត្រូវបានគេទទួលស្គាល់ជាទូទៅនិងជាលក្ខណៈអន្តរជាតិទេ» ។

អាកាយេស៊ូ គឺជាករណីទីមួយដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាត្រូវដោះស្រាយ ដើម្បីសម្រេចថាតើក្រុមជនរងគ្រោះទុតស៊ីអាចជាក្រុមទទួលបានការការពារដោយអនុសញ្ញាក្រុងហ្សឺណែវដែរឬទេ? តុលាការបានចាប់ផ្តើមវិភាគដោយបង្កើតនិយមន័យក្រុមជាតិពន្ធុ ពូជសាសន៍ និងជាតិដែលក្រោយមកត្រូវបានយកមកប្រើប្រាស់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ តុលាការបានឲ្យនិយមន័យក្រុមជាតិពន្ធុថាជា «ក្រុមមួយដែលមានសមាជិកនិយាយភាសាដូចគ្នា និងមានវប្បធម៌ដូចគ្នា» ។ ក្រុមពូជសាសន៍គឺ «ពឹងផ្អែកទៅលើលក្ខណៈដែលបន្សល់ទុកពីឪពុកម្តាយ ដែលត្រូវបានសម្គាល់នៅក្នុងទីតាំងភូមិសាស្ត្រណាមួយ» ។ «ក្រុមជាតិត្រូវបានគេកំណត់ថាជាក្រុមមនុស្សដែលមានសញ្ជាតិ សិទ្ធិ និងករណីយកិច្ចដូចគ្នា» ។ បញ្ហាដែលតុលាការបានជួបប្រទះគឺការបំបែកក្រុមជនរងគ្រោះទុតស៊ីចេញពីក្រុមហ៊ូទូដោយផ្អែកទៅលើមូលដ្ឋាននៃនិយមន័យទាំងនេះ ពីព្រោះទាំងហ៊ូទូ និងទុតស៊ី មានទំនៀមទម្លាប់ ភាសា និងរូបរាងដូចគ្នា ។ ជាងនេះទៅទៀត ក្រុមទាំងពីរនេះរស់នៅក្នុងតំបន់ដូចគ្នា ។ បើតាមនិយមន័យ ក្រុមទាំងពីរនេះអាចជាក្រុមដែលមានជាតិពន្ធុ សាសនា និងជាតិដូចគ្នា ។ ***(នៅមានត)***

**ជេមស៍ ស៊ី. រ៉ូប៊ីត**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ផតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។* **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ការិយាល័យជួយជនរងគ្រោះនៅសាលាក្តីខ្មែរក្រហមត្រូវការម្ចាស់ជំនួយច្រើនជាងមួយ

សំណេរនេះសរសេរឡើងដើម្បីធ្វើការអបអរដល់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមចំពោះការដែលបានចេញដីកាដំណោះស្រាយដែលជាការទន្ទឹងរង់ចាំជាយូរមកហើយនោះ ។ ដីកានេះធ្វើការចោទប្រកាន់ទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់ ដូចជា អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន និង នួន ជា ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសនានាដែលមានចែងនិងផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។

ការចេញដីកាដំណោះស្រាយមានន័យថា សវនាការនឹងអាចកើតមានក្នុងអំឡុងពេលឆាប់ៗដែលនេះជារឿងមួយសំខាន់បំផុតសម្រាប់ជនរងគ្រោះ ។ ក្នុងសំណុំរឿងនេះ តុលាការបានប្រមូលសំណុំឯកសារទាំងមូលចំនួន៣៥០.០០០ទំព័រ ហើយបានធ្វើការស្ទាបស្ទង់ផ្នែកប្រជាសាស្ត្រដែលបញ្ជាក់ថា មានការស្លាប់បាត់បង់ជីវិតមនុស្សប្រមាណពី ១,៧ លាន ដល់ ២,២ លាននាក់ ដែលក្នុងការស្លាប់ទាំងនោះមានមនុស្សប្រហែល៨០០.០០០ នាក់បានស្លាប់ដោយសារអំពើហិង្សា ។

ខណៈពេលដែលអបអរសាទរដល់តុលាការ ខ្ញុំក៏មានការព្រួយបារម្ភផងដែរចំពោះចំនួនដើមបណ្តឹងរដ្ឋប្បវេណីដ៏ច្រើនសន្ធឹកសន្ធាប់ដែលនឹងចូលរួមនៅក្នុងដំណើរការនីតិវិធីនេះ ។ នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់តុលាការកាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ បានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.១២៣នាក់ ក្នុងចំណោមអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៩៨៨ នាក់ ត្រូវបានប្រកាសទទួលយក ។

ចំនួនជនរងគ្រោះដ៏ច្រើនដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញថា ជនរងគ្រោះមានការពាក់ព័ន្ធសំខាន់ណាស់នៅក្នុងដំណើរការនីតិវិធីនេះ ។ ដោយសារតែបែបនេះ ការរៀបចំគ្រប់គ្រងចំពោះជនរងគ្រោះដែលចូលរួមទាំងអស់នេះមិនមែនជារឿងមួយងាយស្រួលនោះទេសម្រាប់អង្គភាពគាំពារជនរងគ្រោះរបស់តុលាការ ប្រសិនបើយើងធ្វើការប្រៀបធៀបទៅនឹងចំនួនអ្នកចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ចំនួន ៩០ នាក់នោះ ។

រហូតមកដល់បច្ចុប្បន្ននេះ ការិយាល័យជួយជនរងគ្រោះជាមុខមាត់មួយរបស់តុលាការនៅលើឆាកអន្តរជាតិ ។ ភាពជោគជ័យរបស់អង្គភាពនេះមានន័យថាជាភាពជោគជ័យរបស់តុលាការក៏ដូចជាការចូលរួមរបស់ជនរងគ្រោះផងដែរ នៅក្នុងការស្វែងរកយុត្តិធម៌ជាអន្តរជាតិនេះ ។

អាស្រ័យហេតុនេះ វាគឺជារឿងសំខាន់ខ្លាំងណាស់ក្នុងការធានាឲ្យបានថាការិយាល័យជួយជនរងគ្រោះអាចដោះស្រាយនឹងចំនួនដើមបណ្តឹងរដ្ឋប្បវេណីដ៏ច្រើនបែបនេះ ។ ការិយាល័យនេះត្រូវការជំនួយយ៉ាងច្រើនពីសំណាក់ម្ចាស់ជំនួយផ្សេងៗក៏ដូចជាតុលាការផ្ទាល់ផងដែរ ។ រហូតមកដល់ពេលនេះ មានតែប្រទេសអាល្លឺម៉ង់មួយប៉ុណ្ណោះដែលជាអ្នកផ្តល់ជំនួយផ្ទាល់ ។ ដូច្នេះការិយាល័យនេះត្រូវការការគាំទ្រពីម្ចាស់ជំនួយផ្សេងៗទៀតផងដែរ ។

ក្នុងអំឡុងនៃសំណុំរឿង០០១ អង្គភាពនេះជួបស្ថានភាពល្អផងអាក្រក់ផង ។ ហើយក្នុងករណីនៃសំណុំរឿង០០២នេះវិញគឺជាឱកាសមួយសំខាន់ណាស់សម្រាប់អង្គភាពនេះធ្វើការបញ្ជាក់បង្ហាញជូនដល់ជនរងគ្រោះថា អង្គភាពនេះត្រូវបានបង្កើតឡើងដើម្បី និងសម្រាប់ប្រជាជនទាំងអស់គ្នា ។

ជំនួយនិងធនធានចាំបាច់ត្រូវតែផ្តល់ជូនជាអាទិភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំង២.១២៣ នាក់ ដែលយ៉ាងហោចណាស់ជាអប្បបរមា ។ ឥឡូវនេះ ការលំបាករបស់ការិយាល័យជួយជនរងគ្រោះគឺទាមទារឲ្យមានការដោះស្រាយជាបន្ទាន់ ដោយសារតែធនធានដើម្បីផ្តល់ជូនជនរងគ្រោះរបស់អង្គការក្រៅរដ្ឋាភិបាលផ្សេងៗនោះនៅពេលបច្ចុប្បន្ននេះមានភាពតិចតួចស្តួចស្តើងណាស់ ។ ការិយាល័យជួយជនរងគ្រោះត្រូវការអ្នកផ្តល់ជំនួយច្រើនជាងមួយដើម្បីធ្វើការផ្តល់ជូននូវការចូលរួមមួយដ៏មានអត្ថន័យដល់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាអ្នកប្តឹងធម្មតាផងដែរ ។

**ឌី ឆេរិទ្ធិ**

# វិញ្ញាណចងចាំ

***(តពីលេខមុន)***

***ឡានគ្មានតម្លៃ***

ពេលរៀបចំអីវ៉ាន់រួចរាល់ហើយ ម៉ាក់យកថង់វែងមួយប៉ុនមេជើងដែលមានរាងដូចខ្សែក្រវ៉ាត់ មកឲ្យខ្ញុំពាក់នៅចង្កេះ រួចគាត់ចងយ៉ាងជាប់ ហើយប្រាប់ខ្ញុំថា «កុំឲ្យអ្នកណាឃើញឲ្យសោះ ហើយត្រូវប្រយ័ត្នប្រយែងកុំឲ្យជ្រុះបាត់» ។ ម៉ាក់ធ្វើបែបនេះព្រោះគាត់ខ្លាចយោធាខ្មែរក្រហមឆែករកឃើញ និងដកហូតយករបស់មានតម្លៃរបស់គាត់ ។ ប៉ុន្តែតាមពិតទៅ យោធាខ្មែរក្រហមខ្លះមិនស្គាល់អ្វីជាមាសពេជ្រនោះទេ អ្វីដែលគេចង់បានបំផុតនោះគឺនាឡិកាដៃម៉ាក CITIZEN ប៉ុណ្ណោះ ។ ចែថា និង នឹងដៀប (ត្រូវជាបងថ្លៃខ្ញុំ) បានរៀបចំអីវ៉ាន់ដាក់ពេញមួយឡាន និងពេញមួយរ៉ឺម៉កដែលមាន គូឈុន និង គូវ៉ា ជាអ្នកជិះម៉ូតូ CL អូស ។ យើងធ្វើដំណើរតាមផ្លូវជាតិលេខប្រាំ ប៉ុន្តែមុននឹងចេញដំណើរទៅ ប៉ា ម៉ាក់ បានគិតគ្នាថា តើគួរទៅនៅទីណា? បន្ទាប់ពីពិភាក្សាគ្នាហើយ យើងក៏សម្រេចថាត្រូវទៅនៅផ្ទះកុង ខាងម៉ាក់ខ្ញុំ គឺកុងស៊ិន់ (យើងហៅចាំមាត់ថា កុងនៅភូមិអូរឡោង) ។ ក្រោយមក ខ្ញុំបានឮចាស់ៗនិយាយថា មានអ្នកខ្លះបានបង្ខំចិត្តលោតទឹកសម្លាប់ខ្លួនតែម្តង ដោយសារការសោកស្តាយទ្រព្យសម្បត្តិរបស់ខ្លួន ព្រោះពេលដែលចេញពីផ្ទះនៅភ្នំពេញនោះមិនបានយកសម្ភារៈមកតាមខ្លួនទេ គឺប្រមូលយកតែលុយប្រុកបាវយកតាមខ្លួនប៉ុណ្ណោះ ។ ប៉ុន្តែ ពេលចេញពីទីក្រុងបានបន្តិចទើបយើងដឹងថា ខ្មែរក្រហមបំបាត់មិនឲ្យចាយលុយ ។ មកដល់គីឡូម៉ែត្រលេខប្រាំមួយ ស្រាប់តែយោធាខ្មែរក្រហមឃាត់ ចែថា មិនឲ្យយកឡាន និងម៉ូតូទៅជាមួយទេ ពេលនោះយើងក៏រើអីវ៉ាន់ចេញពីឡាន ប៉ុន្តែយើងមានសំណាងល្អដោយសារ គូឈុន បានយកកង់ និងរ៉ឺម៉ក ទៅជាមួយ ។ ពេលនោះ យើងបានជញ្ជូនអីវ៉ាន់ដាក់លើរ៉ឺម៉កកង់ ដោយមានគូវ៉ាអ្នករុញពីក្រោយ ហើយ បងរិត និង គូឈុន ជាអ្នកអូសកង់ពីមុខ ។

***ហែលទឹកក្អួចបាយ***

យើងឈប់នៅព្រែកក្តាមរង់ចាំស្រឡាងចម្លងទៅត្រើយម្ខាងទៅផ្ទះ កុងស៊ិន់ នៅភូមិអូរឡោង ។ ប៉ុន្តែយើងបង្ខំចិត្តស្នាក់នៅព្រែកក្តាមមួយរយៈ ព្រោះពេលនោះមានមនុស្សកកកុញរាប់ម៉ឺននាក់រង់ចាំស្រឡាងមកចម្លងដូចយើងដែរ ។ នៅទីនោះ ខ្ញុំសប្បាយណាស់ដោយសារបានហែលទឹកទន្លេ ព្រោះតាំងពីតូចមកខ្ញុំកម្របានលេងហែលទឹកដូច្នេះណាស់ ។ រាល់ថ្ងៃ ខ្ញុំបានចុះហែលទឹកលេង ប៉ុន្តែពេលហែលម្តងៗខ្ញុំមិនដែលភ្លេចយកដៃខ្ញុំស្ទាបចង្កេះខោទេ ព្រោះខ្លាចរហែកក្រណាត់ធ្លាក់គ្រឿងមាសពេជ្រដែលម្តាយខ្ញុំចងភ្ជាប់នៅចង្កេះចូលក្នុងទន្លេ ។ ពេលលិបទឹកម្តងៗ ខ្ញុំឮសូរសំឡេងពេជ្រទង្គិចគ្នាក្រឹបៗ ខ្ញុំក៏ប្រញាប់ប្រញាល់យកដៃស្ទាបចង្កេះខោភ្លាមព្រោះខ្លាចជ្រុះបាត់ ។

ខ្ញុំនៅចាំថា កាលពីខ្ញុំនៅក្មេងៗ ខ្ញុំបានចុះទៅលេងទឹកទន្លេជាមួយនឹងបងប្អូនខ្ញុំ និងក្មេងៗជាច្រើននាក់ ។ យើងលេងយកភក់ទន្លេគប់គ្នាទៅវិញទៅមកចាប់តាំងពីម៉ោង៨ព្រឹក រហូតដល់ពេលរសៀល ។ យើងលេងសប្បាយរហូតភ្លេចទៅផ្ទះហូបបាយ ។ ពេលមិនឃើញកូនៗនៅផ្ទះ ប៉ាបានជិះម៉ូតូ MOBILETTE ដើររកយើងស្ទើរសព្វទីកន្លែងនៅតែរកមិនឃើញ ស្រាប់តែពេលគាត់ជិះមកដល់ច្រាំងទន្លេ គាត់ក៏ក្រឡេកឃើញក្មេងៗមួយហ្វូងកំពុងលេងទឹក ។ ប៉ាក់រំពៃមើលក៏ស្គាល់ច្បាស់ថាកូនៗ ទើបគាត់ឲ្យក្មេងម្នាក់ចុះទៅហៅខ្ញុំឡើងមកវិញ ។ ពេលយើងឡើងមកដល់លើច្រាំងទន្លេ ប៉ាមិននិយាយស្តីមួយម៉ាត់ទេ គាត់គ្រាន់តែបញ្ចេញទឹកមុខមាំ ធ្វើឲ្យបងប្អូនខ្ញុំភ័យខ្លាចយ៉ាងខ្លាំង ។ មកដល់ផ្ទះ ប៉ាបានឲ្យយើងងូតទឹករួចឲ្យហូបបាយឆ្អែត បន្ទាប់មកគាត់ឲ្យបងប្អូនខ្ញុំអង្គុយបត់ជើងទល់មុខគ្នា ។ ខ្ញុំភ័យខ្លាំងណាស់ព្រោះមិនបានដឹងថាមានរឿងអ្វីកើតឡើងនោះទេ ។ ប៉ាស្រឡាញ់កូនៗណាស់ ហើយគាត់ក៏មិនដែលវាយកូនដែរ ម្ល៉ោះហើយកូនៗក៏ស្រឡាញ់គាត់ ហើយក៏ខ្លាចគាត់ណាស់ដែរ ។ ប៉ាបានចូលទៅក្នុងបន្ទប់ទាញយកខ្សែក្រវ៉ាត់គាត់មកលាហើយវាយយ៉ាងខ្លាំងទៅលើក្តារក្រាលផ្ទះជិតកន្លែងខ្ញុំអង្គុយ ពេលនោះខ្ញុំភ័យស្ទើរស្លន់ ប៉ុន្តែប៉ាមិនបានវាយខ្ញុំទេ ដោយគាត់

គ្រាន់តែបំភ័យកូនៗប៉ុណ្ណោះ ។ ប៉ាបានឲ្យខ្ញុំសរសេរកិច្ចសន្យាមួយមកឲ្យ គាត់ដោយបញ្ជាក់ថា «ឈប់ទៅលេងទឹកទន្លេទៀតហើយ» ។ ប៉ាធ្វើដូច្នេះ ព្រោះគាត់ខ្លាចកូនលង់ទឹកស្លាប់ចោលគាត់ ។ ចាប់តាំងពីពេលនោះមក ខ្ញុំលែងបានស្គាល់ទឹកទន្លេដូចក្មេងៗឯទៀតហើយ ហើយទោះបីពេលក្មេងៗទាំងនោះបបួលខ្ញុំទៅលេងទឹកក៏ដោយ ក៏ខ្ញុំពុំដែលហ៊ានក្បត់នឹងការសន្យារបស់ខ្ញុំចំពោះប៉ាខ្ញុំដែរ ។

## គូរ៉ាចុកពោះ

យើងបានឆ្លងស្រឡាងពេលស្បៀយមនុស្សបន្តិច រួចហើយយើងនាំគ្នាបន្តដំណើរទៅមុខទៀត ។ យើងទាំងអស់គ្នាត្រូវដើរថ្មើរជើងព្រោះខ្មែរក្រហមបានដកហូតយកឡាននិងម៉ូតូអស់ហើយ លើកលែងតែកុងខ្ញុំ និង បងពៅ ត្រូវជិះលើរ៉ឺមកម្តងម្កាល ព្រោះគាត់ស៊ិតជើងដោយសារកើតជំងឺ ប៉ូលីយ៉ូតាំងពីតូចមក ហើយគាត់ដើរមិនបានឆ្ងាយដូចគេទេ ។ ខ្ញុំនិងប្អូនប្រុស អាញ៉ នាំគ្នាដើរទន្ទឹមប៉ា ពេលនោះ ប៉ាប្រាប់ខ្ញុំឲ្យរាប់ជំហានថាតើបានប៉ុន្មានជំហាន ហើយជារឿយៗខ្ញុំតែងប្រាប់គាត់ថាដើរបានប៉ុណ្ណេះប្ប៉ុណ្ណេះជំហាន ។ ក្រោយមកទើបខ្ញុំដឹងថា តាមការពិតប៉ាឲ្យខ្ញុំរាប់ដើម្បីបន្ធូរកុំឲ្យខ្ញុំមានអារម្មណ៍នឿយហត់ប៉ុណ្ណោះ ។ យើងដើរជាច្រើនយប់ច្រើនថ្ងៃ ហើយថ្ងៃមួយនោះ គូរ៉ា និង គូឈុន ដែលជាអ្នកអូសរ៉ឺម៉កយូរជាងគេក្រោមកម្តៅថ្ងៃខែចែត្រ រកទឹកផឹក ប៉ុន្តែយើងពុំមានទឹកទេ ហើយក៏មិនអាចរកទឹកស្អាតផឹកបានដែរ ព្រោះមានមនុស្សរាប់ម៉ឺននាក់នៅតាមផ្លូវដណ្តើមទឹកគ្នាផឹក ។ ដើរបានឆ្ងាយបន្តិច យើងទំរំពៃរកទីណាដែលមានទឹក ប៉ុន្តែយើងមិនបានជួបប្រទះទេ ម្នាក់ៗស្រេកទឹកឡើងស្ងួតមាត់ស្ងួតក ។ ក្រោយមក ស្រាប់តែចៃដន្យល្អ យើងមកដល់កន្លែងមួយមានថ្លុកក្របីមួយមានទឹកឡើងល្អក់ដែលពោរពេញដោយមេរោគ ព្រោះមានអាចម៍ក្របី ព្រមទាំងមានកាកសំណល់សំរាមទៀតផង ។ ដោយសារ គូរ៉ា ស្រេកទឹកខ្លាំងពេក គាត់ក៏យកក្រមាដាក់ចូលក្នុងទឹកនោះធ្វើជាចម្រោះហើយឱនបឺតមួយចម្អែត ហើយស្រែកថា «អាតូចមិនដែលឈឺអាធំទេ!» ។ ពេលនោះ យើងមិនហ៊ានផឹកទេ ប៉ុន្តែយើងដងយកទឹកខាងលើយកមកច្រោះ រួចដាក់ដាំឲ្យពុះទើបនាំគ្នាផឹក រួចហើយក៏បន្តដំណើរទៅមុខទៀត ។ ពេលស្អែកឡើង គូរ៉ា ដែលផឹកទឹកនោះចាប់ផ្តើមឈឺគ្រុនក្តៅផង រាគផង ដោយសារមេរោគក្នុងទឹកផ្ទឹកក្ដ ។ យើងត្រូវផ្អាកការធ្វើដំណើរដើម្បីជួយគូរ៉ា ពេលនោះសំណាងល្អដោយសារបងថ្លៃខ្ញុំជាគ្រូពេទ្យបានយកថ្នាំពេទ្យមួយចំនួនមកជាមួយ ហើយក៏ចាក់ឲ្យគាត់បានជាសះស្បើយ ទើបបន្តដំណើរទៅមុខទៀត ។

## បាត់កុងរហូត

នៅវេលាម៉ោងប្រមាណជាប្រាំមួយល្ងាច យើងមកដល់បាធាយ ក៏នាំគ្នាឈប់សម្រាកដាំបាយហូប ។ ខ្ញុំចាំថា ពេលនោះ ទ្រាកៅ (ឪពុកមា) ដែលរស់នៅឃុំស្ពឺ ស្រុកចម្ការលើ បានឲ្យកូនប្រសាគាត់ ហ៊ាកុងវិន (បង) យកម៉ូតូឌុបគាត់ដើររកបងប្អូន ហើយចៃដន្យក៏បានជួបយើងនៅម្តុំបាធាយនេះ ។ ទ្រាកៅចូលមកសំណេះសំណាលលេង ហើយប្រាប់ព័ត៌មានខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុង ហើយឲ្យអ្នកទីក្រុងទៅធ្វើស្រែចម្ការវិញ ។ ពេលនោះដោយសារ ទ្រាកៅ ឃើញកុងខ្ញុំចាស់ជរាពិបាកដើរផ្លូវឆ្ងាយ គាត់ហៅកុងឲ្យទៅនៅជាមួយគាត់ ព្រោះទ្រាកៅ មានសិទ្ធិដើរបានច្រើនកន្លែង ចំណែកកូនប្រសាគាត់ទាំងអស់សុទ្ធសឹងជាកម្មាភិបាលខ្មែរក្រហម ។ កុងខ្ញុំមិនចង់ទៅទេព្រោះគាត់មិនចង់បែកពីប៉ា តែដោយសារប៉ាជំរុញខ្លាំងព្រោះឃើញគាត់ពិបាក ទើបកុងសុខចិត្តឡើងជិះម៉ូតូជាមួយ ទ្រាកៅ ទៅនៅឃុំស្ពឺ ស្រុកចំការលើ ។ ចាប់តាំងពីពេលនោះមក ខ្ញុំលែងបានឃើញមុខគាត់រហូត ហើយសូម្បីតែដំណឹងថាគាត់ស្លាប់នៅកន្លែងណាក៏ខ្ញុំពុំដឹងផង ។

## អូរឡោងភូមិថ្មី

ស្អែកឡើងយើងចាប់ផ្តើមបន្តដំណើរទៅមុខ ។ មកដល់ម្តុំភូមិខិតធំ គូឈុន បានបែកពីយើងទៅរស់នៅជុំគ្នាជាមួយប្រពន្ធកូនគាត់ ដែលកាលមុននោះប្រពន្ធ គូឈុន បានខឹងនឹង គូឈុន ហើយរត់មកនៅផ្ទះបងគាត់នៅភូមិនេះវិញ ។ ឥឡូវនេះ យើងនៅសល់តែ១៥នាក់ប៉ុណ្ណោះមាន ៖ ប៉ា, ម៉ាក់, ប៉ិសែ (ឪពុកអាឌី), នឹងជៀប, ចៃថា, ចៃស្រី, បងមុំ, បងពៅ, ខ្ញុំ, អាញ៉ និងក្មួយបីនាក់ទៀតគឺ អាភ៉ាត, អាវ៉ែន និងអាវ័ត្ត ហើយនិង បងរិត និងគូរ៉ា ។ នៅតាមផ្លូវពីភ្នំពេញមកកំពង់ចាមមានរឿងរ៉ាវជាច្រើនដែលមនុស្សមិនគួរឃើញ ជាពិសេសក្មេងៗដែលនៅមានវ័យស្របាលខ្ញុំ ។ ខ្ញុំឃើញមនុស្សចាស់ក្មេងឈឺស្លាប់ហើយត្រូវគេ

យកទៅបោះចោលតាមផ្លូវ ស្ពឹកផ្លូវទន្លេតាមទីវាល និងឃើញខ្មោចមនុស្សស្លាប់តាមដងផ្លូវថ្ងៃក្តៅឡើងក្រៀមស្វិត ខ្លះហើមស្អិតខ្មោចខ្លះទៀតត្រូវឡានបរកិនឡើងសំប៉ែត ។ មកដល់ព្រែកទឹង យើងធ្វើដំណើរចុះមករកដងទន្លេពាមជីកងដើម្បីជិះទូកឆ្លងទៅកាន់ត្រើយម្ខាងដែលខ្ញុំស្គាល់ថា ភូមិអូរឡោង ដើម្បីរកផ្ទះ កុងស៊ិន ។

ពេលមកដល់ផ្ទះ កុងស៊ិន យើងហាក់សប្បាយចិត្តព្រោះបានជួបជុំជាមួយបងប្អូនកូនចៅដែលបែកគ្នារាប់សិបឆ្នាំមកហើយ ។ ដោយសារដី និង ផ្ទះ កុងស៊ិន ធំយើងក៏រៀបចំទីកន្លែងស្នាក់នៅរៀងៗខ្លួន គ្រួសារខ្ញុំស្នាក់នៅខាងក្រោមផ្ទះ ចែថា និងកូនរបស់គាត់ធ្វើរោងជាប់របងនៅខាងមុខផ្ទះ ។ គិតៗទៅក្នុងដីកុងខ្ញុំមានមនុស្ស២៨នាក់រស់នៅ គឺ កុងស៊ិន, យាយឃឹម, ប៉ា, ម៉ាក់, ប៉ុសែ, គូវ៉ា, នឹងជៀប, ចែថា, ចែស្រី, បងពៅ, បងមុំ, ខ្ញុំ, អាញ៉, អាវ៉ា, អាវ៉ែន, អារ័ត្ន, បងរិត ។ គ្រួសារទ្រាកេង មាន ៖ ទ្រាកេង, អ៊ីយាងអ៊ី សៀមគាង, សៀមចេង, សៀមហួង, អាបេ និង អាហៀង ។ គ្រួសារទ្រាយុនហួយ មាន ៖ ទ្រាយុនហួយ អ៊ីទាង និងកូនពីនាក់គឺ អាទី និងម្នាក់ទៀតខ្ញុំមិន ចាំឈ្មោះ ។ ពេលនោះប្រធានភូមិបានមកកត់ឈ្មោះគ្រួសារយើងទាំងអស់ដែលទើបនឹងមកដល់ថ្មី ហើយក៏ចាប់ផ្តើមបែងចែកមនុស្សឲ្យចូលធ្វើការតាមក្រុម ដោយប្រុសទៅខាងក្រុមប្រុសៗ ស្រីទៅខាងក្រុមស្រីៗ និងក្មេងៗទៅខាងក្រុមក្មេង ។ ប៉ាពុំដែលធ្លាប់ធ្វើការងារធ្ងន់ទេពេលនេះ ប្រធានភូមិឲ្យគាត់គាស់គល់ឈើដើម្បីវានយកដីធ្វើស្រែ ម៉ាក់គេឲ្យប្រូតកក់ធ្វើកន្ទេល មនុស្សប្រុសពេញកម្លាំងខ្មែរក្រហមឲ្យធាក់រហាត់ទឹក ចំណែកក្មេងៗត្រូវដើររើសអាចម៍គោ និងកាប់ដើមទន្រ្ទានខែត្រធ្វើជី ។ ក្រៅពីធ្វើការងារ ខ្ញុំក៏បានចូលរៀននៅសាលាក្នុងវត្តមួយរយៈដែរ ។ នៅទីនោះ យើងទាំងអស់គ្នាត្រូវចេញទៅធ្វើការទាំងអស់គ្នា គ្មានអ្នកណាម្នាក់អាចនៅទំនេរបានទេ សូម្បីតែ បងពៅ ដែលមានជើងដៃពិការ ដោយសារជំងឺប៉ូលីយ៉ូក៏ត្រូវទៅធ្វើការដែរ ។

## វិន័យអង្គការ

ក្នុងការរស់នៅក្នុងភូមិអូរឡោង ខ្មែរក្រហមបានចាត់ទុកយើងជាប្រជាជន១៧មេសា ឯអ្នកស្រុករស់នៅទីនោះយូរហើយគេហៅប្រជាជនមូលដ្ឋាន ។ សូម្បីតែបងប្អូនជីដូនមួយខ្ញុំទាំងប្រុសទាំងស្រីក៏គេចាប់ផ្តើមមានអារម្មណ៍ស្អប់គ្រួសារយើងដែលទើបជម្លៀសទៅដល់ថ្មីដែរ ដោយគេហៅយើងថា «ពួកអាឈ្លើយសឹក» នៅពេលស្តាប់ពាក្យនេះខ្ញុំខឹងណាស់ ប៉ុន្តែពុំដែលហ៊ាននិយាយអ្វីទេ ។ ចំណែក អ៊ីយាង នៅពេលនោះសូម្បីតែយើងលុបមុខដោយប្រើទឹកច្រើនក៏គាត់ស្តីឲ្យយើងដែរ ហើយមានម្តងនោះ អ៊ីយាង បានជៀមដាមដាក់ប៉ាខ្ញុំទៀតផង ។ ខ្ញុំដឹងថា ប៉ាអន់ចិត្តខ្លាំងណាស់ ព្រោះពីដើមមកគាត់ជាអ្នកមានមុខមាត់នៅក្នុងក្រុងកំពង់ចាមដែរ ហើយបងប្អូនទាំងអស់ធ្លាប់តែគោរពកោតខ្លាចគាត់ ពុំគួរណាពេលនេះធ្លាក់ខ្លួនដល់បងប្អូនមើលស្រាលគាត់ដូច្នេះទេ ។ ខ្ញុំមើលទៅប៉ាពុំអស់ចិត្តនឹង អ៊ីយាង ដែលនិយាយបញ្ឆិតបញ្ឆៀងឲ្យគាត់សោះ ។ ចំណែកបងស្រីខ្ញុំទាំងអស់ត្រូវអង្គការបង្ខំឲ្យកាត់សក់ខ្លីទាំងអស់គ្នាដោយមិនអនុញ្ញាតឲ្យនរណាម្នាក់ទុកសក់វែងទេ ។ ពេលនោះ ចែស្រី យំស្តាយសក់របស់គាត់ និងពុំព្រមកាត់ទេរហូតដល់ប្រធានភូមិគំរាមដាក់ទោសទើបគាត់យល់ព្រមកាត់ ។ ស្រីៗទាំងអស់ត្រូវតែទុកសក់ខ្លីត្រឹមក ដោយពុំមាននរណាម្នាក់ហ៊ានប្រឆាំងនឹងបញ្ជារនេះបានឡើយ ។ មនោគមន៍របស់ខ្មែរក្រហមបានបំផុសឲ្យប្រជាជនមានការបែងចែករវាងអ្នកទៅពីទីក្រុង និងអ្នកស្រុកក្នុងមូលដ្ឋានដែលធ្វើឲ្យមានការស្អប់ខ្ពើមគ្នាយ៉ាងខ្លាំង សូម្បីតែបងប្អូនខ្ញុំដែលមុននេះស្រឡាញ់រាប់អានគ្នាស្និទ្ធស្នាល ក៏ពេលនោះក្លាយទៅជាសត្រូវនឹងគ្នាដែរហើយរាល់ការងារអ្វីដែលអ្នកនៅមូលដ្ឋានយល់ថា យើងអ្នកថ្មីធ្វើមិនល្អគេរាយការណ៍ទៅកាន់អង្គការឲ្យហៅយើងទៅអប់រំភ្លាម ។

## រងរបួសដោយសារសត្វកំប្រុកស្រែ

ក្នុងពេលរស់នៅជាមួយនឹង កុងស៊ិន ខ្ញុំបានបង្កឲ្យមានរឿងដល់ខ្លួនឯងបិះនឹងស្លាប់ម្តងជាពីរដងទៅហើយ ព្រោះពេលមកដល់ផ្ទះ កុងស៊ិន បានប៉ុន្មានថ្ងៃបង រិត ធ្វើជំពាមកៅស៊ូទុកបាញ់សត្វ ។ ថ្ងៃមួយពេល ខ្ញុំ និង បងរិត ដើរទៅក្រោយផ្ទះ កុងស៊ិន ស្រាប់តែឃើញសត្វកំប្រុកមួយក្បាលលើមែកឈើ ពេលនោះបងរិត ក៏យិតជំពាមកៅស៊ូជាមួយគ្រាប់ដីលញ់បាញ់ទៅចំខ្លួនសត្វកំប្រុកនោះ ធ្វើឲ្យវាស្រងល់ធ្លាក់មកដល់ដី យើងក៏រត់ទៅចាប់វាប៉ុន្តែពេលយើងរត់ជិតដល់វាក៏រត់ឡើងលើដើមល្មុតវិញ ។ ខ្ញុំ និងបងរិត បានស្ទុះរត់ដេញចាប់សត្វកំប្រុកនោះ ប៉ុន្តែចៃដន្យខ្ញុំរត់ទាក់

នឹងបន្ទាលួសមុតជាប់ក្លៅខាងស្ដាំ ហើយពេលដកដែកលួសចេញមកក្រៅមានចេញខ្លាញ់ និងឈាមហូរមកជាមួយដែរ ។ ចំណែកបង រិត ក៏មុតបន្លាលួសជាប់នឹងកំភួនជើងដែរ ។ ខ្ញុំឈឺចុកចាប់យ៉ាងខ្លាំង ប៉ាយកថ្នាំមកលាងមុខរបួសនិងបិទមុខរបួសឲ្យខ្ញុំ ។ ស្អែកឡើង ខ្ញុំ និង បងរិត ចាប់ផ្ដើមក្ដៅខ្លួនយ៉ាងខ្លាំង ព្រោះមេរោគតេតាណុសធ្វើទុក្ខ ។ សំណាងល្អ ចែថា នៅសល់ថ្នាំមួយដបចាក់ឲ្យយើងទាំងពីរនាក់ ប្រសិនបើគ្មានថ្នាំព្យាបាលទេនោះ ខ្ញុំស្លាប់តាំងពីអាយុ១៣ឆ្នាំបាត់ទៅហើយ ។

## បេះត្រកួនឈ្លក់ទឹក

ក្រោយមក នៅរដូវទឹកឡើងខ្ញុំដើរទៅបឹងក្រោយផ្ទះ ខ្ញុំឃើញត្រកួនឈ្លក់ទឹកដុះត្រួយខ្ចីៗ ខ្ញុំក៏ដើរដកយកមកផ្ទះឲ្យម៉ាក់ស្ល ។ ខ្ញុំដកបានមួយបាច់ធំ ហើយក៏ដើរកាត់ទឹកត្រឹមកទៅដកត្រកួនបន្ថែមទៀត ស្រាប់តែពេលនោះខ្ញុំធ្លាក់ចូលទៅក្នុងប្រឡាយលិចក្បាល ។ ខ្ញុំឈ្លក់ទឹក និងដកដង្ហើមមិនបាន ហើយនៅសល់តែបន្តិចទៀតខ្ញុំដាច់ដង្ហើមស្លាប់បាត់ ។ ប៉ុន្តែវាសនាល្អ ពេលលិចចុះទៅបាតក្រោម ស្រាប់តែជើងខ្ញុំប៉ះដី ខ្ញុំក៏ខំធាក់ឡើងមកលើ និងយកដៃកាយទឹកទៅក្រោយទើបមកដល់កន្លែងរាក់វិញ ។ ខ្ញុំនឹកឃើញដល់រឿងដែលប៉ាមិនឲ្យលេងទឹកព្រោះខ្លាចលង់ស្លាប់ ហើយចាប់តាំងពីពេលនោះមក ខ្ញុំមិនចេះហែលទឹកទេ ។ ពេលនោះរដូវអត់ឃ្លានបានចូលមកដល់ ខ្មែរក្រហមតម្រូវឲ្យពួកយើងដាំបាយលាយជាមួយនឹង ពោត សណ្ដែក ឬគល់ចេក ខ្ញុំនឹកក្នុងចិត្តថាតើគេហូបយ៉ាងម៉េចកើតទៅ? សូម្បីតែអង្ករដែលយើងដាំបាយហូបរាល់ថ្ងៃ ខ្ញុំពុំដឹងថាគេបានមកពីណាឬធ្វើពីអ្វីផង ទើបតែពេលនេះខ្ញុំដឹងពីរសជាតិរបស់វា ។ សម្រាប់ក្មេងៗដូចខ្ញុំ ពុំសូវយល់បញ្ហារាក់ជ្រៅទេ ហើយក៏ខ្ញុំមិនដឹងថាទុក្ខវេទនាការគ្រាំគ្រាក្នុងចិត្តរបស់ប៉ាម៉ាក់យ៉ាងណានោះដែរ ។

## ដីដំបូក

បងប្អូន និងគ្រួសារខ្ញុំ រស់នៅក្នុងផ្ទះ កុងស៊ិន អស់រយៈជិតមួយឆ្នាំ ប្រធានភូមិក៏មកប្រាប់យើងឲ្យចេញពីភូមិ ពេលនោះប៉ាម៉ាក់រៀបចំអីវ៉ាន់ម្ដងទៀត ។ ពេលរៀបចេញដំណើរ ខ្ញុំឃើញប៉ាម៉ាក់ទៅលា កុងស៊ិន ហើយ កុងស៊ិន ក៏ហុចដីដំបូកមួយដុំមកឲ្យម៉ាក់ ព្រមទាំងផ្ដាំថា «ត្រូវនឹកដល់គុណព្រះធរណី បើទៅដល់ស្រុកចាញ់ត្រូវយកដីដំបូកនេះទៅដាក់ដាំទឹកផឹកទៅនឹងបានជាសះស្បើយ» ។ នេះគឺជាលើកទីពីរនៃការជម្លៀសអ្នក១៧មេសា (ប្រជាជនថ្មី) ឲ្យទៅតាមខេត្តផ្សេងៗដែលអង្គការបានកំណត់ ហើយពេលនោះគ្រួសារខ្ញុំត្រូវធ្វើដំណើរទៅកាន់ខេត្តកំពង់ធំ ។ ខ្ញុំបានឮប៉ានិងចាស់ៗពិគ្រោះគ្នាពីការធ្វើដំណើរ ហើយពេលនោះចាស់ៗមួយចំនួនបានលើកឡើងថាខេត្តនោះសម្បូរស្រូវ អង្ករ ត្រីសាច់សម្រាប់ហូបណាស់ព្រោះជាខេត្តសម្បូរដីស្រែនិងមានស្ទឹងត-ភ្ជាប់ពីបឹងទន្លេសាប ហើយមធ្យោបាយធ្វើដំណើរក៏មានច្រើនទៀត ។ មកដល់ថ្ងៃកំណត់ យើងដឹកអីវ៉ាន់ចេញពីភូមិអូរឡោង ឆ្លងមកពាមជីកង រួចហើយមកឈប់សម្រាកប៉ុន្មានថ្ងៃនៅពាមក្នុងមុំវត្តនិរោធរង្សី ។ ពេលនោះ នៅក្នុងអំឡុងខែវិច្ឆិកា ជារដូវដែលសម្បូរត្រី យើងបានស្ទូចត្រីនៅព្រែកយកមកធ្វើត្រីប្រឡាក់សម្រាប់ហូបតាមផ្លូវទៀតផង ។

## ក្អែបពណ៌ក្រម៉ៅ

ខ្ញុំនៅចាំថា នៅយប់មួយនោះពេលខ្ញុំកំពុងដេកលក់ស្រាប់តែមានសត្វមកទិចខ្ញុំចំដៃខាងឆ្វេងធ្វើឲ្យខ្ញុំចុកចាប់ ហើយខ្ញុំស្រែកយំយ៉ាងខ្លាំង ។ ពេលនោះ ប៉ាស្ទុះមកមើលរួចលើកកន្ទេលឡើងឃើញមានក្អែបមួយធំពណ៌ក្រហមក្រម៉ៅ ហើយគាត់ក៏វាយក្អែបនេះរួចយកទៅបោះចោល ។ ខ្ញុំចុកចាប់កាន់តែខ្លាំងឡើង ប៉ុន្តែពេលនោះ នឹងដៀប មិនហ៊ានយកថ្នាំពេទ្យមកចាក់ឲ្យខ្ញុំទេ ព្រោះគាត់ខ្លាចខ្មែរក្រហមឃើញ រួចហើយចាប់ខ្លួនគាត់ដោយចោទថា ជាខ្មាំងប្រើប្រាស់របស់ចក្រពត្តិ ។ ប៉ាបានដើរទៅរកពេទ្យខ្មែរក្រហមឲ្យមកជួយព្យាបាល ហើយអ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនោះ គឺពេលពេទ្យទាញថ្នាំចេញពីថង់យាម ឃើញដបទឹកក្រូចមីរិនដាពណ៌ផ្កាឈូក រួចយកសឺរ៉ាំងបូមពីក្នុងដបមកចាក់ចំដៃដែលក្អែបខាំនោះតែម្ដង ។ ខ្ញុំនៅតែឆ្ងល់ថាហេតុអ្វីពេទ្យអាចយកទឹកក្រូចមកធ្វើថ្នាំចាក់បាន ប៉ុន្តែតាមពិតជាប្រភេទថ្នាំថ្មីរបស់អង្គការដែលទើបនឹងរកឃើញ ។ អង្គការមិនឲ្យប្រើប្រាស់ថ្នាំរបស់ពួកចក្រពត្តិជាដាច់ខាត ហើយថែមទាំងកម្ទេចចោលនូវសម្ភារៈ និងសមិទ្ធផលគ្រប់យ៉ាងរបស់ចក្រពត្តិទៀតផង ។

## ស្រុកស្ទោងវង់ចាំ

យើងស្នាក់នៅពាមអស់រយៈពេលជាច្រើនយប់ ក៏បន្ត

ដំណើរមកដល់ព្រៃទទឹង ទើបឃើញឡានយោធាខ្មែរក្រហមមកទទួលយើង និងប្រជាជនជាច្រើនគ្រួសារទៀតទៅកាន់ខេត្តកំពង់ធំ ។ ខ្មែរក្រហមបានយកយើងទៅដាក់ចោលនៅម្តុំទីរួមស្រុកស្ទោង ហើយនៅទីនោះ ប្រធានភូមិជាអ្នកទទួលភារកិច្ចមកទទួលប្រជាជនថ្មីឲ្យទៅរស់នៅតាមភូមិរៀងខ្លួនៗ ។ យើងត្រូវបានប្រធានភូមិឲ្យទៅតាំងលំនៅជាមួយអ្នកភូមិចក សង្កាត់កំពង់ចិនខាងជើង ។ ខ្មែរក្រហមបែងចែកឲ្យយើងទៅរស់នៅជាមួយអ្នកមូលដ្ឋានដូច្នេះ គឺដើម្បីងាយស្រួលតាមដានពីសកម្មភាពរស់នៅរបស់យើងដើម្បីរាយការណ៍ទៅប្រធានភូមិ ។ ពេលទៅដល់ដំបូង ចំរដូវរំហើយជាពេលច្រូតកាត់ ហើយមនុស្សទាំងអស់ត្រូវច្រូតស្រូវ បោកបែន ឬបររទេះដឹកកណ្តាប់ស្រូវ ។ អ្នកនៅទីក្រុងខ្លះ ដែលមិនធ្លាប់ធ្វើការងារធ្ងន់ និងលំបាកដូច្នេះ ត្រូវអ្នកមូលដ្ឋានបន្ទោស និងជេរស្តីមិនដាច់ពេលឡើយទម្រាំនឹងចេះធ្វើកិច្ចការនោះ ។ ចំពោះរបបអាហារ អង្គការដាំហូបរួម ហើយបែងចែកឲ្យយើងហូបតែពីរពេលប៉ុណ្ណោះ គឺពេលថ្ងៃត្រង់ និងពេលល្ងាច ។ ទៅដល់ដំបូងម្នាក់ៗនៅមានកម្លាំងកំហែងនៅឡើយ ។ ចំពោះខ្ញុំក្មេងៗ ប្រធានកងឲ្យយើងដើររើសក្រួរស្រូវដែលជ្រុះក្នុងស្រែដោយកំណត់ចំនួនឲ្យយើងរក ហើយបើយើងរើសបានគ្រប់ចំនួនទើបអង្គការចែកបាយឲ្យហូប ប៉ុន្តែបើយើងរើសមិនគ្រប់ទេ អង្គការមិនចែកបាយឲ្យយើងទេ ។

## អាត្ងួ

ថ្ងៃមួយពេលកំពុងធ្វើការ ខ្ញុំមានទំនាស់ជាមួយអាកូនចៅចិនឈ្មោះ អាជា ដែលជម្លៀសមកពីភ្នំពេញដែរ ។ ទំនាស់នេះបានឈានដល់ការវាយតប់គ្នា ហើយខ្ញុំបានបោក អាជា ដួលទៅលើដីរួចសង្កត់កវាជាប់ ហើយទីបំផុតវាក៏សុំចុះចាញ់ខ្ញុំ ដោយពេលនោះមានក្មេងៗនៅមូលដ្ឋាន និងក្មេងដែលជម្លៀសមកពីភ្នំពេញជាច្រើននាក់ឈរមើលយើងវាយគ្នាដែរ ។ កាលនៅពីតូច ខ្ញុំមានមាឌក្រអាញ ហើយស្គាល់រហូតដល់ក្មេងម្នាក់ដែលជម្លៀសទៅពីភ្នំពេញដាក់ងារឲ្យខ្ញុំថា «អាត្ងួ» សំដៅដល់ត្ងួឯកក្នុងខ្សែភាពយន្តចិន ។ ចាប់ពីពេលនោះមកឈ្មោះខ្ញុំចាប់ផ្តើមព្ញពីមាត់មួយទៅមាត់មួយក្នុងចំណោមក្មេងៗក្នុងភូមិ ហើយវាក៏មិនហ៊ានរករឿងឬក្អេងក្អាងដាក់ខ្ញុំទៀតដែរដោយសារវាល្បីថា «ខ្ញុំចេះក្បាច់កាំវ៉ាត់គេ» ។

## សំបកដំឡូង

នៅរដូវច្រូតស្រូវដំបូង យើងមានបាយហូបគ្រប់គ្រាន់ដោយពុំមានការខ្វះអ្វីច្រើនទេ ។ ពេលវេលាចេះតែកន្លងទៅរហូតដល់រដូវធ្លាក់ភ្លៀង ពេលនោះមនុស្សចាស់ និងក្មេងទាំងអស់ត្រូវចេញទៅវាលស្រែ ។ មនុស្សប្រុសមានកម្លាំង ខ្មែរក្រហមឲ្យភ្ជួរស្រែ គាស់គល់ឈើ ដឹកសំណាប កាប់ដី រែកដី លើកទំនប់ ដោយប្រើកម្លាំងមនុស្សទាំងអស់ សូម្បីតែភ្ជួរស្រែក៏ខ្មែរក្រហមឲ្យមនុស្សជាអ្នកអូសនង្គ័លជំនួសគោដែរ ។ ចំណែកស្ត្រីវ័យចំណាស់ ខ្មែរក្រហមឲ្យស្ទូងស្រូវ ចំណែកអ្នកមានប្តីត្រូវទៅរែកដីលើកទំនប់ ។ រដូវវស្សាភ្លៀងធ្លាក់ច្រើន ការងារកាន់តែលំបាក ហើយបាយកាន់តែខ្សត់រហូតដល់ដាំបបររាវកក្កូកឲ្យយើង ហូប ព្រោះបបរមួយខ្ទះត្នោតដាក់អង្ករតែពីបីកំប៉ុងទឹកដោះគោប៉ុណ្ណោះសម្រាប់មនុស្ស៥០-៦០នាក់ ដូច្នេះមិនមានអ្នកណាបានហូបឆ្អែតនោះទេ ។ ពេលមួយ ម៉ាក់បានដើររើសយកសំបកដំឡូងមីដែលគេបោះចោលមកទុកលាយជាមួយនឹងបបរហូបបន្ថែមលើរបបដែលខាងចុងភៅចែកឲ្យ ។ ប៉ាបានប្រាប់ម៉ាក់ថា «សំបកដំឡូងនោះមិនអាចហូបបានទេ វាអាចបណ្តាលឲ្យពុលព្រោះមានមនុស្សក្នុងភូមិច្រើនណាស់ពុល» ។ ពេលនោះ ម៉ាក់តបវិញថា «មិនអីទេ! ខ្ញុំបានលាងនិងត្រាំទឹកជ្រះហើយ» ព្រោះម៉ាក់គិតថា ជាតិពុលវានឹងសាបអស់ជាមិនខាន ។ ក្រោយពេលហូបសំបកឡូងនេះជាមួយនឹងបបររួច យើងគ្រប់គ្នាចាប់ផ្តើមក្អួតចង្អោរ ឈឺក្បាល រាកចុកពោះ លើកលែងតែប៉ា និង បងស្រី ប៉ុណ្ណោះ ។ ពេលនោះ ម៉ាកប្រាប់ប៉ាឲ្យទៅសុំស្ករត្នោតពីចុងភៅយកមកបន្សាបជាតិពុល តែប៉ាគាត់ខឹងខ្លាំងណាស់ព្រោះអីគាត់ប្រាប់ហើយមិនស្តាប់ ។ ទីបំផុត បងស្រីខ្ញុំក៏សុខចិត្តទៅសុំស្ករត្នោតពីចុងភៅ ប៉ុន្តែដំបូងចុងភៅបដិសេធព្រមទាំងបន្ទោសថា «ឲ្យវាងាប់ទៅព្រោះវាស៊ីមិនដឹងអី» ។ បងស្រីខ្ញុំលុតជង្គង់យ៉ាងយូរទើបចុងភៅព្រមឲ្យស្ករប៉ុនមេជើងយកមកចែកគ្នាលិតម្នាក់បន្តិច ដើម្បីបន្សាបជាតិពុល ប៉ុន្តែសំណាងល្អដោយសារជាតិពុលមានកម្រិតទាប កុំអីពួកយើងមុខជាស្លាប់តាំងពីពេលនោះហើយ ។

**(នៅមានត)**

**ថៃ ច័ន្ទរិទ្ធ**

# កែន ឆែម ៖ សៀវភៅស្វែងរកគ្រួសារបានផ្សះផ្សារបួសផ្លូវចិត្តរបស់ខ្ញុំ




កែន ឆែម សព្វថ្ងៃជាមន្ត្រីចូលនិវត្តន៍នៅក្រសួងអប់រំ មានអាយុ៨៥ឆ្នាំ រស់នៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ក្រុងភ្នំពេញ ។ អស់រយៈពេលជាង៣០ឆ្នាំមកហើយ កែន ឆែម រស់នៅឯកោ និងទុក្ខសោកដោយសារការបាត់បង់ប្រពន្ធ និងកូនជាទីស្រឡាញ់របស់គាត់ ។ ប៉ុន្តែពេលនេះ កែន ឆែម បានធូរស្បើយចិត្តជាខ្លាំង នៅពេលដែលគាត់ចុះឈ្មោះប្រពន្ធនិងកូនទាំងប្រាំនាក់នៅក្នុងសៀវភៅស្វែងរកគ្រួសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរំឭកដល់ការចងចាំរបស់គាត់ ។

មុនឆ្នាំ១៩៧៥ ឆែម មានក្រុមគ្រួសារដ៏កក់ក្តៅមួយនៅក្នុងខេត្តកំពង់ស្ពឺ ។ ក្រោយពីខ្មែរក្រហមឡើងកាន់កាប់អំណាច ស្រាប់តែអ្វីៗបានផ្លាស់ប្តូរទាំងស្រុង ។ ពេលនោះ កូនច្បងរបស់គាត់ពីរនាក់ដែលកំពុងតែរៀននៅទីក្រុងភ្នំពេញក៏ត្រូវជម្លៀសឲ្យមកស្រុកកំណើតវិញ ។ ឆែម បានរៀបរាប់ថា ក្រោយពីក្រុមគ្រួសារជួបជុំគ្នាហើយ ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់គាត់ឲ្យទៅរស់នៅឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ នៅទីនោះមិនបានប៉ុន្មានថ្ងៃផង ខ្មែរក្រហមក៏ចាប់ផ្តើមបំបែកសមាជិកគ្រួសាររបស់គាត់ឲ្យទៅរស់នៅតាមកងផ្សេងៗពីគ្នា ដោយគាត់ស្ថិតនៅក្នុងកងយុវជន ប្រពន្ធក្នុងកងនារី កូនដែលពេញវ័យក្នុងកងចល័ត និងកូនតូចៗនៅក្នុងកងកុមារ ។ បន្ទាប់មក ខ្មែរក្រហមបានបង្ខំឲ្យគ្រួសាររបស់ ឆែម ធ្វើការងារធ្ងន់ៗ និងហូបចុកតិចតួចបំផុតព្រោះគ្រួសាររបស់គាត់ត្រូវបានចាត់ទុកជាប្រជាជនថ្មី ។ ដោយសារតែមានការរឹតបន្តឹងខ្លាំង ឆែម មិនត្រូវបានអនុញ្ញាតឲ្យមកលេងផ្ទះ និងមកជួបប្រពន្ធ និងកូនឡើយ ។

នៅឆ្នាំ១៩៧៧ ឆែម បានជួបបងថ្លៃរបស់គាត់ដោយចៃដន្យ ។ នៅពេលនោះ បងថ្លៃរបស់ ឆែម ស្រាប់តែនិយាយប្រាប់គាត់ថា «ប្រពន្ធឯងស្លាប់បាត់ហើយ ដោយសារតែជំងឺហើម» ។ ក្រោយពីឮដំណឹងនេះភ្លាម ឆែម មានអារម្មណ៍តក់ស្លុតយ៉ាងខ្លាំង ព្រោះមិនដែលបានជួបប្រពន្ធទាល់តែសោះ បែរជាឮដំណឹងថាស្លាប់ទៅវិញ ។ មិនទាន់ទាំងបានរសាយចិត្តផង មួយរយៈក្រោយមកទៀត ឆែម ក៏បានទទួលដំណឹងពីបងថ្លៃរបស់គាត់ទៀតថា កូនប្រុសទាំងបួននាក់របស់គាត់បានឈឺស្លាប់អស់ហើយ ។ ក្រោយពីប្រពន្ធនិងកូនទាំងបួននាក់ស្លាប់ទៅ ឆែម លែងខ្វល់ខ្វាយពីអ្វីទាំងអស់ ដោយគាត់គិតតែខិតខំធ្វើការជូនអង្គការទាំងយប់ទាំងថ្ងៃ ថែមទាំងមិនដែលត្អូញត្អែរម្តងណាឡើយ ព្រោះយ៉ាងហោចណាស់ក៏នៅសល់កូនទីបីម្នាក់ឈ្មោះ កែន វុឌ្ឍី ដែលជាក្តីសង្ឃឹមចុងក្រោយរបស់គាត់ដែរ ។ ប៉ុន្តែ ខ្មែរក្រហមមិនបានលើកលែងចំពោះកូនរបស់គាត់ឡើយ ដោយប្រធានកងតែងតែដាស់ វុឌ្ឍី ឲ្យក្រោកតាំងពីម៉ោងបួនទៀបភ្លឺដើម្បីទៅធ្វើការនៅការដ្ឋានដែលមានចម្ងាយប្រហែល៥–៦គីឡូម៉ែត្រពីកន្លែងស្នាក់នៅ ។ នៅទីនោះ អង្គការចាត់តាំង វុឌ្ឍី ឲ្យលើកទំនប់ និងជីកប្រឡាយតាំងពីព្រលឹមរហូតដល់ព្រលប់ទើបត្រឡប់មកផ្ទះវិញ ។ ដោយសារតែមិនអាចទ្រាំទ្រនឹងពលកម្មដ៏ធ្ងន់ធ្ងរនេះបាន នៅដើមឆ្នាំ១៩៧៨ វុឌ្ឍី បានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង ។ ដោយឃើញកូនមានរូបរាងស្គមស្គាំង និងស្លេកស្លាំងបែបនេះ ឆែម បានលួចយំតែម្នាក់ឯង ព្រោះមិនដឹងធ្វើយ៉ាងណាដើម្បីជួយកូនបាន ។ ក្រោយមក វុឌ្ឍី ដែលជាក្តីសង្ឃឹមចុងក្រោយនេះក៏បានស្លាប់ទៅទៀត ។ អ្វីៗហាក់ដូចជាអស់រលីងពីខ្លួន ព្រោះប្រពន្ធនិងកូនទាំងប្រាំស្លាប់ទាំងអស់ ។ ឃើញដូច្នេះ មេកងក៏មានចិត្តអាណិត ឆែម ដោយបានអនុញ្ញាតឲ្យគាត់មកមើលសពកូនរបស់គាត់ជាលើកចុងក្រោយដែរ ។ ឆែម បានរៀបរាប់ទាំងទឹកមុខស្រងូតស្រងាត់ថា «ក្នុងចំណោមកូនទាំងប្រាំនាក់ វុឌ្ឍី គឺជាកូនដែលមានភ័ព្វសំណាងជាងគេ ព្រោះខ្ញុំបានឃើញសពនិងលើកត្រកងបីកូនដោយផ្ទាល់ដៃខ្ញុំមុននឹងកម្មាភិបាល

ខ្មែរក្រហមយកសពរបស់វាទៅកប់» ។ ឆែម បានបន្តថា «កាលណោះខ្ញុំមិនបានសម្រក់ទឹកភ្នែកទេ ទោះបីជាកូនរបស់ខ្ញុំស្លាប់យ៉ាងអាណោចអាធ័មក៏ដោយ ប៉ុន្តែនៅក្នុងចិត្តវិញគឺមានការឈឺចាប់ និងសោកសង្រេងជាខ្លាំង ដោយមានតែព្យាយាមពង្រឹងស្មារតីរបស់ខ្លួន និងលើកកូនបីទាំងក្តីរន្ធត់បំផុត» ។ មួយស្របក់ក្រោយមក ខ្មែរក្រហមបានយកសពរបស់ វុឌ្ឍី ពីដៃរបស់គាត់ទៅកប់នៅក្នុងព្រៃក្រោយភូមិបាត់ទៅ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ ឆែម បានវិលត្រឡប់មកទីក្រុងភ្នំពេញ និងបានចូលបម្រើការងារនៅក្រសួងអប់រំ ។ ឆែម បានរៀបរាប់ឲ្យដឹងថា «នៅរាល់បុណ្យទានម្តងៗ គាត់តែងតែធ្វើពិធីបុណ្យបង្សុកូលបញ្ជូនមគ្គផលទៅប្រពន្ធ កូន ព្រមទាំងសាច់ញាតិរបស់គាត់ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមជានិច្ច ដើម្បីឲ្យអ្នកទាំងនោះទៅកាន់សុគតិភព» ។

ឥឡូវនេះ នៅពេលដែលព្ធ័ត៌មានស្តីពីការកត់ត្រាឈ្មោះអ្នកដែលស្លាប់និងបាត់ខ្លួននៅក្នុងរបបខ្មែរក្រហមតាមរយៈវិទ្យុ ដើម្បីបោះពុម្ពសៀវភៅស្វែងរកគ្រួសារ ឆែម សប្បាយចិត្តជាខ្លាំង ព្រោះគាត់សង្ឃឹមថា រឿងរ៉ាវរបស់គាត់នឹងត្រូវបានប្រជាជនផ្សេងទៀតក៏ដូចជាក្មេងជំនាន់ក្រោយបានដឹងរឿងរ៉ាវរបស់គាត់ដែលបានបាត់បង់គ្រួសារនៅក្នុងរបបនោះ ។ ដូច្នេះហើយ ឆែម និង ចៅប្រុសរបស់គាត់បានមកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីចុះឈ្មោះប្រពន្ធនិងកូនៗរបស់គាត់នៅក្នុងសៀវភៅនោះ ។ ឆែម បានបន្តថា «នេះជាលើកទីមួយហើយដែលប្រពន្ធ និងកូនរបស់ខ្ញុំមានអ្នកយកចិត្តទុកដាក់ ព្រោះរយៈពេលជាង៣០ឆ្នាំមកហើយ ដែលខ្ញុំបានលាក់ទុកនូវការឈឺចាប់ទាំងនេះនៅក្នុងចិត្ត ។ ខ្ញុំមកនេះមិនមែនមកដើម្បីសងសឹកទេ គឺបញ្ជាក់ឲ្យប្រជាជនទាំងអស់ដឹងថា អ្នកដែលស្លាប់នៅក្នុងរបបដ៏សាហាវឃោរឃៅនេះមានគេដឹងឮ និងយកចិត្តទុកដាក់ហើយ ។ លើសពីនេះទៅទៀត សៀវភៅនេះអាចឲ្យក្មេងៗជំនាន់ក្រោយបានដឹង ជាពិសេសអាចជួយដល់អ្នកដែលបាត់ខ្លួននៅក្នុងរបបនោះរកឃើញសាច់ញាតិដែលនៅរស់ ព្រមទាំងឲ្យសាច់ញាតិរបស់ជនរងគ្រោះបានធូរស្បើយពីអារម្មណ៍ទៀតផង» ។ ខាងក្រោមនេះជាឈ្មោះរបស់ក្រុមគ្រួសាររបស់ ឆែម ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ៖

- ◆ ប្រពន្ធ ឆេង ផុំ
- ◆ កូនទីមួយ កែន ប៉ុណ្ណវុឌ្ឍ ហៅ ឆាន់
- ◆ កូនទីពីរ កែន ធនវុឌ្ឍ ហៅ ឆេន
- ◆ កូនទីបី កែន វុឌ្ឍី
- ◆ កូនទីបួន កែន បញ្ញាវុឌ្ឍ
- ◆ កូនទីប្រាំ កែន ផល្លា

**អ៊ុច ប៊ុន**

# ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការ ព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីសង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីរិសាវិណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។

**សូមអរគុណ**

# ខ្លោជីវិត

ទោះបីរបបខ្មែរក្រហមបានកន្លងផុតទៅអស់រយៈពេលបីទសវត្សរ៍ហើយក៏ដោយ ក៏ស្នាមរបួសដែលខ្មែរក្រហមបានដុតត្រាដែកបោះនៅលើទ្រូងខាងឆ្វេងរបស់ប៉ារូខ្ញុំបានបន្សល់ទុកនៅជាប់ខ្លួនរបស់គាត់រហូតដល់សព្វថ្ងៃ ។ នៅពេលដែលឃើញស្លាកស្នាមនេះ ប៉ារបស់ខ្ញុំតែងតែនឹកឃើញជានិច្ចពីរបបខ្មែរក្រហមជាពិសេសរបបនេះបានសម្លាប់ឪពុកម្តាយ និងបងប្អូនរបស់គាត់ទាំងប្រាំមួយនាក់ធ្វើឲ្យរូបគាត់ក្លាយជាក្មេងកំព្រា ។

ប៉ារបស់ខ្ញុំឈ្មោះ ស៊ិន ផល្គុន កើតឆ្នាំ១៩៦៥ និងជាកូនទីបីនៅក្នុងចំណោមបងប្អូនប្រាំមួយនាក់ ដោយគាត់រស់នៅក្នុងវង្សត្រកូលមួយប្រកបទៅដោយភាពថ្លៃថ្នូរនិងសេចក្តីសុខក្នុងក្រុងព្រះសីហនុ ។ ឪពុករបស់លោកប៉ាឈ្មោះ ស៊ិន នី មានតួនាទីជាក្រឡាបញ្ជីនៅក្រុងព្រះសីហនុ និងម្តាយឈ្មោះ ឡឹក នាង ជាមេផ្ទះ ។

ក្រោយពីទទួលជ័យជម្នះនៅក្នុងឆ្នាំ១៩៧៥ ក្រុមអាវខ្មៅបានបង្ខំឲ្យប្រជាជនទាំងអស់ចាកចេញពីលំនៅរបស់ខ្លួន ។ ពេលនោះ គ្រួសាររបស់ប៉ាខ្ញុំក៏ត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងភូមិប្រាំង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុងវិញ ។ នៅទីនោះខ្មែរក្រហមចាប់ផ្តើមបំបែកគ្រួសាររបស់គាត់ឲ្យទៅរស់នៅឆ្ងាយៗពីគ្នា ដោយតារបស់ខ្ញុំត្រូវបានចាត់តាំងឲ្យទៅរស់នៅក្នុងកងបុរស (កងភ្នូរ) ហើយយាយនៅក្នុងកងនារី (កងស្នូង) ។ ចំណែកបងប្រុសពីរនាក់របស់ប៉ានិងប្អូនស្រីម្នាក់រស់នៅក្នុងកងកុមារ ប្អូនប្រុសៗពីរនាក់ទៀតនៅជាមួយម្តាយ ចំណែកឯប៉ារស់នៅតែម្នាក់ឯងជាមួយកុមារដទៃទៀត ។ បន្ទាប់មក ខ្មែរក្រហមបានចាត់តាំងប៉ារបស់ខ្ញុំឲ្យកាប់ទន្ទ្រានខែត្រ រើសអាចម៍គោនិងរែកដីលាមកមនុស្សសម្រាប់យកទៅជ្រលក់ឫសសំណាប ។ ប៉ារបស់ខ្ញុំខិតខំធ្វើការយ៉ាងអស់កម្លាំងកាយចិត្ត ប៉ុន្តែអាហារដែលគាត់ទទួលបានគឺត្រឹមតែបបរាវមួយចាន និងជួនកាលមានលាយដំឡូង ឬពោតប៉ុណ្ណោះ ។ ប៉ារបស់ខ្ញុំបានរៀបរាប់ឲ្យដឹងថា ថ្ងៃខ្លះគាត់ថែមទាំងអត់មានរបបអាហារហូបទៀតផងដោយសារតែកូនអ្នកមូលដ្ឋានយករបបគាត់ទៅហូបអស់ជាញឹកញយ ។ ដោយតែធ្វើការហត់អស់កម្លាំងនិងឃ្លានខ្លាំងផង ប៉ារបស់ខ្ញុំក៏បានសម្រេចចិត្តលួចស្ទាក់វាយធ្វើបាបកូនអ្នកមូលដ្ឋាននោះដោយយកដីខ្សាច់ញាត់ចូលមាត់កូននោះ ។ ប៉ុន្តែក្រោយហេតុការណ៍នេះ ឪពុករបស់ក្មេងនោះខឹងយ៉ាងខ្លាំង ហើយក៏ចាប់គាត់ទៅចងផ្អោបជាមួយសសរដែលមានសំបុកស្រមោចក្រហមនៅពីក្រោម រួចក៏រុកឲ្យស្រមោចផ្អើលចេញមកខាំខ្លួនរបស់គាត់រហូតដល់សន្លប់បាត់ស្មារតី ។ ប៉ុន្តែសំណាងល្អ ព្រោះចាស់ៗអាណិតគាត់ និងជួយលើកគាត់យកទៅកប់ភក់រយៈពេលមួយម៉ោងក្រោយមកទើបភ្ញាក់ដឹងខ្លួនវិញ ។

ក្រោយមក មេកងបានផ្លាស់ប៉ាឲ្យទៅរស់នៅកងកុមារផ្សេងមួយទៀត ។ នៅទីនោះ ដោយសារតែការហូបចុកមិនបានគ្រប់គ្រាន់ គាត់ក៏បានសម្រេចចិត្តរត់ចេញពីកងទៅរស់នៅជាមួយលោកយាយវិញ ។ ដោយឃើញចៅគ្មានបបរហូប លោកយាយត្រូវចែករបបបបររបស់គាត់និងរបបប្អូនប្រុសទាំងពីរដើម្បីឲ្យប៉ាដែលមានរូបរាងស្គមស្គាំងបានហូបដែរ ។ រស់នៅជាមួយគ្នាមិនយូរប៉ុន្មាន លោកយាយបានបង្ខំឲ្យប៉ារត់ចេញពីទីនេះទៀតដោយសារតែគាត់បានឃើញលោកយាយចាស់ម្នាក់បានយកកាម៉ែល (ម្ហូកទាហាន) សម្រាប់ដាក់បបរចៅទៅភ្នូរនៅដើមឈើរួចហើយក៏ចុះទៅដួតទឹក តែត្រូវកងឈ្លបទៅទាន់ ហើយចោទថាយកបាយឲ្យខ្មាំង ។ បន្ទាប់មក លោកយាយនោះក៏ត្រូវចាប់ចងស្លាបសេក រួចអារ-កសម្លាប់ ដោយហៅឲ្យអ្នកនៅក្នុងសហករណ៍ទាំងអស់មកមើល និងហាមមិនឲ្យងាកមុខចេញឡើយ ។

នៅក្នុងឆ្នាំ១៩៧៦ ប្អូនប្រុសរបស់ប៉ាឈ្មោះ ស៊ិន សុគន្ធីបានស្លាប់ដោយសារពុលហ៊ីង ។ នៅឆ្នាំ១៩៧៧ ដោយសារស្ថានភាពកាន់តែលំបាកទៅៗ និងគ្មានអ្វីហូប ប៉ាបានលួចដកដំឡូងឈើមកដុតហូប ។ ពីរ-បីថ្ងៃក្រោយមក ឈ្លបបានមកចាប់គាត់បណ្តើរយកទៅឃុំទុកនៅផ្ទះបាយរយៈពេលពីរថ្ងៃ រួចបញ្ជូនទៅដាក់ក្នុងគុកមួយទៀត ដោយជើងរបស់គាត់ត្រូវដាក់ខ្នោះឃ្នាងនិងចងស្លាបសេកដែលធ្វើឲ្យដៃទាំងសងខាងរបស់គាត់ត្រូវហើម ។ រយៈពេលពីរថ្ងៃក្រោយមក ឈ្លបទាំងនោះបានបញ្ជូន

គាត់ទៅដាក់នៅក្នុងគុកមួយកន្លែងទៀតជាមួយអ្នកទោសចាស់ៗជាច្រើននាក់ទៀត ។ ជាប់នៅទីនោះមួយរយៈ គាត់ត្រូវបានបញ្ជូនបន្តទៅឃុំនៅក្នុងគុកភ្នំយុនឆាង ។ នៅទីនោះ គាត់បានឃើញពីការធ្វើទារុណកម្មយ៉ាងសាហាវឃោរឃៅរបស់ឆ្មាំគុកមកលើអ្នកទោស ។ ប៉ាបានរៀបរាប់ដោយទឹកមុខស្រងូតស្រងាត់ថា «ខ្ញុំបានឃើញឈ្លបខ្មែរក្រហមយកថង់ប្លាស្ទិកខ្ទប់មុខអ្នកទោសរហូតដល់ដួលសន្លប់បាត់ស្មារតី រួចក៏អូសអ្នកទោសនោះទៅជះទឹក នៅពេលដឹងខ្លួនក៏បន្តការសួរចម្លើយទៀត ។ បន្ទាប់ពីសួរចម្លើយរួចរាល់ ឈ្លបនោះក៏បណ្តើរអ្នកទោសទៅក្នុងព្រៃដែលនៅមិនឆ្ងាយប៉ុន្មានពីកន្លែងសួរចម្លើយនោះ» ។ ប៉ារបស់ខ្ញុំមានអារម្មណ៍ភ័យតក់ស្លុតយ៉ាងខ្លាំងដោយមួយសន្ទុះក្រោយមកគាត់ស្រាប់តែឮសំឡេងដូសៗនិងសម្រែកស្រែកយ៉ាងគ្រលួចចេញពីព្រៃដែលនេះបញ្ជាក់ថា អ្នកទោសនោះត្រូវបានសម្លាប់ហើយ ។ អ្នកទោសនៅទីនោះបានស្លាប់ជាបន្តបន្ទាប់ ក្រោយពីសួរចម្លើយរួចដោយនៅសល់តែប៉ារបស់ខ្ញុំម្នាក់ប៉ុណ្ណោះដែលខ្មែរក្រហមទុកជីវិតឲ្យព្រោះគាត់ជាកុមារដែលតូចជាងគេមានអាយុត្រឹមតែ ១២-១៣ឆ្នាំ ។ ប៉ុន្តែមុនពេលដោះលែង ឈ្លបទាំងនោះបានយកត្រាដែកដែលមានរូបទង់បដិវត្តន៍ដុតឡើងពណ៌ក្រហមយកមកបោះនៅទ្រូងខាងឆ្វេងក្រោមដោះរបស់ប៉ា ដែលស្លាកស្នាមនេះនៅបន្សល់ទុករហូតដល់សព្វថ្ងៃ ។ ទោះបីជាប៉ាមានសេរីភាពពិតមែន ប៉ុន្តែគាត់ត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់ ដោយត្រូវលើកភ្លឺស្រែក្នុងមួយថ្ងៃឲ្យបានមួយម៉ែត្រគូបទៅពីរម៉ែត្រគូបចាប់តាំងពីព្រឹករហូតដល់យប់ ។

នៅឆ្នាំ១៩៧៧ បងប្រុសច្បងរបស់ប៉ាឈ្មោះ ស៊ិន បូផល ក៏ត្រូវស្លាប់ដោយសារតែអត់អាហារនិងកើតជំងឺហើម ។ នៅចុងឆ្នាំ ១៩៧៧ លោកតារបស់ខ្ញុំស្រាប់តែត្រូវយោធាមកពីបូព៌ាបញ្ជូនទៅរៀនសូត្រ (យកទៅសម្លាប់) ។ ក្រោយពីទទួលបានដំណឹងនេះភ្លាម លោកយាយក៏ចាប់ផ្តើមធ្លាក់ខ្លួនឈឺ ។ មួយរយៈក្រោយមក អង្គការបានហៅគាត់ទៅកសាងដោយសារតែគាត់យកខ្សែកមួយខ្សែទៅដូរយកអំបិលមកហូប ។ ឃើញស្ថានភាពបែបនេះ ប្អូនប្រុសស្រីរបស់គាត់ពីរនាក់ទៀតឈ្មោះ ស៊ិន រតនា និង ស៊ិន សុភាសី បានទៅរើសក្បាលដំឡូងឈើដែលសហករណ៍កាប់ចោលយកមកដុតឲ្យគាត់ពិសា តែត្រូវឈ្លបមកទាន់ ហើយក៏ចោទថាមើលងាយអង្គការ ។ ឈ្លបទាំងនេះបានចាប់គាត់ចងស្លាបសេក ដោយរឹតចំណងយ៉ាងតឹង ។ រយៈពេលបីថ្ងៃក្រោយមក លោកយាយបានពិការដៃឆ្វេងម្ខាង ហើយធ្លាក់ខ្លួនឈឺជាទម្ងន់ រហូតបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ។

នៅពេលដែលប៉ាដឹងថា លោកតាត្រូវបានចាប់ខ្លួនយកទៅសម្លាប់ និងយាយធ្លាក់ខ្លួនឈឺជាទម្ងន់ គាត់ក៏បានលួចរត់មកមើលលោកយាយដែលកំពុងសម្រាកនៅក្នុងមន្ទីរពេទ្យ ដោយបានយកត្រីប្រឡាក់បួនកន្ទុយដែលគាត់រកបានទៅជូនគាត់ពិសា ។ ប៉ុន្តែគាត់មិនបានហូបត្រីទាំងនេះទេ ព្រោះពេទ្យបានយកទុកជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយថែមទាំងបញ្ជាឲ្យគាត់ទៅជម្រះស្មៅក្នុងបរិវេណពេទ្យទៀតផង ។ លោកប៉ាបានឮសូរសំឡេងខ្សាវៗចេញពីមាត់លោកយាយសុំអង្វរពេទ្យថា «ឲ្យខ្ញុំសុំហូបត្រីប្រឡាក់ដែលកូនខ្ញុំយកមកឲ្យផង ខ្ញុំរស់នៅមិនបានយូរទៀតទេ» ។ រំលងបានពីរ-បីថ្ងៃ លោកយាយក៏ស្លាប់ទៅ ។ មួយរយៈក្រោយមក ប៉ាបានឮដំណឹងថា ប្អូនប្រុស-ស្រីរបស់គាត់ស្លាប់ទៀត ។

ក្រោយពីលោកយាយស្លាប់ទៅ លោកប៉ាបានក្លាយជាមុខសញ្ញាដែលអង្គការត្រូវតាមចាប់ខ្លួន ។ ដូច្នេះហើយ គាត់ក៏រត់ចូលទៅពួនក្នុងព្រៃលើភ្នំយុនឆាងអស់រយៈពេលជាង១ឆ្នាំ ដោយហូបស្លឹកឈើនិងយប់ឡើងលួចចូលភូមិមកដកដំឡូងនៅក្នុងសហករណ៍ហូបប៉ុណ្ណោះ នៅពេលឈ្លបខ្មែរក្រហមធ្វេសប្រហែស ។ ប៉ារស់នៅទីនោះជាមួយក្មេងពីរនាក់ទៀតរហូតដល់កងទ័ពវៀតណាមចូលមករំដោះ ។ ក្រោយមក កងទ័ពវៀតណាមទាំងនោះក៏នាំប៉ាទៅជាមួយដែរ ។ មួយរយៈក្រោយមក អ៊ំប្រុសម្នាក់ដែលស្គាល់ក្រុមគ្រួសារប៉ាកាលពីពេលមុននោះបានសុំប៉ាយកគាត់ទៅរស់នៅជាមួយ ។ នៅពេលដែលប៉ាបានទៅបើករបបអង្ករ មុនពេលចាកចេញ អ៊ំប្រុសនោះគាត់ក៏បានជួបជាមួយអ្នកដែលបើកអង្ករហើយបានសួរប៉ាថាជាកូនរបស់អ៊ំប្រុសនោះឬ? ក្រោយពីប៉ាបដិសេធថាមិនមែន ក្រោយមកទើបគាត់សួរប៉ាទៅក៏ដឹងថា ប៉ាជាកូនរបស់ក្រឡាបញ្ជីឈ្មោះ ទន់ ។ បន្ទាប់មក គាត់បានទៅប្រាប់បងស្រីជីដូនមួយរបស់ប៉ាម្នាក់ដែលរស់នៅក្រុងភ្នំពេញឈ្មោះ ម៉ាក់ ណេង ឲ្យបានដឹង ហើយយកគាត់មករស់នៅក្រុងភ្នំពេញ

វិញ ។ ដោយសារតែជីវភាពគ្រួសាររបស់គាត់ជួបការលំបាក និងពុំមានលទ្ធភាពចិញ្ចឹមប៉ា ឪពុកមាររបស់គាត់ក៏យកគាត់មកចិញ្ចឹមវិញ ។ ប៉ាបានខិតខំប្រឹងប្រែងធ្វើការគ្រប់បែបយ៉ាងដើម្បីបន្តការសិក្សាឲ្យបានចប់ ទោះបីជាការងារនោះមានការលំបាកយ៉ាងណាក៏ដោយ ។

ជាលទ្ធផល ប៉ាបានប្រឡងជាប់សញ្ញាបត្រទុតិយភូមិ ក្រោយមកប្រឡងជាប់នៅសាលាកសិកម្មព្រែកលៀប ដោយជាប់ចំណាត់ថ្នាក់លេខ២ នៅទូទាំងសាលានិងថែមទាំងមានការងារធ្វើដ៏សមរម្យទៀតផង ។ ប៉ុន្តែ ភាពជោគជ័យរបស់ប៉ាបានត្រឹមតែធ្វើឲ្យគាត់សប្បាយចិត្តមួយភ្លែតនោះទេ ព្រោះគាត់មិនបានឃើញឪពុកម្តាយនិងបងប្អូនរបស់គាត់មកអបអរសាទរគាត់ឡើយ ។ ការបាត់បង់គ្រួសារនេះគឺជាសុបិនអាក្រក់មួយដែលតែងតែមកលងគាត់ជាពិសេសនៅពេលដែលធ្វើបុណ្យឧទ្ទិសកុសលទៅឪពុកអ្នកម្តាយនិងបងប្អូនរបស់គាត់ ។ ខាងក្រោមនេះជាឈ្មោះរបស់ក្រុមគ្រួសារប៉ា ៖

- ឪពុក ស៊ិន នី ស្លាប់
- ម្តាយ ឡឹក នាង ស្លាប់
- បងប្រុស ស៊ិន បូផល កើតឆ្នាំ ១៩៦២ ស្លាប់
- បងប្រុស ស៊ិន ស៊ីនី កើតឆ្នាំ ១៩៦៤ ស្លាប់
- ប្អូនប្រុស ស៊ិន សុគន្ធី កើតឆ្នាំ ១៩៦៧ ស្លាប់
- ប្អូនស្រី ស៊ិន រតនា កើតឆ្នាំ ១៩៦៩ មិនច្បាស់ថាស្លាប់ ឬបាត់ខ្លួន ។
- ប្អូនប្រុស ស៊ិន សុរាសី កើតឆ្នាំ១៩៧០ មិនច្បាស់ថាស្លាប់ ឬបាត់ខ្លួន ។

**ឆន់ ឧត្តម**

# សេចក្តីប្រកាសស្វែករកប្អូនប្រុសឈ្មោះ ង៉ូវ ជាបហេង

នាងខ្ញុំឈ្មោះ ង៉ូវ ជានលន់ អាយុ៦៤ឆ្នាំ សព្វថ្ងៃរស់នៅផ្ទះលេខ២០៣ ផ្លូវគ្រួសក់ផ្អែម សង្កាត់បឹងកេងកង ខណ្ឌចម្ការមន ក្រុងភ្នំពេញ ។ នាងខ្ញុំសូមប្រកាសស្វែករកប្អូនប្រុសទីបីឈ្មោះ ង៉ូវ ជាបហេង ដែលបានទៅរកស៊ីថ្មៃត្បូងនៅប៉ៃលិននៅ១៩៧៤ ។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ជាបហេង ក៏បានបាត់ដំណឹងរហូត ។ កាលពីសង្គមចាស់ ខ្ញុំរស់នៅម្តុំរោងសិប្បកម្មធ្វើតាំងហ៊ុននៅភូមិទឹកវល់ ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ។

ប្រសិនបើបងប្អូនណាបានឃើញ ឬបានឮឈ្មោះខាងលើនេះ សូមមេត្តាទំនាក់ទំនងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១២ ៨៣៤ ៧៤៧ ឬ ០៩២ ៩៩៩ ៥៣១ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សូមអរគុណ ។

# ដំណឹងស្វែងរកបងស្រីចិញ្ចឹម

ខ្ញុំបាទឈ្មោះ សឹង ស៊ីថា អាយុ៤៨ឆ្នាំ រស់នៅភូមិអន្លង់ស្ពាន ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង ។ ខ្ញុំសូមប្រកាសស្វែករកបងស្រីឈ្មោះ យ៉េស មានស្រុកកំណើតនៅកំបូល ខេត្តកណ្តាល ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានជម្លៀសបងស្រីទៅនៅសហករណ៍ចាហួយ ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសខ្ញុំ (សឹង ស៊ីថា) ឪពុកម្តាយនិងបងប្អូនទាំងអស់ពីខេត្តស្វាយរៀងឲ្យទៅរស់នៅសហករណ៍ចាហួយ ។ នៅទីនោះ ខ្មែរក្រហមបញ្ចូលខ្ញុំទៅនៅក្នុងកងពិសេស និងចាត់តាំងខ្ញុំឲ្យទៅជីកប្រឡាយនៅកំពង់ខ្វាងដោយមិនឲ្យឈប់សម្រាកឡើយ ។ ឃើញដូច្នេះ បង យ៉េស បានទៅស្នើមេកងយកខ្ញុំទៅធ្វើជាការជាមួយ ដោយគាត់លើកហេតុផលថា នៅកងរបស់គាត់គ្មានកម្លាំងមនុស្សប្រុសកាប់ដី ។ រៀងរាល់ថ្ងៃ បង យ៉េស តែងតែលួចលាក់បាយទុកឲ្យខ្ញុំហូប និងដេរប៉ះខោអាវឲ្យខ្ញុំ ។

ក្រោយរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំ និងឪពុកម្តាយធ្វើដំណើរត្រឡប់មកស្រុកកំណើតនៅខេត្តស្វាយរៀងវិញ ក៏បានជួបនឹងបង យ៉េស នៅខេត្តពោធិ៍សាត់ម្តងទៀត ប៉ុន្តែ ចាប់តាំងពីពេលនោះខ្ញុំពុំដែលទទួលដំណឹងគាត់ឡើយ ។

បើបងប្អូនណាស្គាល់ឈ្មោះ យ៉េស ឬបង យ៉េស បានទទួលដំណឹងនេះ សូមទាក់ទងមកខ្ញុំតាមអាស័យដ្ឋាន ភូមិអន្លង់ស្ពាន ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង ឬ តាមរយៈទូរស័ព្ទលេខ ០១៥ ៦១៩ ៥៥១ ។ សូមអរគុណ ។

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ ៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ ៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 131, November 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.